# ការជំរុញអោយមានសមភាពនៃយេនឌ័រ
# ក្នុងសកម្មភាពប្រឆាំងនឹងពលកម្មកុមារ និងការជួញដូរ

## មគ្គុទ្ទេសក៍ជាក់ស្តែងសំរាប់អង្គការ

**Nelien Haspels និង Busakorn Suriyasarn**



បាងកក ខែ កញ្ញា ឆ្នាំ ២០០៣
អង្គការពលកម្មអន្តរជាតិ (**ILO**
កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (**IPEC**
ការិយល័យតំបន់សំរាប់អាស៊ី និង ប៉ាស៊ីភិច (**ROAP**
ការិយាល័យអនុតំបន់សំរាប់អាស៊ីខាងកើត (**SRO**-បាងកក
I:\BS\GECL\Docs\Guide GECL-NH/BS( កញ្ញា 2003 doc.

# ការជំរុញអោយមានសមភាពនៃយ៉េនឌ័រក្នុង

## សកម្មភាពប្រឆាំងនឹងពលកម្មកុមារ និងការជួញដូរ

### មគ្គុទ្ទេសក៍ជាក់ស្តែងសំរាប់អង្គការ

**Nelien Haspels** និង **Busakorn Suriyasarn**

បាងកក ខែ កញ្ញា ឆ្នាំ ២០០៣
អង្គការពលកម្មអន្តរជាតិ (**ILO**
កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (**IPEC**
ការិយល័យតំបន់សំរាប់អាស៊ី និង ប៉ាស៊ីភិច (**ROAP**
ការិយាល័យអនុតំបន់សំរាប់អាស៊ីខាងកើត (**SRO**-បាងកក
I:\BS\GECL\Docs\Guide GECL-NH/BS( កញ្ញា 2003 doc.

**រក្សាសិទ្ធិ C អង្គការពលកម្មអន្តរជាតិ 2003**
**បោះពុម្ពផ្សាយលើកទីមួយឆ្នាំ 2003**

ការបោះពុម្ពផ្សាយរបស់ការិយាល័យពលកម្មអន្តរជាតិទទួលច្បាប់រក្សាសិទ្ធិក្រោមពិធីការ 2 នៃអនុសញ្ញានៃច្បាប់រក្សាសិទ្ធិជាសកល ។ ទោះជាយ៉ាងណាក៏ដោយការដកស្រង់ខ្លីៗពីការបោះពុម្ពផ្សាយទាំងនេះអាចធ្វើទៅបានដោយមិនបាច់មានការអនុញ្ញាតិ ក្នុងលក្ខខណ្ឌណាដែលប្រភពត្រូវបានបង្ហាញ ។ ចំពោះសិទ្ធិនៃការបោះពុម្ពជាថ្មីឬការបកប្រែគួរធ្វើសំណើរទៅកាន់ការិយាល័យបោះពុម្ពផ្សាយ( សិទ្ធិ និងការអនុញ្ញាតិ របស់ការិយាល័យពលកម្មអន្តរជាតិ អស័យដ្ឋាន CH-1211 Geneva 22, Swilzerland ។ ការិយាល័យពលកម្មអន្តរជាតិទទួលស្វាគមន៍សំណើទាំងនេះ ។

---

បណ្ណាល័យ ស្ថាប័ននិងអ្នកប្រើប្រាស់ទាំងឡាយដែលបានចុះបញ្ជីនៅក្នុង United Kingdom ចក្រភព ( អង់គ្លេស ជាមួយទីភ្នាក់ងារផ្តល់អជ្ញាបណ្ណ័រក្សសិទ្ធិ អស័យដ្ឋាន 90 Tlttenhaml Court Road, London W 1T 4LP (Fax +442076315500, email: cla@cal.co.uk) នៅក្នុងសហរដ្ឋ ជាមួយមជ្ឈមណ្ឌលរក្សាសិទ្ធិ អស័យដ្ឋាន 222 Rosewood Drive, Danvers MA 01923 (Fax +19787504470, e-mail: info@copyright.com ) ឬនៅក្នុងប្រទេសឯទៀតជាមួយអង្គ ារសិទ្ធិបោះពុម្ពជាថ្មីដែលពាក់ពន្ធ័ ពួកគេអាចធ្វើការថតចំលងបានដោយអនុលោមតាមអជ្ញាបណ្ណ័ដែលបានចេញឱ្យពួកគេសំរាប់គោលបំណងនេះ ។

**Nelien Haspels និង Busakorn Suriyasarn**

**ការលើកកំពស់សមភាពយ៉េនឌ័រក្នុងសកម្មភាពប្រឆាំងការជួញដូរពលកម្មកុមារ ។ មគ្គុទ្ទេសក៏អនុវត្តសំរាប់អង្គការ**
**Bangkok, International Labour Office, 2003**
**ជាភាសាអង់គ្លេស Print : ISBN 92-2-115098-4, Web version, pdf. ISBN 92-2-115099-2**
**ក៏អាចរកបាននៅក្នុង**
**ជាភាសាចិន Print :ISBN 92-2-515098-9, Web version, pdf : ISBN 92-2-515099-7**
**ជាភាសាខ្មែរ Print : ISBN 922-815102-1, Web version, pdf ISBN 92-2-815103-X**
**ជាភាសាឡាវ Print : ISBN 92-2-815104-8, Web version, pdf. ISBN 92-2-815105-6**
**ជាភាសាថៃ Print: ISBN 92-2-815100-5, Web version, pdf. ISBN 92-2-815101-3**
**ជាភាសាវៀតណាម Print : ISBN 92-2-815098-X, Web version, pdf. ISBN 92-2-815099-8**

---

ការទទួលខុសត្រូវចំពោះមតិដែលបានសំម្តែងក្នុងអត្ថបទដែលចុះហត្ថលេខាហើយការសិក្សានិងការរួមវិភាគទានដ៏ទៃទៀតស្ថិតនៅតែជាមួយអ្នកនិពន្ធអត្ថបទឬការរួមវិភាគទានទាំងនោះ ចំណែកឯការបោះពុម្ពផ្សាយមិនបង្កើតនូវ ចំណារណាមួយដោយការិយាល័យពលកម្មអន្តរជាតិអំពីមតិដែលបានសំម្តែងក្នុងនោះទេ ។

យោងដល់ឈ្មោះក្រុមហ៊ុននិងផលិតផលពាណិជ្ជកម្មនិងដំណើរការ មិនបង្ហាញថាឈ្មោះទាំងនោះត្រូវបានគាំទ្រដោយការិយាល័យពលកម្មអន្តរជាតិទេ ហើយការអាក់ខានមិនបានរៀបរាប់ដំណើរការ ឈ្មោះក្រុមហ៊ុនឬផលិតផលពាណិជ្ជកម្មពិសេសណាមួយមិនមែនជាសញ្ញានៃការមិនយល់ព្រមទទួលស្គាល់នោះទេ។

ចំពោះពត៌មានអំពីរបៀបទទួលការបោះពុម្ពផ្សាយនេះ សូមសរសេរសំណើរទៅកាន់ការិយាល័យតំបន់សំរាប់អាស៊ីប៉ូពានិងប៉ាស៊ីហ្វិក អស័យដ្ឋាន 11th floor, United Nation Building, Rajdamnern Nok Avenue, Bangkok, 10200 Thailand, Fax +662288 3062, e-mail: lbroap@ilo.org. សំរាប់ Web version, visit our website wwwilo.org/asia/libraly/pub4.htm ។ កូនសៀវភៅ (catalogues) និងបញ្ជីនៃការបោះពុម្ពផ្សាយដែលនឹងចេញរបស់ ILO ក៏អាចរកបានដោយឥតគិតថ្លៃពីអស័យដ្ឋានដដែលនេះដែរ។

# សេចក្តីផ្តើម

**ភាគ ១**

បុព្វកថា......................................................................................................

**១ គំនិតជាមូលដ្ឋាន**

១.១ តើពាក្យយ៉េនឌ័រមានន័យយ៉ាងដូចម្តេច ? ......................................................

១.២ តើពាក្យថាសមភាពយ៉េនឌ័រមានន័យយ៉ាងដូចម្តេច ?................................................

១.៣ តើពាក្យថាការរើសអើងនៃយ៉េនឌ័រមានន័យយ៉ាងដូចម្តេច ?.........................................

១.៤ តើសិទ្ធិមនុស្សមានន័យយ៉ាងដូចម្តេច ?..........................................................

១.៥ តើសិទ្ធិជាមូលដ្ឋាននៃការងារមាន ន័យយ៉ាងដូចម្តេច ?.............................................

១.៦ តើសិទ្ធិជាមូលដ្ឋានសំរាប់កម្មករស្ត្រីមាន ន័យយ៉ាងដូចម្តេច ?.....................................

១.៧ តើសិទ្ធិកុមារមាន ន័យយ៉ាងដូចម្តេច ?...........................................................

១.៨ តើពលកម្មកុមារមាន ន័យយ៉ាងដូចម្តេច ?........................................................

១.៩ តើការជួញដូរមាន ន័យយ៉ាងដូចម្តេច ?...........................................................

១.១០ ទំនាក់ទំនងរវាងការផ្លាសប្តូរទីលំនៅ ការជួញដូរ និង ការកេងប្រវ័ញ្ចពលកម្ម...............................

១.១២ បញ្ហាប្រឈមមុខក្នុងការអនុវត្តច្បាប់ .......................................................

**២ សន្និធានភាពនិងភាពខុសគ្នានៃយ៉េនឌ័រសំខាន់ៗ នៅក្នុងពលកម្មកុមារ**

២.១ ហេតុការណ៍ជាក់ស្តែងនិងតួលេខ ..............................................................

២.២ បទពិសោធន៍ខុសគ្នារបស់កុមារា និងកុមារី ......................................................

២.៣ កុមារី និងស្ត្រី នៅក្នុងសង្គមដែលកំណត់ឱ្យមានឋានៈទាប .........................................

២.៤ ការអប់រំ និងការបំពាក់បំប៉ន សំរាប់ការងារ ......................................................

២.៥ ការងារដែលមិនបានទទួលប្រាក់កំរៃ និងការងារដែលមិនអាចមើលឃើញ ..............................

# មាតិកា


២.៦ ការងារដែលមានគុណភាពខ្ពស់-ទាប

២.៧ ការងារដែលមិនមានការការពារ និងខុសច្បាប់

២.៨ ប្រាក់ចំណូល និងប្រាក់ចំណាយ

២.៩ ចំណង់ចំណូលចិត្តចំពោះកម្មករជាស្ត្រី និងកុមារី

២.១០ ចំណង់ចំណូលចិត្តនៃកម្មករជាស្ត្រី និងកុមារី

២.១១ ទំនាក់ទំនងរវាង យុទ្ធសាស្ត្រអោយរស់របស់គ្រួសារ ការងាររបស់ស្ត្រី និងពលកម្មកុមារ

២.១២ ការចែករំលែកចំពោះការទទួលខុសត្រូវក្នុងគ្រួសារ

២.១៣ ការធ្វើតំណាងក្នុងការធ្វើសេចក្តីសំរេចចិត្ត

**៣ គោលការណ៍ចំបង និងយុទ្ធសាស្ត្រសំរាប់ជំរុញអោយមានសមភាព នៃយ៉េនឌ័រ ក្នុងកម្មវិធីប្រឆាំងនឹងពលកម្មកុមារ**

៣.១ គោលការណ៍សំខាន់ដើម្បីជំរុញឱ្យមានសមភាពយ៉េនឌ័រ

៣.២ ការបញ្ជ្រាប យ៉េនឌ័រ ឧបករណ៍សំខាន់ៗ

៣.៣ យុទ្ធសាស្ត្រចំបងអ្វីដែលត្រូវធ្វើ និង ត្រូវធ្វើដូចម្តេច

# មាតិកា

ភាគ២ ឧបករណ៍អនុវត្ត


**១. ឧបករណ៍មគ្គុទ្ទេសក៍យោងក្នុងការបណ្តុះបណ្តាល ៖គោលគំនិតសំខាន់ និង យុទ្ធសាស្ត្រ**

**១.១ គោលគំនិតជាមូលដ្ឋាន**

១.២ ភាពខុសគ្នានៃយេនឌ័រសំខាន់ៗក្នុងពលកម្មកុមារយុទ្ធសាស្ត្រចំបងដើម្បីជំរុញឱ្យមានសមភាពយេនឌ័រក្នុងសកម្មភាពប្រឆាំងពលកម្មកុមារ

១.៣ ឧបករណ៍សំខាន់ៗជំរុញឱ្យមានសមភាពយេនឌ័រ

**២. មគ្គុទ្ទេសក៍ ៖ របៀបបញ្ជ្រាបយេនឌ័រក្នុងការរៀបចំគំរោងសកម្មភាព**

២.១ ប្រវត្តិ និងការកែតម្រូវ........................................................

២.២ ក្រុមគោលដៅ........................................................

២.៣ ក្របខណ្ឌនៃស្ថាប័ន........................................................

២.៤ ទិសដៅ ........................................................

២.៥ លទ្ធផលសំខាន់ៗ និងសកម្មភាព ........................................

២.៦ សូចនករ ការសន្មត់ ហើយនិងកាតព្វកិច្ចអទិភាព ....................................

២.៧ ផែនការ និងទំរង់ការ ការត្រួតពិនិត្យ និងនៃការវាយតំលៃ ..............................

២.៨ ធនធាន ........................................................

**៣. តារាងត្រួតពិនិត្យ៖ តើអង្គការរបស់អ្នកបានរួមបញ្ចូលបញ្ហាយេនឌ័រក្នុងការរៀបចំកម្មវិធីសកម្មភាពឬទេ ?** ........................................

**៤. តារាងត្រួតពិនិត្យ៖តើបញ្ហាយេនឌ័រត្រូវបានរួមបញ្ចូលក្នុងគំរោងស្រាវជ្រាវរបស់អ្នកឬទេ?**

**៥. តារាងត្រួតពិនិត្យ ៖ នៅក្នុងសកម្មភាពប្រឆាំងពលកម្មកុមារ តើអ្នកបានប្រើប្រាស់យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឬទេ?**

**៦. តារាងត្រួតពិនិត្យ ៖ តើអង្គការរបស់អ្នកដោះស្រាយការជំរុញឱ្យមានសមភាពយេនឌ័រយ៉ាងដូចម្តេច?**

**ប្រភពព័ត៌មាន**........................................................

# បុព្វកថា

គ្រួសារទាំងឡាយនៅក្នុងសង្គមទាំងអស់ប្រាថ្នាចង់ឱ្យបុត្រ និងបុត្រធីតារបស់ខ្លួនមានភាពល្អប្រពៃបំផុត។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងពិភពលោកទាំងមូលយុវវ័យនិងកុមាររាប់លាននាក់បានធ្លាក់ខ្លួនជាជនរងគ្រោះក្នុងពលកម្មយ៉ាងធ្ងន់ធ្ងរ និងការរំលោភសិទ្ធិមនុស្ស ទាសភាពក្នុងសេវាកម្មបំរើតាមផ្ទះ ក្នុងឧស្សាហកម្មកមន្តសាលក្នុងការកំសាន្តសប្បាយ ឬលើដី។ភាគច្រើនបំផុតនៃជនរងគ្រោះទាំងនោះគឺក្មេងស្រីនិងនារីជំទង់ ប៉ុន្តែក្មេងប្រុសក៏ត្រូវបានគេ រកឃើញក្នុងចំណោមនោះដែរ។ ជារឿយៗពួកអ្នកទាំងនោះបានធ្វើចំណាកស្រុក ឬត្រូវបានគេជួញដូរ។ ពួកគេធ្វើការងារ និងរស់នៅក្នុងបរិយាកាសមួយដែលពួកគេមិនស្គាល់នៅក្រោមលក្ខខណ្ឌដែលនៅឆ្ងាយពីកុមារភាព និងសុខភាពរបស់ពួកគេ ហើយបំបាត់ចោលនូវការគោរពជាមូលដ្ឋាននិងដកហូតសិទ្ធិរបស់កុមារទាំងនោះដែលពួកគេ ត្រូវបានទទួលក្នុងឋានៈជាមនុស្សជាតិ។

ការជួញដូរនិងការធ្វើអាជីវកម្មលើកម្លាំងពលកម្មកុមារមិនមែនជាបញ្ហាមួយសាមញ្ញនៃយុទ្ធសាស្ត្រជាគ្រិះដើម្បីរស់រានរបស់ជនក្រីក្រទេ។ ការបំបែកកុមារចេញពីគ្រួសារ- ទោះជាបានដឹងឬមិនដឹង-ដើម្បីធ្វើអាជីវកម្មអាចត្រូវបាន ពន្យល់ថាដោយសារកង្វះនូវឱកាស ។ ជាពិសេសស្ត្រីជាម្តាយតែងតែមានជំរើសមួយចំនួនតូចហើយក៏ដូចជាយុវវ័យទាំងស្រីទាំងប្រុសវ័យក្មេងត្រូវបាននាំមកកាន់ទីក្រុង។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះវាឆ្ងាយហួសពីឧបសគ្គសេដ្ឋកិច្ច និងមហិច្ឆតារបស់មនុស្សម្នាក់ៗទៅទៀត។ វាជាការកៃច្នៃមុខមាត់ជាពហុភាពក្នុងទំហំទ្រង់ទ្រាយធំនិង បណ្តាលមកពីកត្តាអន្តរសកម្មភាពយ៉ាងស្មុគ្រស្មាញមួយ។ ភាពមិនស្មើគ្នានៃសេដ្ឋកិច្ចនៅក្នុងប្រទេស និងរវាង ប្រទេសនិងប្រទេសតំរូវការតម្លៃកម្លាំងពលកម្មថោក ឋានៈទាបរបស់ស្ត្រី ការធ្វើពាណិជ្ជកម្មនៃរាងកាយរបស់គេ និងការកើនឡើងនៃបណ្តាញឧក្រិដ្ឋកម្មយ៉ាងស្ទាត់ជំនាញបានជំរុញឱ្យផ្នែកតំរូវការនៃបញ្ហាទៅក្នុងបរិបទនៃសកល ភាវូបនីយកម្ម។ ភាពក្រីក្រ បំណងដែលចង់ឱ្យការរស់នៅកាន់តែប្រសើរឡើង និងទំនិញប្រើប្រាស់ជម្លោះនយោ បាយ គ្រោះធម្មជាតិ រួមជាមួយនិងកង្វះការអប់រំ និងពត៌មានច្បាស់លាស់ កលល្បិចស្របច្បាប់និងកត្តាដ៏ទៃទៀតបានបន្តឱ្យមានការកើនឡើងនៃការផ្គត់ផ្គង់ក្មេងជំនាន់ក្រោយសំរាប់ការធ្វើអាជីវកម្មកេងប្រវ័ញ្ចក្នុងទំរង់ផ្សេងៗជាច្រើន

យុវវ័យនិងកុមារដែលបានធ្លាក់ខ្លួនក្នុងកន្លែងការងារនិងលក្ខណ្ឌរស់នៅដែលទទួលរងនូវការធ្វើអាជីវកម្មនិងការរំលោភបំពានបានចែករំលែកនូវបញ្ហារួមរបស់ខ្លួនៈ ពួកគេប្រឈមមុខនិងការរើសអើង និងវិសមភាពក្នុងសង្គមពី ព្រោះពួកគេនៅក្មេងនិងក្រ ពួកគេជាកូនចៅរបស់ក្រុមជនជាតិភាគតិច និងជននិរប្រវេសន៍ ហើយក្នុងករណីរបស់ ក្មេងស្រីគឺពីព្រោះពួកគេជានារីភេទទន់ខ្សោយ។ តម្លៃនៃយេនឌ័រជាប្រពៃណីនិងវប្បធម៌បានកំណត់ស្ត្រីនិងកុមារ ក្នុងលំដាប់ទាបបំផុតក្នុងឋានានុក្រមនៃគ្រួសារនិងសហគមន៍។ វប្បធម៌និងប្រពៃណីនេះបានធ្វើឱ្យមានការមិន គោរពសិទ្ធិស្ត្រីនិងកុមារហើយបានធ្វើឱ្យពួកគេងាយរងគ្រោះដោយមិនហ៊ាននិយាយអំពីវាសនារបស់ពួកគេផ្ទាល់។ ការយល់ដឹងអំពីយេនឌ័រ អំពីវ័យ និងទំហំនៃការធ្វើអាជីវកម្មលើកម្លាំងពលកម្មនិងការជួញដូរនិងទំនាក់ទំនងជាមួយនិងវិសមភាពសេដ្ឋកិច្ចនិងសង្គម គឺជាគន្លិះនៃការចាប់ផ្តើមធ្វើសកម្មភាពដោយមាននិរន្តភាពដើម្បីលុបបំបាត់ចោលនូវការរំលោភបំពានទាំងនេះ។

សៀវភៅមគ្គុទេសក៏អនុវត្តសំរាប់អង្គការ "ការជំរុញឱ្យមានសមភាពយ៉េនដ័រក្នុងសកម្មភាពប្រឆាំងនឹងការជួញដូរនិងពលកម្មកុមារ" នេះមានបំណងដើម្បីបំរើជាក្បួនខ្នាតតូចងាយប្រើប្រាស់សំរាប់អ្នករៀបធ្វើគោលនយោបាយនិងអ្នកអនុវត្តទាំងឡាយដែលប្តេជ្ញាចិត្តដោះស្រាយបញ្ហាជួញដូរនិងអាជីវកម្មលើកម្លាំងពលកម្មដ៏ធ្ងន់ធ្ងរក្នុងចំណោមក្មេង ប្រុស ក្មេងស្រី បុរសនិងស្ត្រី។ សៀវភៅមគ្គុទេសក៏នេះបានទទួលប្រយោជន៏ពីទុន ជាច្រើនពីអ្នកជំនាញនិងអ្នកអនុវត្តមានបទពិសោធន៏យ៉ាងល្អក្នុងវិស័យនេះពីរដ្ឋជាសមាជិកជាច្រើនរបស់អង្គការ ILO ក៏ដូចជាសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុង ILO ដោយមានធនធានផ្តល់ដោយរដ្ឋាភិបាលរបស់អង់គ្លេស (UK) និងហូល្លង់។ គេសង្ឃឹមថា សៀវភៅមគ្គុទេសក៏នេះនឹងចូលរួមវិភាគទានក្នុងការស្វែងរកវិធីសាស្ត្រយ៉ាងមានប្រសិទ្ធិភាពដើម្បីកាត់បន្ថយនូវ ភាពងាយរងគ្រោះរបស់ក្មេងប្រុស ក្មេងស្រី និងគ្រួសាររបស់ពួកគេហើយផ្តល់ឱ្យពួកគេនូវមធ្យោបាយ ដើម្បីសំរេច នូវបទដ្ឋាននៃការរស់នៅយ៉ាងសមរម្យតាមរយៈការផ្តល់អំណាចនយោបាយ សង្គមនិងសេដ្ឋកិច្ចដល់ខ្លួន។

Chris Evans-Kloc
នាយក ការិយាល័យអនុតំបន់សំរាប់អាស៊ីបូព៌ា

Alice Ouedraogo
នាយកសាខាគោលនយោបាយ IPEC

ILO Bangkok និង Geneva, ខែកញ្ញាឆ្នាំ 2003

# សេចក្ដីផ្ដើម

ការលុបបំបាត់ពលកម្មកុមារ ការជួញដូរ និងការលើកកំពស់នៃសមភាពរវាងក្មេងប្រុស ក្មេងស្រី បុរស និងស្ត្រីត្រូវបានគេរួមដៃគ្នាអនុវត្ត ។ ពលកម្មកុមារ គឺជាការងារដែលបណ្ដាលឱ្យកុមារទទួលរងការកេងប្រវ័ញ្ច និងការរំលោភបំពាន ។ ការជួញដូរលើការ កេងប្រវ័ញ្ចពលកម្មមានន័យថា គឺជាការយកក្មេងឬមនុស្សចាស់ទៅ
កន្លែងដ៏ទៃៗទៀត ដើម្បីធ្វើការ ហើយការងារទាំងនោះ គឺជាការងារដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេ ។ ការលើកកំពស់សមភាពនៃយ៉េនឌ័រ មានន័យថា ជាការផ្ដល់ឱកាសស្មើៗគ្នា ចំពោះក្មេងប្រុស និងក្មេងស្រី បុរស និងស្ត្រី ។ ការប្រើប្រាស់ Gender Lens គឺសំខាន់សំរាប់ការពារ និងដោះស្រាយ ចំពោះបញ្ហាការជួញដូរពលកម្មកុមារ ។

ការប្រយុទ្ធប្រឆាំងចំពោះការជួញដូរពលកម្មកុមារ និងការលើកកំពស់សមភាពរវាងបុរស និងស្ត្រីភេទដោះស្រាយសិទ្ធិកម្មករនិងសិទ្ធិមនុស្សជាមូលដ្ឋានក្នុងជីវិតរស់នៅនិងនៅឯកន្លែងធ្វើការ ។ទាំងនេះជាចំនុច សំខាន់នាំទៅរកនិរន្តរភាព អង្គការមហាជន ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៃប្រទេសនានាក្នុងសេដ្ឋកិច្ចសកល ។ សកម្មភាពប្រឆាំងការជួញដូរពលកម្មកុមារ ហើយនិងការលើកកំពស់សមភាពយ៉េនឌ័រ មិនមានន័យថា ការប្ដូរយករបស់ថ្មី នៃផលចំណេញក្នុងការអភិវឌ្ឍន៍ដ៏ទៃទៀតតែមួយមុខនោះទេប៉ុន្តែជាការបង្កើនគុណភាពនៃការរស់នៅសំរាប់ទាំងអស់គ្នា ជាមួយនឹងការផ្ដល់នូវផលប្រយោជន៍ដែលគ្មានទីបញ្ចប់ដល់កុមារ គ្រួសារ សហគមន៍ និងសង្គមទាំងឡាយ ។

ទាំងក្មេងប្រុស និង ក្មេងស្រីដែលកើតចេញពីស្រទាប់គ្រួសារដែលមានចំណូលតិចតួច គឺធ្លាប់បានពាក់ព័ន្ធ ក្នុងពលកម្មកុមារ ហើយស្ត្រី និងបុរសគ្រប់វ័យ ក៏អាចក្លាយជាជនរងគ្រោះនៃការជួញដូរដែរ ។ ទោះជាយ៉ាងណា ក៏ដោយ ភស្តុតាងបង្ហាញថា ក្មេងស្រី និង ស្ត្រី ជាញឹកញាប់ត្រូវបានគេរកឃើញថាកំពុងធ្វើការក្នុងទំរង់ធ្ងន់ធ្ងរនៃ ពលកម្ម ដែលទាក់ទងទៅនឹងការផ្ដល់អោយពួកគេស្ថិតនៅក្នុងស្ថានភាពទាបក្នុងសង្គមជាច្រើន។ ក្មេងស្រីជាទូទៅគឺជាជនងាយរងគ្រោះចំពោះអំពើកេងប្រវ័ញ្ចកម្លាំងពលកម្ម ប្រឈមមុខបញ្ហាខុសគ្នាជាច្រើន ហើយមានយុទ្ធសាស្ត្រដោះស្រាយច្រើនជាងក្មេងប្រុស។ កម្មវិធីទាំងឡាយដែលធ្វើការប្រឆាំងការជួញដូរពលកម្មកុមារ ចាំបាច់ត្រូវការយកបញ្ហាខុសប្លែកគ្នាទាំងនោះមកដើម្បីពិចារណា ប្រសិនបើគេមានបំណងធ្វើការអោយមាន ប្រសិទ្ធិភាពចំពោះក្មេងស្រី និងក្មេងប្រុស ។

លើសពីនេះទៅទៀត ខណៈដែលតួនាទីដ៏សំខាន់របស់ឪពុកម្ដាយ ក្នុងការថែរក្សាសុខមាលភាពកូនចៅត្រូវបានគេដឹងឮទូទាំងពិភពលោកក៏ដោយ ក៏ឪពុកម្ដាយជាច្រើននៃក្រុមដែលមានប្រាក់ចំណូលតិចមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើការងារខាងលើបានទេ។ ជាពិសេស ម្ដាយដែលរស់តែឯង តែងប្រឈមមុខនឹងឧបសគ្គជាច្រើននៅក្នុងការងារនិងជីវិតពីព្រោះគាត់ក្រហើយគាត់ជាស្ត្រី ។ ផ្ទុយទៅវិញ ឪពុកជាច្រើនមិនបានចូលរួមគ្រប់គ្រាន់ក្នុងការថែរក្សាកូនទេ។ ដូច្នេះវាមានភាពចាំបាច់ណាស់ដើម្បីឱ្យឪពុកម្ដាយមានលទ្ធភាពធ្វើការចែករំលែកការទទួល ខុសត្រូវក្នុងគ្រួសារទាក់ទងទៅនឹងការធ្វើឱ្យមានភាពត្រចះត្រចង់ចំពោះអនាគតកូនចៅរបស់ពួកគេ ។

ដោយទទួលស្គាល់នូវបញ្ហាទាំងឡាយរបស់ស្ត្រីនៅក្នុងពិភពនៃការងារ រដ្ឋសមាជិករបស់ (ILO) បាន ផ្តោតការ យកចិត្តទុកដាក់លើសារៈសំខាន់នៃការផ្តល់ការចាប់អារម្មណ៍យ៉ាងពិសេស លើការលើកកំពស់ឱកាសស្មើគ្នា និង ឱកាសសំរាប់បុរស និងស្ត្រីនៅ កន្លែងការងារ និង ក្នុងការរស់នៅគ្រប់កន្លែងទាំងអស់ដែលILO ធ្វើសកម្មភាព ។ កម្មវិធីអន្តរជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) របស់ ILOបានកំណត់ក្មេងស្រីជាក្រុមគោលដៅ អាទិភាពចាប់តាំងពីការចាប់ផ្តើមរបស់ខ្លួននៅក្នុងទសវត្សឆ្នាំ៩០ ។ នៅក្នុងឆ្នាំ ១៩៩៩ គោលការណ៍ណែនាំស្តី អំពីដំណោះស្រាយលើតំរូវការរបស់ក្មេងស្រី គឺត្រូវបានគេយកមកពិភាក្សាវិញ នៅក្នុងអនុសាសន៍របស់ ILO ស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។ បទពិសោធន៏របស់ ILO បានបង្ហាញថា ការធ្វើសកម្មភាពព្រមគ្នា គឺចំបាច់ណាស់ដើម្បីធានាថា ក្មេងស្រី និង ក្មេងប្រុសដែលបានពាក់ព័ន្ធ ឬ បានធ្លាក់ទៅក្នុងសកម្មភាពពលកម្មកុមារ ត្រូវបានផ្តល់ជាមួយនឹងការទប់ស្កាត់ដ៏មានប្រសិទ្ធិភាព ឬ សេវាកម្មសុខភាព ហើយដើម្បីធានាថាគោលការណ៍ សមភាពត្រូវបានគេអនុវត្តន៏នៅពេលមានការផ្តល់នូវកាលើកទឹកចិត្តដល់ឪពុកម្តាយ និងអ្នកផ្តល់ការថែទាំដ៏ទៃ ទៀត១ ដែលពុំបានគិតពីភាពខុសគ្នានៃភេទ និង យ៉េនឌ័រ ។

សៀវភៅមគ្គុទេសក៏ណែនាំសំរាប់អង្គការ ផ្តល់នូវទិដ្ឋភាពនៃយុទ្ធសាស្ត្រ និងឧបករណ៍រួមដើម្បីនាំទៅដល់ ក្មេងស្រី និងក្មេងប្រុសនៅពេលប្រយុទ្ធប្រឆាំងការអនុវត្តពលកម្មកុមារដ៏គ្រោះថ្នាក់ និង ការរំលោភការជួញដូរដ៏ធ្ងន់ធ្ងរដល់កុមារ ដើម្បីឆ្លើយតបទៅ នឹងឧបសគ្គជាក់លាក់ ដែលក្មេងស្រី និងស្ត្រីវ័យជំទង់កំពុងប្រឈមនឹងបញ្ហា ឬដែលបានធ្លាក់ទៅក្នុងពលកម្មកុមារ និងដើម្បីពង្រឹងតួនាទីនៃឪពុកម្តាយក្នុងការអប់រំកូនចៅរបស់ពួកគេនិងការពារពួកគេពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម ។មគ្គុទេសនេះ មានបំណងណែនាំផ្តល់ដល់បុគ្គលិករដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយដែលធ្វើការពាក់ព័ន្ធការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងការជួញដូរ ។ អ្នករៀបចំគោលនយោបាយ ដែលចូលរួមលើកកំពស់ សិទ្ធកុមារ និងស្ត្រី គោលការណ៍ ច្បាប់ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការងារក៏អាចប្រើប្រាស់សៀវភៅមគ្គុទេសក៏នេះបានដែរ ។

មគ្គុទេសក៏ណែនាំនេះ មានបំណង :

- **ផ្តល់ពត៌មានដល់អ្នកជំនាញនិងបុគ្គលិកកម្មវិធីនៅក្នុងកិច្ចការពលកម្មកុមារហើយដែលមិនមានការយល់ច្បាស់ពីបញ្ហាសមភាព យ៉េនឌ័រ ឬ ចំពោះអ្នកដែលមានបំណងរំលឹកនូវចំណេះរបស់ពួកគេចំពោះប្រធានបទនេះ ។**
- **ជួយបុគ្គលិកនិងអង្គការជាដៃគូរនៃកម្មវិធីអន្តរជាតិរបស់អង្គការ ILOស្តីអំពីការលប់បំបាត់ការងារពលកម្មលើកុមារ(IPEC) របស់ILO នៅក្នុងការអភិវឌ្ឍន៍ អនុវត្តន៍ និងការវាយតំលៃលើកម្មវិធីសកម្មភាពឆ្លើយតបផ្នែក យ៉េនឌ័រ ។**

មគ្គុទេសក៏ដែលណែនាំនេះមានពីរផ្នែក ៖

- ផ្នែកទី១ផ្តល់នូវនិយមន័យជាមូលដ្ឋាន និង យុទ្ធសាស្ត្រសំរាប់ការលើកកំពស់អោយមានភាពស្មើគ្នានៃយ៉េនដ័រក្នុងគោលនយោបាយ និង កម្មវិធីប្រឆាំងនិងការជួញដូរកុមារ និង ពលកម្មកុមារ ។ ផ្នែកនេះផ្តល់នូវទិដ្ឋភាពរួមមួយក្នុងការបង្ហាញលើភាពខុសគ្នានៃយ៉េនដ័រដ៏សំខាន់ក្នុងពលកម្មកុមារនិង ការរៀបចំឧបករណ៏ដែលអាចដោះស្រាយវិសមភាពនៃយ៉េនដ័រក្នុងនយោបាយ និងកម្មវិធីប្រឆាំងនិងការងារពលកម្មលើកុមារនិងការជួញដូរកុមារ ។
- ផ្នែកទី២ មានឧបករណ៏អនុវត្តន៏ចំនួនប្រាំមួយមគ្គុទេសក៏ណែនាំពីរ និងតារាងត្រួតពិនិត្យបួន ៖

  - គោលការណ៏ណែនាំទីមួយ ផ្តល់នូវការសង្ខេបនិយមន័យដ៏សំខាន់ ឧបករកណ៏ជំនួយស្មារតី និង យុទ្ធសាស្ត្រដែលបានពន្យល់នៅផ្នែកទីមួយ ។គោលការណ៏ណែនាំនេះអាចត្រូវបានប្រើក្នុងការលើកកំពស់ការយល់ដឹងឬសកម្ម ភាពបណ្តុះបណ្តាលឬធ្វើជាមគ្គុទេសក៏យោងមួយដ៏លឿន ។
  - គោលការណ៏ទីពីរទាក់ទងជាមួយនិងប្រព័ន្ធការបញ្ចូលគ្នានៃបញ្ហាយ៉េនដ័រក្នុងគំរោងកម្មវិធីសកម្មភាពប្រឆាំងពលកម្មកុមារ ។ គោលការណ៏ណែនាំនេះបន្ថែមលើឯកសារកម្មវិធីសកម្មភាពក្នុងស្តង់ដានិតិវិធីប្រតិបត្តិការ របស់IPEC ។
  - តារាងត្រួត ពិនិត្យទីមួយអាចត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃលើកិរិតនៃកង្វល់ពីបញ្ហាយ៉េនដ័រដែលត្រូវបញ្ចូលក្នុងគំរោងកម្មវិធីសកម្មភាព ។
  - តារាងត្រួតពិនិត្យទីពីរផ្តល់នូវឧបករណ៏មួយដើម្បីពិនិត្យឡើងវិញលើគំរោងស្រាវជ្រាវក៏រិតណាដែលផ្តល់ការណែនាំដែលពាក់ពន្ធ័សំរាប់អនុវត្តការវិភាគអំពីយ៉េនដ័រ ។
  - តារាងត្រួតពិនិត្យទីបីអាចត្រូវបានប្រើប្រាស់ដើម្បីពិនិត្យឡើងវិញនូវការប្រើប្រាស់យុទ្ធសាស្ត្របញ្ជ្រាយ៉េនដ័រក្នុងគោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៏ ។
  - តារាងត្រួតពិនិត្យទីបួនផ្តល់នូវឧបករណ៏មួយដើម្បីវាយតម្លៃសមត្ថភាពរបស់អង្គការក្នុងការដោះស្រាយវិសមភាពនិងលើកកំពស់សមភាពយ៉េនដ័រក្នុងសកម្មភាពប្រឆាំងការជួញដូរនិងពលកម្មកុមារ ។

មគ្គុទេសក៏ណែនាំនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់អង្គការ ILO ស្តីពីការបញ្ជ្រាបយ៉េនដ័រសំរាប់ សមភាពយ៉េនដ័រដែលត្រូវបានយល់ព្រមទទួលយកនៅក្នុងឆ្នាំ២០០០ ។ វាជាផ្នែកនៃការខិតខំប្រឹងប្រែងកសាងសមត្ថភាពរបស់ ILOដើម្បីដោះស្រាយ ចំពោះវិសមភាពយ៉េនដ័រក្នុងសកម្មភាពប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារនិងបង្កើនការយល់ដឹងលើសិទ្ធិមនុស្សជាមូលដ្ឋាននិងបទដ្ឋានការងារ និង សិទ្ធិរបស់កុមារនិងស្ត្រីក្នុងចំណោមក្រុមមនុស្សដែលរងគ្រោះនូវការកេងប្រវ័ញ្ចខាងពលកម្មដ៏ធ្ងន់ធ្ងរ ។មគ្គុទេសក៏ណែនាំនេះត្រូវបានបង្កើតឡើងក្រោមគំរោងសាកល្បងមួយ "ការលើកកំពស់ឱ្យមានសមភាពយ៉េនដ័រក្នុងសកម្មភាពប្រឆាំងពលកម្មកុមារក្នុងអាស៊ីបូព៌ា(GECL)"ដែលអនុវត្តដោយការិយាល័យអនុតំបន ILOសំរាប់អាស៊ីបូព៌ា(SRO-Bangkok) ក្នុងកិច្ចប្រតិបត្តិការជាមួយ IPEC ។យុទ្ធសាស្ត្រដ៏សំខាន់របស់គំរោងរួមមាន ៖

- ការកសាងសមត្ថភាពដៃគូរក្នុងការបញ្ជ្រាប ការដោះស្រាយសិទ្ធិនិងភាពស្មើគ្នាក្នុងការរៀបចំគំរោងការ និង ឧបករណ៍ត្រួតពិនិត្យនិងវាយតំលៃ និង ដំណើរការ កម្មវិធី ។
- ការអភិវឌ្ឍន៍ឧបករណ៍ថ្មីដើម្បីការរៀបចំការផ្តល់សិទ្ធិអំណាចខាងសេដ្ឋកិច្ច និងសង្គមដល់កុមារ យុវជន និងក្រុមគ្រួសារ ។
- ការពង្រឹងការចែករំលែកចំនេះដឹង និងបណ្តាញការងាររវាង ពលកម្មកុមារ និង អ្នកឯកទេស យ៉េនដ័រនៅ អាស៊ីភាគខាងកើត ។

# ផ្នែកទី ១: គំនិត និង យុទ្ធសាស្ត្រជាមូលដ្ឋាន

## ១. គំនិតជាមូលដ្ឋាន :

### ១.១ តើយ៉េនឌ័រមានន័យយ៉ាងដូចម្តេច ?

កុមារភេទត្រូវបានកើតឡើងជាមួយឥទ្ធិពលដែលមានឱកាសរបស់ពួកគេ ស្របគ្នាជាមួយភាពខុសគ្នា សំខាន់ ដ៏ទៃទៀត ដូចជា ឋានៈ ឬ វណ្ណៈ សេដ្ឋកិច្ចសង្គម ពូជសាសន៍ ឬជនជាតិភាគតិច ។ ភាពខុសគ្នាពីកំណើត ក្នុងការចាប់កំណើតជាក្មេងប្រុស ឬក្មេងស្រីបានត្រឡប់ ជាមានភាពសំខាន់នៅពេលក្រោយ នៅពេលដែលក្មេង បានទៅដល់វ័យគ្រប់ការ ។ ទោះជាយ៉ាងណាក៏ដោយ ចាប់ពីខណៈដែលគេបានចាប់កំណើត សង្គមបានផ្តល់តួនាទី កំណត់លទ្ធផល និង ឱកាសផ្សេងគ្នាចំពោះក្មេងប្រុស និងក្មេងស្រី ។ ពួកគេបានសម្របខ្លួនដើម្បីប្រតិបត្តិតួនាទី ជាបុរស និងស្ត្រីនៅក្នុងសង្គមរបស់ពួកគេ ដោយយោងទៅលើគំនិតក្នុងសង្គមនោះដែលកំណត់ថា តើបុរស ឬស្ត្រីត្រូវមានឥរិយាបថបែបណា ។ អត្ថន័យសង្គមទាំងនេះ បានផ្តល់ទៅឱ្យជីវសាស្ត្រខុសគ្នានៃភេទពីកំណើត ដែលគ្របដណ្តប់ដោយពាក្យថា "យ៉េនឌ័រ" ។



- យ៉េនឌ័រ សំដៅទៅលើភាពខុសគ្នានៃសង្គម និងទំនាក់ទំនងរវាង ក្មេងស្រី និងក្មេងប្រុស ស្ត្រី និងបុរស ដែលបានដឹង និងធ្វើអោយមានភាពខុសប្លែកគ្នាយ៉ាងទូលំទូលាយរវាងប្រពៃណី និងការផ្លាស់ប្តូរតាមពេល វេលា។ ឧទាហរណ៍ : នៅប្រទេសជាច្រើន ស្ត្រីជាអ្នកថែរក្សាកូនចៅ ប៉ុន្តែបុរសជាអ្នកមើលថែរក្សា ក្មេងក៏កើនឡើងមានចំនួនច្រើនផងដែរ ។



- ភេទ សំដៅទៅលើភាពខុសគ្នាជាលក្ខណៈជីវសាស្ត្រ ពីកំណើតរវាងបុរស និងស្ត្រីជាលក្ខណៈទូទៅ ហើយដែល មិនអាចមានការផ្លាស់ប្តូរបានឡើយ ។ ឧទាហរណ៍ ស្ត្រីគឺជាអ្នកផ្តល់កំណើត ហើយមានតែបុរសទេដែល ដុះពុកចង្កា ( ពុកមាត់) ។

យ៉េនឌ័រ គឺជាភាពខុសគ្នានៃសេដ្ឋកិច្ចសង្គម ដើម្បីវិភាគរកភាពខុសគ្នារវាងក្មេងប្រុស និងក្មេងស្រី បុរស និងស្ត្រី ដោយយោងទៅលើ :

- តួនាទី ការទទួលខុសត្រូវ និងសេចក្តីត្រូវការ
- ឧបសគ្គ និងឱកាសផ្សេងៗ

គំនិត និងការអនុវត្តន៍នៃក្មេងប្រុស បុរស ក្មេងស្រី និងស្ត្រីអាចមានធ្វើខុសគ្នាពីប្រទេសមួយទៅប្រទេស មួយទៀត ។ ជួនកាលភាពខុសប្លែកគ្នាធំៗអាចកើតមានឡើងនៅក្នុងប្រទេសតែមួយ ។ ឧទាហរណ៍ : នៅក្នុងប្រទេសខ្លះ ស្ត្រីមិនធ្វើការទេក្នុងផ្នែកសាងសង់ ហើយបុរសមិនចេះត្បាញ ឬក៏ដេរប៉ាក់នោះទេ ខណៈ ដែលប្រទេសខ្លះទៀត វាជាការសមញ្ញទៅហើយ ដែលយើងឃើញពួកគេធ្វើការក្នុងផ្នែកនេះ ។

វាមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យមានភាពខុសគ្នារវាងតំលៃ យ៉េនឌ័រ, បទដ្ឋាន ផ្នត់ រូបារម្មណ៍ ( ផ្នត់គំនិត) និងតួ នាទី ។

- តំលៃនិងបទដ្ឋានរបស់ យ៉េនឌ័រ នៅក្នុងសង្គម គឺសំដៅទៅលើគំនិតដែលមនុស្សមានចំពោះអ្វី ដែលបុរស និងស្ត្រីនៅគ្រប់ជំនាន់ទាំងអស់គួរតែប្រព្រឹត្តខ្លួនដូចជាអ្វីមួយ ។ ឧទាហរណ៍ : នៅក្នុងសង្គមជាច្រើន ក្មេងស្រី គួរត្រូវបានឱ្យស្តាប់បង្គាប់ និង

- ផ្នត់រូបារម្មណ៍នៃយ៉េនឌ័រ គឺជាគំនិតដែលមនុស្សមានចំពោះក្មេងប្រុសនិងបុរស ក្មេងស្រីនិងស្ត្រីមានលទ្ធភាពក្នុង ការធ្វើអ្វីមួយ ។ ឧទាហរណ៍:គំនិតដែលថាស្ត្រីគឺជាទូទៅធ្វើការផ្ទះបានល្អជាងបុរស ហើយបុរសធ្វើការប្រសើរ ជាមួយ និង គ្រឿងម៉ាស៊ីន ឬក៏ថាក្មេងប្រុស ច្រើនពូកែក្នុងគណិតវិទ្យា ហើយក្មេងស្រីច្រើនពូកែក្នុងការងារផ្ទះ ។

- តួនាទីរបស់យេនឌ័រ សំដៅទៅលើសកម្មភាពដែលភេទទាំងពីរអនុវត្តជាក់ស្តែង ។ ឧទាហរណ៍ៈ ក្មេងប្រុស តែងជួយឪពុករបស់គេក្នុងការងារក្រៅផ្ទះ ហើយផ្ទុយទៅវិញ ក្មេងស្រីជួយម្តាយរបស់គេក្នុងការងារផ្ទះ សម្បែង ។

តួនាទីយេនឌ័រត្រូវបានពង្រឹងឡើងដោយតំលៃយេនឌ័រ បទដ្ឋាន និងផ្នត់ រូបារម្មណ៍ដែលបានកើតមានឡើងនៅ គ្រប់សង្គម ។ ទោះជាយ៉ាងណាក៏ដោយ តួនាទីយេនឌ័រ អាចនឹងពិតជាមានការផ្លាស់ប្តូរ ជាញឹកញាប់វាមាន លក្ខណៈរហ័សជាងគំរិតដែល មនុស្សមានចំពោះក្មេងស្រី និងក្មេងប្រុស បុរស និងស្ត្រី ដែលថា គួរឬមិនគួរមាន ឥរិយាបទបែបណាមួយនោះ ។ ឧទាហរណ៍ : ក្មេងស្រីនិងស្ត្រីនៅគ្រប់សង្គមទាំងអស់ ត្រូវបានគេសន្មត់ថាជាភេទ ទន់ខ្សោយ ហើយពួកគេគួរតែត្រូវបានគេការពារពីបន្ទុកការងារធ្ងន់ធ្ងរ ។ ទោះជាយ៉ាងណាក៏ដោយ ជាលក្ខណៈ ជាក់ស្តែង ក្មេងស្រី និង ស្ត្រីដែលមកពីក្រុមនៃប្រជាជនក្រខ្សត់







តែងបានធ្លាក់ទៅក្នុងការងារធ្ងន់ធ្ងរ ក្នុងរយះពេល ច្រើនម៉ោងដូចគ្នា នឹងក្មេងប្រុស និងបុរសដែរ ។ ជាមួយគ្នានេះផងដែរនៅក្នុងគ្រប់សង្គមទាំងអស់ ឪពុកម្តាយដែល មានធនធានស្តួចស្តើង មានការលំអៀងក្នុងការជំរុញការសិក្សានៃកូនប្រុសរបស់ពួកគេជាងកូនស្រី ពីព្រោះកូនប្រុសត្រូវបានគេសង្ឃឹមថាជាអ្នកផ្តល់ការផ្គត់ផ្គង់សំរាប់ គ្រួសារនៅពេលអនាគត ។ បច្ចុប្បន្ននេះតំលៃសេដ្ឋកិច្ច របស់កូនស្រីបានកើនឡើងនៅក្នុងសង្គមពីព្រោះថាក្មេងស្រីអាចនាំចំណូលឡើងទាត់ចូលគ្រួសារពីការងារជាកម្មករ រោងចក្រឬក៏ស្ត្រីជាអ្នកធ្វើការងារក្នុងសេវាកម្មកំសាន្តសប្បាយ ។ បញ្ហានេះបានបង្ហាញថាឥរិយាបទស្តីពីតួនាទី យេនឌ័ររបស់ក្មេងស្រីមានការផ្លាស់ប្តូរទោះបីថាការផ្លាស់ប្តូរនេះវា មិនចាំបាច់ធ្វើអោយជីវិតបានល្អប្រសើរសំរាប់ក្មេងស្រីក៏ដោយ ។

## ១.២ តើពាក្យថាសមភាពនៃយេនឌ័រមានន័យដូចម្តេច ?





នៅក្នុងសង្គមភាគច្រើន វាមានភាពខុសគ្នានិងមានភាពមិនស្មើរវាង ក្មេងស្រីនិងក្មេងប្រុស ស្ត្រីនិងបុរស នៅក្នុងឱកាសការទទួលខុសត្រូវ សិទ្ធិ និងផលប្រយោជន៏ដែលត្រូវបានផ្តល់ឱ្យពួកគេ និងសំរាប់សកម្មភាពដែល ពួកគេបានធ្វើកន្លងមក ។ ខណៈដែលមានភាពខុសគ្នាជុំវិញវប្បធម៌ វាមានលក្ខណៈពិសេសរួមមួយ ។ យេនឌ័រនៅជុំវិញពិភពលោកត្រូវបានចាត់ទុកដោយវិសមភាព និង មិនតុល្យភាពគ្នាក្នុងទំនាក់ទំនងរវាងភេទទាំងអស់ ។ ឧទាហរណ៏ភាពផ្សេងគ្នានេះបានកើតឡើងរវាងក្មេងស្រី និងក្មេងប្រុស ក្នុងការទទួលបានការអប់រំ និងការហ្វឹកហ្វឺន រវាង បន្ទុកការងារស្ត្រីនិង បុរស ការទទួលបានសិទ្ធិប្រើប្រាស់ និង គ្រប់គ្រងរក្សាទុកធនធាន និង ផលប្រយោជន៏ផ្សេងៗក្នុងតួនាទីរបស់ បុរសនិង ស្ត្រីក្នុងការធ្វើសេចក្តីសំរេចចិត្ត ។





- **សមភាពយេនឌ័រ** ឬសមភាពរវាងបុរស និង ស្ត្រីសំដៅសិទ្ធិស្មើគ្នា ការទទួលខុសត្រូវ ឱកាសថែរក្សា និង ការឱ្យតំលៃដូចគ្នារវាងបុរស និង ស្ត្រីដូចជា :
  - នៅក្នុងការងារ
  - នៅក្នុងទំនាក់ទំនងការងារ និង ការរស់នៅ

សមភាពនៃយេនឌ័រមានន័យថាមនុស្សនៅគ្រប់កំរិតអាយុ ហើយនិងភេទទាំងពីរគួតែមានឱកាសស្មើគ្នា ដើម្បីធ្វើអោយមានជោគជ័យក្នុងការរស់នៅ ។ វាមានន័យថា គ្រប់មនុស្សជាតិទាំងអស់គួតែមានភាពស្មើគ្នា ពាក្យម្យ៉ាងទៀត ដែលយើងអាចហៅ គឺភាពមិនលំអៀង និងយុត្តិធម៏ ក្នុងការទទួលបាននិងការគ្រប់គ្រងធនធាន និងផលប្រយោជន៏ផ្សេងៗដើម្បីឱ្យគ្រប់គ្នាអាចទទួលបានផលប្រយោជន៏ពីការចូលរួមក្នុងការងារអភិវឌ្ឍន៏ ។

- **ការជំរុញអោយមានសមភាពយេនឌ័រ:** បាននាំទៅរកការធានាបាននូវការចែករំលែក និងទទួលបានលទ្ធផលស្មើគ្នារវាងបុរស និងស្ត្រី ដើម្បីឱ្យមនុស្សយើងទាំងអស់ត្រូវបានគេផ្តល់នូវសេចក្តីថ្លៃថ្នូរនិងត្រូវបានគេអនុញ្ញាតិអោយធ្វើការអភិវឌ្ឍន៍ នូវសក្តានុពលទាំងអស់ដែលនាំឱ្យមានគុណភាពនៃការរស់នៅប្រសើរជាងមុនសំរាប់ជនគ្រប់រូប ។ វាមិនមានន័យថា បុរស និងស្ត្រីចាំបាច់ត្រូវតែដូចគ្នា សុទ្ធសាធនោះទេ ប៉ុន្តែវាមានន័យថា ពួកគេមានសិទ្ធិការទទួលខុសត្រូវនិងឱកាសដូចគ្នានៅក្នុងមធ្យោបាយមួយដែលការងារ និង ខ្លួនរបស់ពួកគេត្រូវបានគេអោយតំលៃ ដោយមិនគិតដល់ពួកគេកើតមកជាស្រី ឬប្រុសនោះទេ ។ ថ្វីត្បិតតែបុរសនិងស្ត្រី អាចនឹងមានភាពផ្សេងគ្នាមែនប៉ុន្តែពួកគេគួរអោយមានសិទ្ធិការទទួលខុសត្រូវនិងឱកាសដូចគ្នា ។ ដូច្នេះហើយ សមាសភាពយេនឌ័រគឺមានរួមទាំងសិទ្ធិមនុស្សសិទ្ធិការងារនិងមានតំលៃដូចគ្នា ហើយជាការចែករំលែកនៃ :
    - ការទទួលខុសត្រូវ និង ឱកាស
    - បន្ទុកការងារ និង ការធ្វើសេចក្តីសំរេចចិត្ត

## ១.៣ តើពាក្យថាការរើសអើងយេនឌ័រមានន័យយ៉ាងដូចម្តេច ?

**ការរើសអើង** គឺមានការបែងចែកជាច្រើន ការមិនរាប់បញ្ចូល រឺ ការស្រលាញ់ចូលចិត្តដែលស្ថិតនៅលើភេទ យេនឌ័រ (ឬក៏ការចាត់ថ្នាក់ផ្សេងៗទៀតនៅក្នុងសង្គម ដូចជា ជាតិសាសន៍ ពណ៌សំបុរ សាសនា និង គំនិតនយោបាយ) ដែលវាធ្វើអោយទទួលរងនូវការខាតផលប្រយោជន៍ ឬ ក៏សមភាពថយចុះទាំងឱកាស និង ការទទួលស្គាល់អោយតំលៃ ។

ការរើសអើងមានពីរបែប :

- **ការរើសអើងដោយផ្ទាល់** : ជាទូទៅគឺស្តែងឡើងដោយបំណង ឬ ចែងឡើងយ៉ាងជាក់លាក់ ។ជួនកាលការរើសអើងដោយផ្ទាល់អាចត្រូវបានគេរកឃើញមានចែងឡើងនៅក្នុងច្បាប់ ។នេះគេហៅថា ការរើស អើង "de jure" ។ ឧទាហរណ៍ នៅក្នុងប្រទេសជាច្រើន :
    - ស្ត្រីមិនអាចគ្រប់គ្រងលើទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចជាដីធ្លី ឬផ្ទះសំបែង
    - ស្រីដែលរៀបការហើយ មិនបានចុះហត្ថលេខា លើឯកសារស្របច្បាប់ណាមួយទេ
    - អាយុចូលនិវត្តន៍របស់បុរស និងស្ត្រីមានការខុសប្លែកពីគ្នា
    - ស្ត្រីត្រូវបានគេហាមឃាត់ដោយច្បាប់ចំពោះការងារមួយចំនួន







ការរើសអើងដោយផ្ទាល់រវាងបុរសនិងស្ត្រី កំពុងត្រូវបានថយចុះនៅក្នុងប្រទេសជាច្រើន ដោយ ហាមឃាត់មិនអោយមានការរើសអើងលើមូលដ្ឋានភេទឬ យេនឌ័រនោះទេ ហើយនិងបានជំរុញនូវសមភាព រវាងបុរស និងស្ត្រី នៅក្នុងច្បាប់ទៀតផង ។ ទោះបីជាយ៉ាងណាក៏ដោយ ទំរង់នៃការរើសអើងដោយ ផ្ទាល់ក្នុងន័យម្យ៉ាងទៀតថា "de facto" ការរើសអើងនៅតែបន្តរីកសាយភាយនៅក្នុងការអនុវត្តន៍ជាក់ស្តែង។ ឧទាហរណ៍ការផ្សាយដំណឹងជ្រើសរើសបុគ្គលិកអោយបំរើការងារនៅក្នុងប្រទេសជាច្រើនមានន័យ ដូចជា :

- **ការរើសអើងដោយប្រយោល:** សំដៅទៅស្ថានភាពស្តែងចេញភាពមិនលំអៀង បទបញ្ញត្តិ ឬក៏ការ ប្រតិបត្តិដែលជាក់ស្តែងផ្តល់លទ្ធផលក្នុងការអោយតំលៃមនុស្សទាំងឡាយមិនស្មើគ្នា ។ នេះជាការបដិសេធ ចោល ព្រោះតែសេចក្តីស្រលាញ់ពេញចិត្ត ឬ ផ្តត់រូបារម្មណ៍ ។ ម៉្យាងវិញទៀត ជាក់ ស្តែងចេញនូវច្បាប់មានភាពអព្យាក្រិត្យឬក៏ការប្រតិបត្តិដែលមិនមានផលប៉ះពាល់អវិជ្ជមានទៅភាពមិនមានសមាមាត្រ លើក្រុមណាមួយ ។ ឧទាហរណ៍
    - សហគ្រាសមួយចំនួនតែងតែចូលចិត្តជ្រើសរើសកម្មករជាបុរស ជាងកម្មករស្ត្រី ដែលមានវ័យពរពោះ ពីព្រោះតែពួកគេគិតថាស្ត្រីអាចនឹងអវត្តមាននឹងការងារច្រើន ដោយហេតុតែមានផ្ទៃពោះ និងការទទួល ខុសត្រូវក្នុងគ្រួសារ ។
    - តួនាទីអ្នកចាត់ការជានិច្ចជាកាលត្រូវបានបំពេញដោយបុរស ព្រោះស្ត្រីមិនត្រូវបានគេចាត់ទុកជាមេដឹកនាំ ដ៏ល្អ ពីធម្មជាតិដូចបុរសនោះទេ ។

នៅពេលការរើសអើងដោយ "de jure" ផ្ទាល់រវាងបុរស និងស្ត្រី បាននិងកំពុងកាត់បន្ថយ ព្រោះសព្វ ថ្ងៃនេះបណ្តាប្រទេសភាគច្រើនបានហាមឃាត់មិនអោយមានការរើសអើង ដោយផ្អែកលើមូលដ្ឋានភេទ និង យេនឌ័រនៅក្នុងច្បាប់ ការរើសអើងដោយផ្ទាល់ និងដោយប្រយោលនៅតែបន្តជាធម្មតា ក្នុងការប្រតិបត្តិ នៅក្នុងសង្គមជាច្រើន និងនៅទីកន្លែងធ្វើការងារជាច្រើន ហើយជាទូទៅផ្តល់អោយស្ត្រី និងកុមារនូវនាទីប្រកប ដោយគុណវិបត្តិជានិច្ចនៅក្នុងសង្គម ។ ការរើសអើងបែបនេះតែងតែកើតឡើងមិនមែនព្រោះតែប្រជាជន នៅក្នុងសង្គមបង្កើតឡើងប្រកបដោយបំណងទេ ប៉ុន្តែវាកើតឡើងព្រោះតែប្រពៃណី និងទំនៀមទំលាប់អោយ តំលៃច្រើនទៅបុរស និង ក្មេងប្រុសៗ ហើយចាត់ទុកស្ត្រី និងក្មេងស្រីៗមានតួនាទីបន្ទាប់ពីខ្លួន ។

ការរើសអើងដោយផ្ទាល់ និងដោយប្រយោលមិនត្រូវបានគេយល់ច្រឡំជាមួយនិងគំនិតនៃសកម្មភាពវិជ្ជមាន ឬក៏ការរើសអើងវិជ្ជមានដែលវាគឺជាឧបករណ៏ដ៏មានសារៈសំខាន់សំរាប់ប្រយុទ្ធបំបាត់ផលប៉ះពាល់អវិជ្ជមាននៃការ រើសអើងដែលកើតមានឡើងក្នុងអតីតកាលជាហូរហែរមកនោះទេ ។ ពតិមានបន្ថែមសូមមើលចំនុចទី ៣ នៅក្នុងផ្នែកទី ១ ។

## ១.៤ តើសិទ្ធិមនុស្សមានន័យយ៉ាងដូចម្តេច ?

■ **សិទ្ធិមនុស្ស** : គឺជាសិទ្ធិមូលដ្ឋានពេញលេញដែលមនុស្សម្នាក់ៗមានព្រោះអ្នកទាំងអស់នោះ គឺជាមនុស្ស ជាតិ ។ ពួកគេទទួលស្គាល់នូវភាពងាយរងគ្រោះ ក្នុងឋានៈជាមនុស្សជាតិស៊ីវិល នយោបាយ សេដ្ឋកិច្ចសង្គម និងការវិវត្តន៏នៃវប្បធម៌ និងផ្តល់នូវការការពារ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មនុស្សម្នាក់ៗមានសិទ្ធិទាំង នេះជាវិសាលភាពបើទោះជាពួកគេត្រូវបានជំរុញការប្រតិបត្តិខុសគ្នាពីប្រទេសមួយទៅប្រទេសមួយក៏ដោយ ។

**មានសិទ្ធិទើបមានកាតព្វកិច្ច និងការទទួលខុសត្រូវមកជាមួយ ។ នៅក្នុងការការពារសេរីភាព សិទ្ធិ និង យុត្តិធម៌សំរាប់មនុស្សទាំងអស់គ្នា មនុស្សម្នាក់ៗមានការទទួលខុសត្រូវក្នុងការគោរពច្បាប់ ហើយ ម្នាក់ៗមានកាតព្វកិច្ចនៅក្នុងសហគមន៍ទៀតផង ។ នៅក្នុងការប្រើប្រាស់សេរីភាព និងសិទ្ធិវិញ គឺម្នាក់ៗ ជានិច្ចកាលត្រូវតែគោរពដល់សិទ្ធិ និងសេរីភាពអ្នកដទៃផងដែរ ។**

**នៅឯកវិតអន្តរជាតិភាគច្រើននៃសិទ្ធិមនុស្សសំខាន់ៗទាំងនេះត្រូវបានគេពិពណ៌នានៅក្នុងសេចក្តីថ្លែងការណ៏ជា សកលស្តីអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៤៨[1] ។ សិទ្ធិមនុស្សសំខាន់រួមមាន :**

សិទ្ធិក្នុងការទទួលបានការគោរព និង គ្មានការរើសអើង

សិទ្ធិក្នុងការមានសញ្ជាតិ

សិទ្ធិក្នុងការមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន

សិទ្ធិក្នុងការអប់រំ

សិទ្ធិក្នុងការធ្វើការងារសមរម្យមានយុត្តិធម៌ និងមានលក្ខខណ្ឌការងារសមស្រប

សិទ្ធិក្នុងការមានសេរីភាពពីទាសភាព និង ពលកម្មដោយបង្ខំ

សិទ្ធិទទួលបានការប្រើប្រាស់សេវាសាធារណៈស្មើគ្នានៅក្នុងប្រទេស

សិទ្ធិក្នុងការមានសេរីភាពផ្លាស់ទីលំនៅ

សិទ្ធិក្នុងការមានសេរីភាពក្នុងការគិត ការបញ្ចេញមតិ និង ការនិយាយស្តី

សិទ្ធិសេរីភាពក្នុងការរៀបចំសមាគម

[1] បរិធានផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិមាន : អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិខាងផ្នែកនយោបាយ និង ស៊ីវិល (ICCPR ចុះឆ្នាំ ១៩៦៦) ហើយនិងស្តីពីសិទ្ធិខាងផ្នែកវប្បធម៌ សេដ្ឋកិច្ច និង សង្គម (ICSECR)

## ១.៥ តើសិទ្ធិជាមូលដ្ឋាននៅក្នុងការធ្វើការងារមានន័យដូចម្តេច ?

នៅក្នុងឆ្នាំ១៩៩៨ បណ្តារដ្ឋជាសមាជិកនៃអង្គការពលកម្មអន្តរជាតិ បានអនុម័តនូវសេចក្តីប្រកាសស្តីពី គោលការណ៍ និងសិទ្ធិសំខាន់ៗនៅក្នុងការធ្វើការងារដែលបានដាក់ចេញនូវគោលការណ៍ពលកម្មជាមូលដ្ឋានដែលជាគ្រឹះនៃសិទ្ធិមនុស្សជាតិនៅក្នុងការងារ ដោយគេមិនបានគិតដល់កំរិតនៃការអភិវឌ្ឍន៍នៅក្នុងប្រទេសនិមួយៗឡើយ ។ គោលការណ៍ពលកម្មស្នូលបានយល់ព្រមដោយ សហគមន៍អន្តរជាតិ នោះគ្របដណ្តប់លើចំនុចសំខាន់៤[2] :

- ការលុបបំបាត់ចោលនូវទំរង់ធ្ងន់ធ្ងរនៃពលកម្មដោយបង្ខំ និង បង្ខាប់បញ្ហាទាំងអស់
- ការលុបបំបាត់នូវពលកម្មកុមារ
- ការលុបបំបាត់ចោលនូវការរើសអើងក្នុងការបំរើការងារនិង ក្នុងមុខរបរ
- សេរីភាពក្នុងការចូលរួម និង សេរីភាពក្នុងការទទួលស្គាល់សិទ្ធិក្នុងការពិភាក្សាដោះស្រាយ (ចរចា)

## ១.៦ តើសិទ្ធិជាមូលដ្ឋានសំរាប់កម្មករជាស្ត្រីមានន័យដូចម្តេចខ្លះ ?

អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីអំពីការលុបបំបាត់នូវរាល់ទំរង់នៃការរើសអើងប្រឆាំងនឹង ស្ត្រីភេទ (CEDAW) ជាគន្លឹះមួយដែលជាបរិធាន (ឯកសារ) របស់អង្គការសហប្រជាជាតិសំរាប់ជំរុញអោយ មានសមភាពយេនឌ័រ ។ វាត្រូវបានអនុម័តនៅឆ្នាំ ១៩៧៩ ដោយមានគោលបំណងប្រយុទ្ធប្រឆាំង និងការរើស អើងដែលនៅតែមានជាបន្តចំពោះស្ត្រី ព្រោះបរិធានសិទ្ធិមនុស្សកាលដើមឡើយភាគច្រើនបានឆ្លុះបញ្ចាំងកង្វល់និង ទស្សនៈវិស័យច្រើនបំផុតចំពោះបុរស ។ វាចង្អុលបង្ហាញថាចំណុចជាច្រើនដែលមានឥរិយាបទរើស អើងចំពោះស្ត្រីភេទ ។ ឧទាហរណ៍ទាក់ទងក្នុងសិទ្ធិខាងនយោបាយក្នុងអាពាហ៍ពិពាហ៍ គ្រួសារ និងនៅក្នុងការងារ ។ អនុសញ្ញានេះបានដាក់ចេញនូវគោលបំណងនិងវិធានការណ៍ជាក់លាក់ដែលត្រូវអនុវត្តដើម្បីសំរួលក្នុងការបង្កើតសង្គមទូទាំងសកលលោកដែលស្ត្រីទទួលបាននូវសមភាពពេញលេញនិងបុរសដែរ ។ ហេតុដូចនេះហើយធ្វើអោយពួកគេមានការយល់ដឹង យ៉ាងពេញលេញអំពីចំពោះសិទ្ធិមនុស្សរបស់គេដែលមានការធានា ។

បន្ថែមលើសិទ្ធសំខាន់ៗក្នុងការធ្វើការងារដែលបានពិពណ៌នាខាងលើមានបទដ្ឋាន [3] ( ស្តង់ដា ) ពល កម្មអន្តរជាតិពីរផ្សេងទៀតដែលផ្តល់សារៈសំខាន់ក្នុងការឆ្លើយតបនិងការរើសអើងដែលរីកសាយភាយ ហើយវាជាឧបសគ្គយ៉ាងធំសំរាប់កម្មករស្ត្រី :

- ការគាំពារមាតុភាពដែលវាបានការពារដល់មុខងារជីវសាស្ត្ររបស់ស្ត្រីមុនពេល កំឡុងពេល និងក្រោយពេល សំរាលកូន ។
- ការផ្តល់នូវឱកាសស្មើភាពគ្នាដល់បុគ្គលិកដោយមានការទទួលខុសត្រូវក្នុងក្រុមគ្រួសារដែលជាភារកិច្ចទាក់ទងការបន្តពូជក្នុងបរិយាកាសសង្គម ដែលស្មើរតែបានប្រគល់ទៅអោយជាពិសេសដល់ក្មេងស្រី និង ស្ត្រីទាំង ឡាយក្នុងសង្គមជាច្រើន ។

[2] អនុសញ្ញាឆ្លើយតបសំខាន់ ៨ និង អនុសាសន៍ ៤ ដែល គឺ :
- អនុសញ្ញាលេខ ២៩ (ចុះឆ្នាំ ១៩៣០) ស្តីពីពលកម្មដោយបង្ខំ
- អនុសញ្ញាលេខ ១០៥ (ចុះឆ្នាំ ១៩៥៧) ស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំ
- អនុសញ្ញាលេខ ១៣៨ និង អនុសាសន៍លេខ១៤៦ (ចុះឆ្នាំ ១៩៧៣) ស្តីពីអាយុអប្បរិមា (ការងារ)
- អនុសញ្ញាលេខ១៨២ និង អនុសាសន៍លេខ១៩០ (ចុះឆ្នាំ ១៩៩៩) ស្តីពីទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- អនុសញ្ញាលេខ ១០០ និង អនុសាសន៍លេខ ៩០ (ចុះឆ្នាំ ១៩៥១) ស្តីពីការសងស្មើគ្នា?
- អនុសញ្ញាលេខ ១១១ និង អនុសាសន៍លេខ ១១១ (ចុះឆ្នាំ ១៩៥៨) ស្តីពីការរើសអើង (ការជ្រើសរើសបុគ្គលិក បំរើ ការងារ និង មុខរបរ)
- អនុសញ្ញាលេខ ៨៧ (ចុះឆ្នាំ១៩៤៨) ស្តីពីសេរីភាពក្នុងការរៀបចំសហគមន៍ និងក្នុងការការពារសិទ្ធិ ដើម្បីរៀបចំ
- អនុសញ្ញាលេខ ៩៨ (ចុះឆ្នាំ ១៩៤៩) ស្តីពីសិទ្ធិក្នុងការរៀបចំ និង ពិភាក្សាដោះស្រាយ?

[3] អនុសញ្ញា ឆ្លើយតប ២ និង អនុសាសន៍ គឺ
- អនុសញ្ញាលេខ ១៥៦ និង អនុសាសន៍លេខ១៦៥ (ចុះឆ្នាំ ១៩៨១) ស្តីពីកម្មករ និងការទទួលខុសត្រូវលើគ្រួសារ
- អនុសញ្ញាលេខ ១៨៣ និង អនុសាសន៍លេខ ១៩១ (ចុះឆ្នាំ ២០០០) ស្តីពីការគាំពារពេលមាតុភាព ។

## ១.៧ តើសិទ្ធិកុមារមានន័យយ៉ាងដូចម្តេច ?

សិទ្ធិមនុស្សគេអនុវត្តន៍ចំពោះក្មេងស្រី និង ក្មេងប្រុសទាំងអស់។ ក្នុងពេលដែលសង្គមមានទស្សនៈខុសប្លែក គ្នាស្តីពីកុមារភាព និងការវិវត្តន៍របស់កុមារ រឿងមួយដែលគេគ្រប់គ្នាយល់ស្រប គឺជាសារៈសំខាន់នៃសុខមាល ភាពរបស់កុមារ ។ បញ្ហានេះ ត្រូវបាន គេទទួលស្គាល់យ៉ាងច្បាស់នៅគ្រប់ទីកន្លែងដែលក្មេងៗទាំងអស់ត្រូវការការថែ ទាំនិងការការពារជាពិសេស សំរាប់ការវិវត្តន៍ ផ្នែក សុខភាព ដោយសារសេចក្តីត្រូវការជាពិសេស និង ភាពងាយរង គ្រោះរបស់ពួកគេ ។ ឧបករណ៍ពិសេសត្រូវបានធ្វើឡើងដើម្បីការពារ ជំរុញការអនុវត្តសិទ្ធិកុមារ ។ ស្តង់ដាដែលបានទទួលស្គាល់ពីអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ CRC ដែលគេ បានតាក់តែង ឡើងនៅឆ្នាំ១៩៨៩ ហើយត្រូវបានផ្តល់សច្ចាបណ៍ស្ទើរតែគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក វាគ្របដណ្តប់ គ្រប់ មនុស្សទាំងអស់ដែលមានអាយុក្រោម ១៨ ឆ្នាំ ។

សិទ្ធិកុមារត្រូវបានកំនត់ដោយអនុសញ្ញា CRC រួមមាននគោលការណ៍ដែលជាចំនុចសំខាន់៤ ដូចខាងក្រោម[៤]

- ភាពស្មើគ្នា(ឬសមភាព) : ដូចមនុស្សពេញវ័យដែរ កុមារអាចងាយនឹងទទួលរងការរើសអើង ដែលជាឥទ្ធិពល អវិជ្ជមានមួយ លើឱកាស និងស្ថានភាពរស់នៅរបស់កុមារ ។ ដូច្នេះហើយគ្រប់ក្មេងទាំងអស់ត្រូវតែមានសិទ្ធិ ស្មើគ្នា ហើយរដ្ឋាភិបាលមាន កាតព្វកិច្ច មួយត្រូវគាំទ្របញ្ហានេះ ។ ឧទាហរណ៍ដូចជា :
  - សិទ្ធិក្នុងការចុះបញ្ជីកំណើត
  - សិទ្ធិក្នុងការដាក់ឈ្មោះ និង សញ្ជាតិ
  - សិទ្ធិក្នុងការការពារពីគ្រប់ទំរង់រំលោភទាំងឡាយ ការព្រងើយកន្តើយ ការរើសអើង និងការកេងប្រវ័ញ្ច ។



សិទ្ធិរស់រានមានជីវិត និង ការវិវត្តន៍ផ្នែកសុខភាព ក្មេងគ្រប់រូបទាំងអស់មានសិទ្ធិ ដើម្បីអភិវឌ្ឍន៍ សក្តានុពលដ៏ពេញលេញ បំផុតរបស់ខ្លួនហើយពួកគេមានសិទ្ធដូចខាងក្រោម :

- សិទ្ធិទទួលបានសេចក្តីត្រូវការជាមូលដ្ឋានសំរាប់រស់នៅដូចជា: អាហារ ទីជំរក សំលៀកបំពាក់ និង មានសិទ្ធិ បានទទួលសេវាថែទាំសុខភាព ។



- សិទ្ធិក្នុងការរៀនសូត្រដោយសេរីនៅសាលាបឋមសិក្សា



- សិទ្ធិជាកុមារភាព សិទ្ធិក្នុងការសំរាក និង លេងកំសាន្ត និងមានមិត្តភក្រ័



- សិទ្ធិក្នុងការការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬការងារណាមួយដែលរំខានដល់ការរៀនសូត្រ ឬដែល ប្រកបដោយគ្រោះថ្នាក់ និងប៉ះពាល់ដល់សុខភាពរាងកាយ សតិអារម្មណ៍ និងការវិវត្តន៍ក្នុងសង្គម

- សិទ្ធិក្នុងការទទួលជំនួយសំរាប់កុមារដែលមានសេចក្តីត្រូវការ ពិសេសដូចជា: ជនភៀសខ្លួនជាកុមារ ក្មេងៗគ្មានទីជំរក ក្មេងៗ ដែលជាជនរងគ្រោះពីការរំលោភ និងក្មេងពិការ ។





[៤] សំរាប់គោលការណ៍នៃនាំជាច្រើនស្តីអំពី វិធីសំរាប់អនុវត្តន៍សិទ្ធិជាមូលដ្ឋានអោយខិតទៅជិតការបង្កើតកម្មវិធី ឃើញនៅក្នុងក្បួន នៃការជួយសង្គ្រោះអន្តរជាតិលើសម្ព័នភាពកុមារ ការបង្កើតកម្មវិធីសិទ្ធិកុមារ ២០០២

■ **ការចូលរួម**:ក្មេងប្រុសនិងក្មេងស្រីដោយយោងទៅតាមអាយុនិងភាពចាស់ទុំផ្សេងពីគ្នាគឺមានសិទ្ធិចូលរួមក្នុង ការសំរេចអ្វីៗមួយដែលអាចជះឥទ្ធិពលដល់ពួកគេ ។ ក្មេងប្រុស និងក្មេងស្រីទាំងអស់ត្រូវបានលើកទឹកចិត្តក្នុង ការចូលរួមធ្វើការសំរេចចិត្ត នៅផ្ទះ នៅសាលារៀន និងនៅសហគមន៍ផ្ទាល់ខ្លួនរបស់ពួកគេ ។

សិទ្ធិក្នុងការ ចូលរួមដ៏សំខាន់នោះមាន :





- សិទ្ធិមានសេរីភាពខាងការនិយាយស្តី និង បញ្ចេញមតិ
- សិទ្ធិក្នុងការទទួល និង ផ្តល់ពត៌មានក្នុងទំរង់ដែលអាចប្រើប្រាស់ និងយល់បាន
- សិទ្ធិក្នុងការធ្វើជាសមាជិកសកម្មរបស់សហគមន៍ការមានអំណរក្នុងវិស័យវប្បធម៌របស់ខ្លួនជំនឿខាងសាសនា និងការប្រើប្រាស់ភាសារបស់ខ្លួន។
- សិទ្ធិក្នុងការធ្វើជាសមាជិកម្នាក់ក្នុងក្រុមណាមួយ



■ **ចំណុចចាប់អារម្មណ៍បំផុតរបស់កុមារ** មានការយល់ដឹងពីររបស់កុមារ គឺមួយជាមនុស្សដែលមាន សមត្ថភាព និងម្យ៉ាងទៀតជាក្មេង ដែលងាយរងការរងគ្រោះផ្សេងៗ ហើយត្រូវការការពារ ។ ចំណុចទាំងពីរនេះអាចបង្កជាទំនាស់នៅពេលធ្វើសេចក្តីសំរេចចិត្តពីអ្វីមួយដែលជាផលប្រយោជន៍ដ៏ល្អបំផុតសំរាប់កុមារគោលការណ៍ នេះផ្តល់នូវដំណោះស្រាយមួយ ចំពោះបញ្ហានេះ ។ រាល់ការសំរេចចិត្តទាំងអស់ដែលជះឥទ្ធិពលដល់កុមារា និងកុមារី ត្រូវផ្តល់ការពិចារណាជាចំបងដល់ពួកគេ ។ ក្នុងការកំនត់អ្វីដែលល្អបំផុតសំរាប់ពួកគេជាសំខាន់វាត្រូវស្វែងយល់ដឹង ពីទស្សនៈរបស់ក្មេងប្រុស និងក្មេងស្រី ដែលបានទទួលរងការប៉ះពាល់ ។



## ១.៩ តើពលកម្មកុមារមានន័យដូចម្តេច ?

គ្រប់ការងារមិនមែនសុទ្ធតែមិនល្អដល់កុមារនោះទេ វាអាចផ្តល់សុខភាពដល់ពួកគេ ប៉ុន្តែវាក៏អាចជាការ បំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ការវិវត្តរីកធំធាត់របស់កុមារដែរ ។ ដើម្បីសំរេចថាតើសកម្មភាពសេដ្ឋកិច្ចណាដែលផ្តល់ សុខភាព ឬ បំផ្លាញកុមារ សហគមន៍អន្តរជាតិបានកំណត់នូវកត្តាជាច្រើនដូចតទៅ :

**ការងារកុមារ**
- ជាការងារស្រាលៗ( តិចជាង១៤ម៉ោងក្នុងមួយអាទិត្យ) សំរាប់ក្មេងដែលមានអាយុចាប់ពី១២ឆ្នាំដល់១៧ឆ្នាំ
- មិនបង្ករអោយមានគ្រោះថ្នាក់ដល់សុខភាព និងការរីកលូតលាស់របស់កុមារ
- មិនរាំងស្ទះដល់ការរៀនសូត្រ ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- មិនបង្ករអោយមានគ្រោះថ្នាក់តាមធម្មជាតិ





**ពលកម្មកុមារ**
- ការងារទ្បើងទាត់ ( ពី១៤ ដល់ ៤៣ ម៉ោងក្នុងមួយអាទិត្យ )
- បណ្តាលអោយគ្រោះថ្នាក់ដល់ផ្លូវកាយនិង ផ្លូវចិត្ត
- ធ្វើអោយរាំងស្ទះដល់ការរៀនសូត្រ និងការវិវត្តខាងផ្លូវកាយ និងខាងផ្លូវចិត្ត
- ក្មេងក្រោមអាយុអប្បបរិមាដែលកំណត់ដោយអនុសញ្ញារបស់អង្គការ ILO លេខ ១៣៨
- ការងារដែលប្រកបដោយគ្រោះថ្នាក់ត្រូវបានកំណត់ដោយការផ្តល់ដោយអនុសញ្ញារបស់អង្គការ ILO ១៨២

### ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ



- គ្រប់ទំរង់ជាលក្ខណៈទាសភាព ឬការអនុវត្តប្រហាក់ប្រហែលទៅនឹងទាសភាព ដូចជាការលក់និងការ ជួញដូរកុមារ ទាសភាពខាងបំណុល និងការងារពលកម្ម ដោយបង្ខំ រួមមានការកែណ្ឌក្មេងដោយបង្ខំអោយ ធ្វើទាហានដើម្បីប្រើក្នុងជម្លោះ ដោយអាវុធ ។
- ការប្រើក្មេងសំរាប់អំពើពេស្យាចារ ការផលិត ឬការសំដែងពីរូបភាពអាសអាភាស ។
- ការប្រើក្មេងសំរាប់សកម្មភាពខុសច្បាប់ផ្សេងៗ ជាពិសេសសំរាប់ការផលិត និងជួញដូរថ្នាំញៀន ។
- ការងារដែលជាលក្ខណ្ឌធម្មជាតិ ឬ ក្នុងកាលៈទេសៈត្រូវអនុវត្តដែលមើលទៅហាក់ដូចជាប៉ះពាល់សុខភាព សុវត្ថិភាព សុជីវធម៌របស់ក្មេង ។

## ១.៩ តើការជួញដូរមានន័យយ៉ាងដូចម្តេច ?

កង្វះឱកាសធ្វើសេដ្ឋកិច្ចនៅផ្ទះ ជម្លោះដោយអាវុធ ឬគ្រោះធម្មជាតិ អាចនាំអោយពួកគេចាកចេញពីផ្ទះ ដោយបង្ខំ ។ ជារឿយៗ ពួកគេច្រើនចេញពីជនបទចុងកាត់មាត់ញក មកកាន់ទីក្រុងហើយជួនកាលត្រូវឆ្លងកាត់ ព្រំដែន។ ខណៈពេលការធ្វើ(បំលាស់លំនៅ) អាចជាបទពិសោធន៏វិជ្ជមានមួយ ដែលផ្តល់នូវឱកាសកាន់តែប្រសើរ ឡើងសំរាប់មនុស្សជាច្រើន ។ បញ្ហានេះអាចនាំដល់អំពើរំលោភធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស និងការងារពល កម្មរបស់ពួកគេ ហើយមានការតៀបសង្កត់កាន់តែកើនឡើងលើស្ត្រីដើម្បីគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រុមគ្រួសារ របស់ពួកគេ និងការផ្លាស់ប្តូរតួនាទីជាប្រពៃណីបណ្តាលអោយស្ត្រីភាគច្រើនចាកចេញពីកន្លែងផ្ទះកំណើតរបស់ពួក គេ ដើម្បីទៅរកការងារធ្វើនៅកន្លែងផ្សេង វាជាដំណើរមួយដែលធ្វើឱ្យស្ត្រីធ្វើចំណាកស្រុក ។ ពួកគេតែងតែ មិនយល់ដឹងអំពីគ្រោះថ្នាក់ដែលមាន ជារឿយៗ ពួកគេត្រូវបានបញ្ឆប់ការស្រមៃរបស់ពួកគេ ដោយត្រូវគេបោកសំរាប់ការជួញដូរ និងការងារកេងប្រវ័ញ្ចខាងផ្លូវភេទ ។

ការរំលោភសិទ្ធិមនុស្សអាចកើតឡើងពីដំណាក់កាលដែលទើបនឹងជ្រើសរើសមកធ្វើការ ទៅរហូតដល់ការ បញ្ជូនទៅកន្លែងផ្សេង និងក្នុងខណៈពេលដែលរស់នៅនិងធ្វើការតាមគោលដៅរៀងៗខ្លួន ។នៅដំណាក់កាល ទាំងនេះស្ត្រី និងកុមារ អាចដឹងដោយខ្លួនឯងថាពួកគេត្រូវគេកេងប្រវ័ញ្ចរំលោភ ឬជួញដូរ ។

- **ការជួញដូរមនុស្ស:** គឺជាទំរង់រំលោភមានលក្ខណជាក់លាក់ដែលកើតមាននៅក្នុងការធ្វើ(បំលាស់លំនៅ) វាត្រូវបានគេអោយអត្ថន័យដោយការប្រើឥរិយាបទខុសឆ្គង ដែលមិនធ្វើឡើងដោយមិនការយល់ព្រម ឬកិច្ចសន្យា និងជាការជាប់ទាក់ទងនិងការរំលោភសិទ្ធិ មនុស្សដ៏ធ្ងន់ធ្ងរមួយចំនួនទៀតរួមមានការងារពលកម្ម ដោយបង្ខំ ការកេងប្រវ័ញ្ចខាងផ្លូវភេទ និងការងារពលកម្ម អំពើហិង្សា និងការរំលោភជនរងគ្រោះ (GENPROM, 2002) ។

## ១.១០ ទំនាក់ទំនងរវាងចំណាកស្រុក ការជួញដូរ និងការកេងប្រវ័ញ្ចការងារពលកម្ម

យុវវ័យនិងក្មេងៗច្រើនងាយរងគ្រោះបំផុត និងការកេងប្រវ័ញ្ចការងារពលកម្មធ្ងន់ធ្ងរដែលញឹកញាប់មកពីក្រុមមួយដែលងាយរងគ្រោះ ឬក្រុមដែលគេបោះបង់មិនអើពើ និងជាក្រុមដែលគេទាត់ចោលក្នុងសង្គម ។ ពួកគេទាំង នេះរួមមានក្មេងកំព្រា ក្មេងដែលមានតែឪពុក ឬមានតែម្តាយ ឬក្មេងដែលជាមេគ្រួសារ ក្មេងៗក្រុមកុលសម្ព័ន ឬក្មេងៗជនជាតិភាគតិច ក្មេងរស់នៅតាម ចិញ្ចើមថ្នល់ ក្មេងធ្វើនិរប្រវេសន៍ និង ក្មេងជាជនភៀសខ្លួន ។

ក្មេងជំទង់ៗច្រើនតែធ្វើនិប្រវេសន៏ជាមួយឪពុកម្តាយរបស់ពួកគេ ហើយក្នុងភាពជាវ័យជំទង់ ពួកគេអាច ជ្រើសរើសដើរតាមផ្លូវរបស់ពួកគេ ។ ទោះបីជាគ្មានការទាក់ទងគ្នាច្បាស់លាស់រវាងការធ្វើនិប្រវេសន៍ និង ពលកម្មកុមារ យ៉ាងណាក៏ដោយ ក៏ការសិក្សាស្រាវជ្រាវមួយចំនួនបានស្នើជាយោបល់ថាក្មេងៗដែលកើតនៅក្រៅ ប្រទេសត្រូវបានគេរកឃើញថាទទួលរង នូវការកេងប្រវ័ញ្ចនិងការងារគ្រោះថ្នាក់ជាងក្មេងៗដែលកើតក្នុងប្រទេសរបស់ខ្លួនដោយសារខ្វះឋានៈខាងផ្លូវច្បាប់ក្នុងប្រទេសដែលជាម្ចាស់ស្រុកនិងការរើសអើងពីប្រជាជនក្នុងស្រុកប្រឆាំងនិងជនជាតិបរទេស ឬអ្នកចំណូលថ្មី ។

ក្មេងដែលធ្វើនិប្បវេសន៍ ឬក៏ត្រូវគេជួញដូរតែម្នាក់ឯងនៅដាច់ពីបណ្តាញគាំទ្ររបស់ក្រុមគ្រួសាររបស់ពួកគេ ជារឿយៗត្រូវបានគេចាត់ទុកជាអមិត្ត ហើយបរិយាកាសដែលពួកគេជួបប្រទះនោះគឺមិនចេះភាសា ត្រូវគេ បដិសេធការចូលរួមក្នុងសង្គម និងមិនមានលទ្ធភាពចូលរៀនក្នុងសាលា ឬក៏ទទួលបានសេវាថែទាំសុខភាព ពីព្រោះពួកគេមិនមានឯកសារចាំបាច់ដែលត្រូវបង្ហាញ ។ ក្មេងៗដែលកើតក្នុងគ្រួសារដែលធ្វើនិប្បវេសន៍ជាច្រើន នៅក្នុងក្រុង ឬប្រទេសថ្មីដោយមិនអាចចុះបញ្ជីនិងធ្វើសំបុត្រកំណើតទេ ។ លទ្ធផលនេះបង្ហាញពីភាពគ្មានរដ្ឋ (បុគ្គលក្រៅរដ្ឋ) ហើយនិងការដកពួកគេចេញពីសង្គម និងឱកាសសេដ្ឋកិច្ចដែលធ្វើអោយពួកគេទទួលរងនូវ ទំរង់ជាច្រើននៃការរើសអើង ។

នៅក្នុងស្ថានភាពដូចនេះជំរើសតែមួយគត់ដែលបន្សល់ដល់ពួកនិប្បវេសន៍ និងកម្មករដែលត្រូវគេជួញដូរគឺ ត្រូវធ្វើការនៅក្នុងការងារ "3D" (គឺការងារលំបាក ក្រខ្វក់ និង គ្រោះថ្នាក់) ។ ការងាររបស់ពួកគេជាញឹកញាប់ គ្មានឯកសារ គ្មានការការពារ និងមិនស្របច្បាប់ ។ ភាគច្រើននៃពួកគេខ្វះការទទួលស្គាល់ស្របច្បាប់ ហើយពួក គេក្លាយជាគោលដៅដ៏សំខាន់សំរាប់ប៉ូលីសវាយបង្ក្រាប ឃុំខ្លួន និងការនិរទេស ។ វាជារឿងធម្មតាទេ សំរាប់ ពួកអ្នកធ្វើនិប្បវេសន៍ដែលត្រូវចោទសួរដោយពួកអាជ្ញាធរ ហើយផ្តល់សំណូក និងសំរាប់ស្ត្រីរកស៊ីផ្លូវភេទ ដែលត្រូវ បានគេស្នើសុំដើម្បីរួមរក្សដោយមិនផ្តល់ប្រាក់ ដើម្បីជៀសវាងការដាក់ទណ្ឌកម្មនោះ (មជ្ឈមណ្ឌល និប្បវេសន៍ អាស៊ាន(AMC) ២០០២) ។

មានអាយុនិងទំហំយេនឌ័រច្បាស់លាស់នៅក្នុងការជួញដូរកុមារ ទៅក្នុងការងារពលកម្មដោយបង្ខំ ។ នោះគឺថាក្មេងៗ ជំទង់ទំនងជាអាចគេចផុតពីការងារពលកម្មដោយបង្ខំតិចតួចណាស់ លើសពីនេះក៏មានក្មេងប្រុស និងក្មេងស្រីផ្សេងៗទៀតដែលមានបំណងចូលរួម និងសកម្មភាពផ្សេងៗទោះបីមានការងារជាន់គ្នាច្រើនយ៉ាងណាក៏ដោយ ។ ប៉ុន្តែក្មេងស្រីមានចំនួនច្រើន ជាងដែលធ្លាក់ទៅក្នុងការកេងប្រវ័ញ្ចខាងផ្លូវភេទ និងការងារតាមផ្ទះ ឯក្មេងប្រុសត្រូវគេកេណ្ឌចូលទ័ពដោយបង្ខំ និងជាអ្នកលីសែងតវ៉ាន់សំរាប់យោធាសំរាប់ជម្លោះដោយអាវុធនៅមជ្ឈឹមបូព៌ា ។(ILO អនាគត ដែលគ្មានពលកម្មកុមារ ២០០២) ។

យេនឌ័រ ជាបញ្ហាកំណត់មួយ ក្នុងការជួញដូរទាំងខាងផ្គត់ផ្គង់ និងតម្រូវការ ។ នៅក្នុងតំបន់មួយចំនួនជន រងគ្រោះមួយចំនួនធំគឺជាមនុស្សប្រុស ។ ឧទាហរណ៍ជនធ្វើនិប្បវេសន៍ជាង ៨០% ត្រូវបានជួញដូរចូលក្នុងប្រទេស អ៊ុយក្រែន និងប្រទេសប៉ូឡូញ ដែលពួកគេគឺជាបុរស[5] ។ ជាទូទៅ ទោះបីយ៉ាងណាក៏ដោយស្ត្រី និង ក្មេងស្រី ដែលជាជនរងគ្រោះក្នុងការជួញដូរ គឺទំនងជាមានច្រើនជាង បុរស និងក្មេងប្រុស ។ ស្ត្រី និង ក្មេងស្រី ជាញឹកញាប់ ត្រូវបានគេជួញដូរដើម្បីធ្វើជាពេស្យាចារ និងការកេងប្រវ័ញ្ចខាងផ្លូវភេទ ។ តែទោះបីជាយ៉ាងណាក៏ដោយការ ជួញដូរមិនគួរចាត់ទុកចូលក្នុងអំពើពេស្យាចារ និងការកេងប្រវ័ញ្ចផ្លូវភេទ ដោយសារតែទំរង់ដទៃៗទៀតជាច្រើននៃការកេងប្រវ័ញ្ចពលកម្មបានកើតឡើងផងដែរ ។ "ការជួញដូរគឺជាសញ្ញាមួយដ៏ធ្ងន់ធ្ងរនៃភាពក្រខ្សត់ ហើយក៏ជា ភារកិច្ចដ៏លំបាករបស់ស្ត្រី និងក្មេងស្រីក្នុងការប្រឈមមុខជាមួយបញ្ហានៅក្នុងពិភពលោកដែលមានលក្ខណៈនៃការ រើសអើងយេនឌ័រទាំងនៅខាងក្នុង និងខាងក្រៅទីផ្សារពលកម្ម" (GENPROM 2002) ។ ទាំងខាងផ្គត់ផ្គង់ និងតម្រូវការ ការរើសអើង និងភាពមិនស្មើគ្នា គឺជាការរាលដាលមួយដែលរារាំងស្ត្រី និងកុមារី ពីការគ្រប់គ្រងលើជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ។

## កត្តានៅពីក្រោយការជួញដូរស្ត្រី និង កុមារី

### ផ្នែកខាងផ្គត់ផ្គង់

- ស្ត្រីទុរគតភាព
- ការគ្មានការងារធ្វើនិងកង្វះនៃឱកាសសេដ្ឋកិច្ច
- ការកើនឡើងនៃសំភារៈនិយម និងការប្រាថ្នាចង់បានជីវិតរស់នៅល្អប្រសើរឡើង
- ស្ថានភាពគ្រួសារអត់ការងារធ្វើ គ្មានមុខរបរ
- ភាពមិនស្មើគ្នានៃយេនឌ័រ ក្នុងឱកាសទទួលបានការ សិក្សានិងការបណ្តុះបណ្តាល
- ការខ្វះឱកាសដើម្បីទទួលពត៌មាន
- ការរើសអើងនៃមូលដ្ឋានយេនឌ័រនិង/ឬជនភាគតិច
- ប្រពៃណីវប្បធម៌ និង ឥរិយាបថសហគមន៍ និងការ អនុវត្តដែលអត់អោនក្នុងការប្រើអំពើហឹង្សា ប្រឆាំង នឹងស្ត្រី
- គោលនយោបាយការធ្វើនិប្បវេសន៍ ដែលផ្អែកលើ ការជ្រើសរើសខាងផ្លូវភេទ
- ច្បាប់ និង ក្របខណ្ឌការងារគ្មានប្រសិទ្ធិភាព
- បន្លាស់ទី និងការអុកឡុកវឹកវរដោយធម្មជាតិ និងវិនាសកម្មដែលបង្កើតឡើងដោយមនុស្ស

### ផ្នែកខាងតម្រូវការ

- និយោជកត្រូវការការងារពលកម្មដែលមានតំលៃថោក និងដែលអាចកេងប្រវ័ញ្ចបាន
- អតិថិជនទាមទារផ្លូវភេទវ័យក្មេង ដែលជួនកាល ត្រូវ បានផ្តល់ដោយអ្នកដែលជួញដូរ
- ការរើសអើងខាងយេនឌ័រ
- ការកើនឡើងនូវការខ្វះខាតបុគ្គលិក និង ពត៌មាន ក្នុងទីផ្សារពលកម្ម
- ការរីកចំរើននៃឧស្សាហកម្មខាងផ្លូវភេទនិង ការកំសាន្ត សប្បាយ
- ការជួញដូរដែលអាចចំនេញខ្ពស់ ហើយមានគ្រោះ ថ្នាក់តិច
- ការខ្វះប្រសិទ្ធិភាពនៃក្របខណ្ឌការងារ និងកង្វះនៃ ការ ដាក់អោយប្រតិបត្តិតាម
- កង្វះអង្គការនិងកិច្ចព្រមព្រៀងពីសំណាក់ដើម្បីតវ៉ារបស់កម្មករ
- ការអនុវត្តតាមវប្បធម៌សង្គមដែលមានការរើសអើង ទាក់ទងទៅនឹងការរំលោភ សិទ្ធិមនុស្ស

ប្រភព : GENPROM ការការពារពីការរើសអើង ការកេងប្រវ័ញ្ចនិងការរំលោភបំពានលើ កម្មករស្ត្រី ដែល និប្បវេសន៍ : ការណែនាំពត៌មាន សៀវភៅតូចលេខ ៦ ការជួញដូរស្ត្រី និង កុមារី ILO : ទីក្រុងហ្សឺណែវ ២០០២ Text Box 6, 5, p 24.

[5] ការិយាល័យស្នងការជាន់ខ្ពស់សំរាប់សិទ្ធិមនុស្ស "ការជួញដូរមនុស្ស : ជាបញ្ហាសិទ្ធិមនុស្ស" ព្រឹត្តិបត្រចេញ រៀងរាល់ បីខែម្តង ស្តីពីការជួញដូរអ្នកធ្វើនិប្បវេសន៍ លេខ ២៦ ខែ កញ្ញា ឆ្នាំ ២០០២ (ទីក្រុងហ្សឺណែវ IOM 2002) http://www.iom.int ក្នុង GENPROM, 2002

## ១.១១ បញ្ហាប្រឈមមុខដ៏លំបាកក្នុងការអនុវត្តន៍ច្បាប់ ?

វាជាការទទួលយកជារួមដែលសិទ្ធិមនុស្សជាមូលដ្ឋានដែលបានពិពណ៌នានៅក្នុងសេចក្តីប្រកាសជាលក្ខណៈអន្តរជាតិ និងអនុសញ្ញាមិនអាចត្រូវបានបដិសេធ ចំពោះមនុស្សជាតិបានឡើយ ហើយរដ្ឋាភិបាលមិនអាច បដិសេធន៍ក្នុងការផ្តល់អោយសិទ្ធិទាំងនេះដល់ប្រជាជនរបស់ខ្លួនដោយគ្មានយុត្តិកម្មឡើយ ។ ឧទាហរណ៍មនុស្ស គ្រប់រូបមានសិទ្ធិក្នុងការរស់នៅ។ ក្នុងករណីមានសង្គ្រាមទាហានទាំងអស់ដែលមកពីខាងសត្រូវអាចត្រូវបានបដិសេធមិនផ្តល់អោយនូវសិទ្ធិនេះប៉ុន្តែមិនមែនជាជនស៊ីវិលឡើយ ។នៅក្នុងលក្ខណៈជាអន្តរជាតិមានការព្រមព្រៀងគ្នាថាគឺគ្មានប្រទេសណាអាចពឹងផ្អែកទាំងស្រុងលើអធិបតេយ្យភាពដើម្បីរំលោភច្បាប់លើសិទ្ធិមនុស្សជាមូលដ្ឋាន របស់ប្រជាជនខ្លួនទេ (របៀបវារៈរបស់អង្គការសហប្រជាជាតិសំរាប់សន្តិភាព នៅឆ្នាំ ១៩៩២) ។ នេះនៅតែជាបញ្ហារសើបខាងនយោបាយមួយប៉ុន្តែមានការយល់ព្រមលើការព្រមព្រៀងនេះកំពុងរីកសាយភាយទូទាំងពិភពលោក និងកើនឡើងលើប្រទេសមួយចំនួន ដោយមិនគិតពីកិរិតនៃការរីកចំរើនរបស់ពួកគេទេ ។

ទោះជាយ៉ាងណាក៏ដោយការអនុវត្តសិទ្ធិមនុស្សជាមូលដ្ឋានត្រូវបានដាក់ចូលក្នុងកិរិតជាលក្ខណៈអន្តរជាតិ និង ក្នុងច្បាប់ជាតិជារឿយៗច្រើនមានបញ្ហាពីព្រោះសិទ្ធិអាចត្រូវបានដាក់អោយប្រតិបត្តិតាមនៅពេលមានមធ្យោបាយ ដោះស្រាយ គឺថាច្បាប់ក្បួនច្បាប់ ឬនិតិវិធីព្រមទាំងប្រព័ន្ធតុលាការ (តុលាការនិងអង្គការអនុវត្តន៍ច្បាប់) ។ នេះគឺជាបញ្ហានៅក្នុងប្រទេសជាច្រើន ។ យន្តការថ្មីមួយ ក្នុងចំនោមយន្តការណ៍ថ្មីទាំងឡាយដែលផ្តល់អោយ ក្រុមដែលងាយទទួលរងគ្រោះជាមួយនិងមធ្យោបាយមួយទៀតដើម្បីការពារសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ គឺការបង្កើតឡើងនូវគណកម្មាធិការ សិទ្ធិមនុស្សជាតិ នៅក្នុងប្រទេសជាច្រើន ។

ជូនកាលមានជំលោះផលប្រយោជន៍ ក្នុងការគោរពសិទ្ធិមនុស្ស ។ ឧទាហរណ៍សិទ្ធិក្នុងការអភិវឌ្ឍន៍ និង អវត្តមាននៃភាពក្រីក្រសំរាប់ប្រជាជនទាំងអស់ មិនបានឆ្លើយតបដោយរដ្ឋាភិបាលជាច្រើន ដោយសារអ្នកពាក់ពន្ធ័ នយោបាយផ្សេងៗគ្នាជាមួយនិងរដ្ឋាភិបាលព្រមទាំងកង្វះការយល់ដឹងនិងជំនាញក្នុងចំណោមប្រជាជនដើម្បីបង្ហាញពីសិទ្ធិរបស់ពួកគេ ។

បទដ្ឋាន និង តំលៃវប្បធម៌ត្រូវបានដាក់ផងដែរតាមឋានានុក្រមនៃសិទ្ធិហើយជាញឹកញាប់បានកំនត់ថា តើ ក្បួនច្បាប់ត្រូវបានគេធ្វើតាមយ៉ាងដូចម្តេច ។ សិទ្ធិកុមារនិងស្ត្រីបានដាក់ក្នុងឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ ហើយ ច្បាប់ជាតិ ជាញឹកញាប់ត្រូវបានគេរំលោភ ពីព្រោះបទដ្ឋានសង្គម និងវប្បធម៌ បានផ្តល់ឋានៈដល់ពួកគេទាប ជាងបុរស ។

ការការពារសិទ្ធិរបស់អ្នកដែលធ្វើនិប្រវេសន៍ និងអ្នកដែលត្រូវគេជួញដូរ គឺលំបាក។ ឧទាហរណ៍ក្នុងករណី ការជួញដូរមនុស្សពេញវ័យសំរាប់ការការពារសិទ្ធិនៃការកេងប្រវ័ញ្ចពលកម្មដែលជាធម្មតាទាក់ទិននងិច្បាប់នៃការ ជួញដូរ ច្បាប់ពេស្យាចារ និងច្បាប់ពលកម្មកុមារ ។ ទោះបីជាយ៉ាងណាក៏ដោយច្បាប់ទាំងនេះមិនមាននៅ ក្នុងប្រទេសមួយចំនួននោះទេ ហើយនៅពេលច្បាប់ទាំងនេះមានការប្រតិបត្តិតាម គឺមានតិចតួច អំពើពុករលួយ ភាពផ្ទុយគ្នានៅក្នុងច្បាប់ និងភាពលំអៀងតាមប្រពៃណីប្រឆាំងនឹងស្ត្រី និងក្មេងស្រី ធ្វើអោយច្បាប់ទាំង នេះគ្មានប្រសិទ្ធិភាព ។ ម៉្យាងវិញទៀតច្បាប់ទាំងនេះ ជាពិសេសច្បាប់ពេស្យាចារ ច្បាប់ការជួញដូរ ឬក៏ច្បាប់ ការងារដែលនិប្រវេសន៍បានដាក់ទម្ងន់ទៅលើការដាក់ទណ្ឌកម្មជាងការការពារចំពោះជនរងគ្រោះកម្មករនិប្រវេសន៍ និងជនរងគ្រោះដែលត្រូវគេជួញដូរ ជារឿយៗត្រូវបានគេដាក់ទោសហើយនិរទេសព្រោះការចូលដោយខុសច្បាប់ នៅពេលដែលនិយោជកនិង អ្នកជួញដូរខុសច្បាប់ទាំងនោះកំរនិងទទួលការដាក់ទោស ។ ក្នុងករណី ការជួញដូរ ពេស្យាចារកុមារ ការដាក់ទោសចំពោះអតិថិជន គឺកំរនិងធ្វើឡើងណាស់ ។ (Tumlin, 2000)

# ២. ភាពផ្សេងគ្នាជាច្រើននៃយេនឌ័រសំខាន់ៗ និងសនិទានភាព នៅក្នុងពលកម្មកុមារ

នៅទូទាំងសកលលោកមានមតិស្របគ្នាកំពុងតែកើនឡើង ដែលមនុស្សជាតិគ្រប់រូបចាប់កំណើតដោយសេរី និង ស្មើគ្នាប្រកបដោយសេចក្តីថ្លៃថ្នូរនិងសិទ្ធិជាច្រើនហើយនិងសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូបដែល រួមមានទាំងកុមារ និងស្ត្រី ត្រូវការអោយគេគោរព ។ បញ្ហានេះត្រូវគេក្រិតយ៉ាងល្អិតល្អន់នៅ អង្គការសហប្រជាជាតិជាច្រើន (UN) និងអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ (ILO) ដែលត្រូវបានអភិវឌ្ឍន៍ ដោយសហគមន៍ពិភពលោក និងត្រូវបានគេអោយសច្ចាបន័ក្នុងបណ្តាប្រទេសជាច្រើន ។

ការផ្តល់ឱកាសច្រើនស្មើគ្នាដល់ក្មេងប្រុស និងក្មេងស្រី បុរស និងស្ត្រីទាំងឡាយ គឺមិនត្រឹមតែជា បញ្ហារបស់សិទ្ធិមនុស្ស និងយុត្តិធម៌ក្នុងសង្គមប៉ុណ្ណោះទេ វាជាបញ្ហានៃការស្ទាបស្ទង់ការវិនិច្ឆ័យសេដ្ឋកិច្ច ទៀតផង ពីព្រោះកម្លាំងការងារមានសុខភាពបរិបូរណ៍មានការអប់រំ គឺជាលក្ខខ័ណ្ឌដំបូងសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដ៏មាននិរន្តរភាពរបស់ប្រទេសហើយសង្គមជាច្រើនមិនសំរេចនូវសក្តានុពលសេដ្ឋកិច្ចរបស់ពួកគេបានទេនៅពេលដែលធនធានមនុស្សរបស់ខ្លួនមិនត្រូវបានប្រើប្រាស់ពេញលេញទេនោះ ។ដូច្នេះវាចាំបាច់ត្រូវអប់រំនិងបណ្តុះបណ្តាលទាំងក្មេងប្រុសទាំងក្មេងស្រីទាំងឡាយនិងការដាក់ ទំងន់ទៅលើការទទួលខុសត្រូវរួមគ្នារបស់បុរសនិងស្ត្រីទាំងឡាយដើម្បីថែរក្សាអ្នកជំនាន់ក្រោយ ។

បទពិសោធន៍បានរៀនមកពីកិច្ចប្រឹងប្រែងនៃការអភិវឌ្ឍន៍នោះ មិនបានដោះស្រាយនូវបញ្ហានៃភាពមិនស្មើរគ្នារបស់យេនឌ័រមានបំណងដើម្បីធ្វើឱ្យការរស់នៅឱ្យយ៉ាប់យ៉ឺនជាងការធ្វើឱ្យងាយស្រួលសំរាប់ក្មេងស្រី និងស្ត្រីទាំងឡាយ ។ នៅទូទាំងពិភពលោកស្ត្រីច្រើនជាងបុរសជាសមាជិកអ្នកក្រីក្រ ភាពក្រីក្ររបស់ស្ត្រីទាំងឡាយ គឺធ្ងន់ធ្ងរជាង និងភាពក្រីក្រក្នុងចំណោមស្ត្រីទាំងឡាយកំពុងតែកើនឡើង ។ ស្ត្រីក្រីក្រទាំងឡាយមិនអាច ថែរក្សាកូនរបស់ខ្លួនអោយបានគ្រប់គ្រាន់នោះទេ និងក្នុងចំណោមពួកគេជាច្រើននៅក្នុងភាពក្រីក្រពីជំនាន់ មួយទៅជំនាន់មួយ ។ ខួបនេះត្រូវការអោយគេបំបែកដោយសារតែយុត្តិធម៌ក្នុងសង្គមទាំងការពិនិត្យពិច្ច័យ ដែលសំអាងលើហេតុការណ៍ ។ ការចរចាជាច្រើនបន្តឱ្យមានការវិនិយោគដល់ស្ត្រី ពីព្រោះពួកគេត្រូវដឹងប្រភពចំណាយនិងប្រាក់ចំណេញដែលពួកគេទទួល លើការកែលំអរសុខុមាលភាពសុភមង្គលនៃគ្រួសារទាំងឡាយរបស់ពួកខ្លួនជាងទៅលើ ផ្ទាល់ខ្លួនឯងតែម៉្យាង ។

ការផ្សព្វផ្សាយនូវការលុបបំបាត់ពលកម្មកុមារ និងភាពស្មើគ្នារវាងភេទគឺមិនមែនតែជាសិទ្ធិ ប៉ុណ្ណោះទេ ប៉ុន្តែជាការងារលំបាកដែលត្រូវធ្វើ ។

## ២.១ ហេតុការណ៍ជាក់ស្តែង និងតួលេខ

នៅដើមសហវត្សថ្មី ក្នុងឆ្នាំ 2000 កុមារ 211 លាននាក់មានអាយុពី 5-14 ឆ្នាំឬប្រមាណជា 18% នៃក្មេងប្រុស និងក្មេងស្រីក្នុងក្រុមអាយុនេះមានភាពសកម្មក្នុងសេដ្ឋកិច្ច គឺធ្វើការងារធ្វើការដើម្បីលុយឬក៏ដើម្បីសងបំណុលផ្សេងៗ ។ ៦០%នៃកុមារធ្វើការទាំងនេះ (១២៧លាននាក់) ត្រូវបានប្រទះឃើញ នៅអាស៊ី និងប៉ាស៊ីហ្វិច ម្នាក់ក្នុងចំណោមក្មេង ៥នាក់ក្នុងប្រភេទអាយុបែបនេះគឺកំពុងធ្វើការក្នុងតំបន់នេះ នៅ Sub-Sahara Africa មានក្មេងចំនួន ៤៨ លាននាក់ពី៥-១៤ឆ្នាំ (22%) កំពុងតែធ្វើការម្នាក់ក្នុងចំណោមក្មេង ៣នាក់ក្នុងប្រភេទអាយុបែបនេះ គឺកំពុងតែធ្វើការនៅក្នុងតំបន់នេះ ។មានតែជាង ៦% (១៣.៤ លាននាក់) គឺត្រូវបានគេឃើញនៅអាហ្វ្រិកខាងជើង និងមជ្ឈឹមបូព៌ាហើយ៨%(១៧.៤លាននាក់)នៅអាមេរិចឡាទិន និងការ៉ាអ៊ីប (ILO អនាគតដែលគ្មានពលកម្មលើកុមារ ២០០២) ។

តាមការអោយអត្ថន័យនៃពលកម្មកុមាររបស់ ILO ក្នុងឆ្នាំ2000 ក្មេងប្រមាណ ២៤៥.៥ លាននាក់ ដែលមានអាយុពី ៥-១៧ឆ្នាំទូទាំងពិភពលោកគឺស្ថិតនៅក្នុងពលកម្មកុមារ ។ ក្រុមនេះមាន ១១០ លាននាក់ គឺមានអាយុ៥-១១ឆ្នាំ ។ កុមារពលកម្មទាំងអស់គឺប្រមាណជា១៧០.៥លាននាក់គឺត្រូវបានគេឃើញនៅក្នុងការងារដែលមានគ្រោះថ្នាក់ហើយ៦០.៥លាននាក់ នៅក្នុងប្រភេទនេះគឺមានអាយុ៥-១១ឆ្នាំ (មើលប្រអប់ខាងក្រោម) ។

ស្ថិតិពលកម្មកុមារគួរពិនិត្យពិច្ច័យអោយបានជិតដល់ពីព្រោះជាចរិតនៃការគេងប្រវ័ញ្ចពលកម្មកុមារគឺត្រូវបានគេ បិទបាំងហើយការទទួលពត៌មានពិតប្រាកដគឺមានការពិបាក ។ ចំនួនក្មេងស្រីដែលកំពុងធ្វើការគឺជារឿយៗត្រូវបានគេវាយតម្លៃទាបដោយតាមការស្ទាបស្ទង់ស្ថិតិនោះដែលជាទូទៅមិនបានគិតពីសកម្មភាពសេដ្ឋកិច្ច ដែលមិន បានទទួលប្រាក់កំរៃ ដូចជាការងារតាមផ្ទះ ឬក៏សកម្មភាពលាក់បំពួនមួយចំនួនទៀត ដូចជាពេស្យាចារ ប្រភេទ ការងារដែលក្មេងស្រីជាច្រើនបានទាក់ទិន (ILO ឯកសារការងារស្តី ពីពលកម្មកុមារនៅអាស៊ី Volume 1,2001) ។

## ស្ថិតិពលកម្មកុមារ (ចំនួនគិតជាលាន 0000.000)

| ក្រុមអាយុ និង ភេទ | កុមារដែលធ្វើសកម្មភាពសេដ្ឋ កិច្ចសកម្ម | ពលកម្មកុមារ | កុមារនៅក្នុងការងារដែលប្រកបដោយគ្រោះថ្នាក់ | និយមន័យ លើពលកម្មកុមារ ដែលផ្អែកលើ អនុសញ្ញា របស់ ILO លេខ ១៣៨ និង ១៨២ |
|---|---|---|---|---|
| 5-11 | 109.7 | 109.7 | 60.5 | នៅក្នុងពីអាយុពី ៥-១១ ឆ្នាំ = កុមារទាំងអស់ នៅក្នុងសកម្មភាពសេដ្ឋកិច្ចយ៉ាងចោក |
| កុមារា | 56.3 | 56.3 | 30.7 | |
| កុមារី | 53.4 | 53.4 | 29.8 | |
| 12-14 | 101.1 | 76.8 | 50.8 | នៅក្នុងពីអាយុពី ១២-១៤ ឆ្នាំ = កុមារទាំងអស់ នៅក្នុងសកម្មភាពសេដ្ឋកិច្ចសកម្មលើក លែងតែសកម្មភាពទាំងនោះស្ថិតក្នុងការងារ ស្រាល |
| កុមារា | 52.7 | 41.5 | 30.6 | |
| កុមារី | 48.4 | 35.1 | 20.2 | |
| 15-17 | 140.9 | 59.2 | 59.2 | នៅក្នុងពីអាយុពី ១៥-១៧ ឆ្នាំ = កុមារ ទាំងអស់ ស្ថិតនៅក្នុងការងារ ដែលគ្រោះ ថ្នាក់ និងទំរង់ធ្ងន់ធ្ងរ បំផុត និងធ្ងន់ធ្ងរផ្សេង ទៀតនៃពលកម្មកុមារ |
| កុមារា | 75.1 | 34.4 | 34.4 | |
| កុមារី | 65.8 | 24.8 | 24.8 | |
| សរុប (5-17) | 351.7 | 245.5 | 170.5 | ស្ថិតិមិនបានរាប់បញ្ចូលកុមារដែលធ្លាក់នៅក្នុងការងារ ដែលគេមិនបានគិតដល់ "សកម្ម ភាពសេដ្ឋកិច្ច" ដូចជា ការងារផ្ទះ ដែលកុមារី ជារឿយៗត្រូវបានគេ ប្រទះឃើញ |
| កុមារា | 184.1 | 132.2 | 95.7 | |
| កុមារី | 167.6 | 113.3 | 74.8 | |

ប្រភព : ILO ចំនួនកុមារទាំងអស់ : ការប៉ាន់ប្រមាណ នៃពិភពលោកជាថ្មីស្តីអំពីពលកម្មកុមារ . ILO :

## តើពលករកុមារធ្វើអ្វី ?

៧០.៤% កសិកម្ម នេសាទ ប្រមាញ់ និង ការដាំដើមឈើ
៨.៣% ផលិតកម្ម
៨.៣% ការលក់ដុំ ការរកស៊ីលក់រាយ ភោជនីយដ្ឋាន និង សណ្ឋាគារ
៦.៥% សហគមន៍ សង្គម និង សេវាកម្មផ្ទាល់ខ្លួន
៣.៨% ដឹកជញ្ជូន កន្លែងផ្ញើរឥវ៉ាន់ និង គមនាគមន៍
២.៧% ការសាងសង់ ការជីករ៉ែ និង ការគាស់យកថ្ម

ប្រភព : ILO អនាគតដែលគ្មានពលកម្មលើកុមារ

## កុមារនៅក្នុងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

| ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | ការប៉ាន់ប្រមាណក្នុងពិភពលោក | ការប៉ាន់ប្រមាណក្នុងអាស៊ី-ប៉ាស៊ីភិច |
|---|---|---|
| ពលកម្មដោយបង្ខំ និងជាប់បំណុល | 5.7 | 5.5 |
| ការជ្រើសរើសដោយបង្ខំក្នុងជំលោះប្រដាប់អាវុធ | 0.3 | 0.12 |
| ពេស្យាចារ និង ការថតរូបអាសអាភាស | 1.8 | 0.59 |
| សកម្មភាពខុសច្បាប់ | 0.6 | 0.22 |
| កុមារត្រូវគេជួញដូរ* | [1.2] | [0.25] |
| សរុបផ្នែក | **8.4** | **6.43** |
| កុមារក្នុងការងារដែលប្រកបដោយគ្រោះថ្នាក់ | 170.5 | 104** |
| សរុប | **178.9** | **110.5** |

<u>កំណត់ចំណាំ</u> : * ចំនួននៃកុមារដែលត្រូវគេជួញដូរគឺមិនរាប់បញ្ចូលចំនួនសរុបនៃកុមារនៅក្នុងទំរង់ធ្ងន់ធ្ងរផ្សេងៗទៀតនៃពលកម្មកុមារទេ ។

** តួលេខពីការិយាល័យតំបន់ IPEC សំរាប់អាស៊ី-ប៉ាស៊ីភិច ។

ប្រភព : ILO ចំនួនក្មេងទាំងអស់ ការប៉ាន់ប្រមាណនៃសកលលោកជាថ្មីស្តីអំពីពលកម្មកុមារ ILO : ទីក្រុងហ្សឺណែវ (២០០២)តារាងលេខ ៥ និង ១០ ។

កាលវាលដាលមួយនៃនៃការកេងប្រវ័ញ្ចពលកម្មកុមារ គឺការងារតាមផ្ទះ ។ តាមធម្មតាការងារតាមផ្ទះ គឺត្រូវគេរកឃើញថាវាជាការងារដែលងាយស្រួល និងមានសុវត្ថិភាពសំរាប់កុមារ ជាពិសេសសំរាប់ក្មេងស្រី ។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានគេបង្ហាញក្នុងពេលថ្មីៗនេះថា ការងារតាមផ្ទះអាចចូលទៅក្នុងចំណោម ការងារដែលគ្រោះថ្នាក់បំផុតសំរាប់កុមារ ហើយត្រូវបានគេទទួលស្គាល់ថា ជាទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។ ខណៈដែលការងារតាមផ្ទះធ្វើជាមួយម្ចាស់ផ្ទះដែល ល្អអាចផ្តល់ដល់កុមារដែលក្រីក្រអោយមានឱកាស ដើម្បីអភិវឌ្ឍន៍ ទទួលការអប់រំហើយអាចរកស៊ីចិញ្ចឹមជីវិត ការងារតាមផ្ទះនៅក្នុងប្រទេសជាច្រើន មានឋានៈទាបបំផុត ហើយស្ថិតក្នុងចំណោមការចំណាយទាបបំផុត ហើយពលករកុមារតាមផ្ទះជាច្រើនបានធ្លាក់ទៅក្នុងការកេងប្រវ័ញ្ច ។ ដោយសារតែកុមារបំរើការតាមផ្ទះភាគច្រើនរស់នៅក្នុងផ្ទះហើយមានសេរីភាពតិចតួចការរស់នៅហើយនិងសុវត្ថិភាពរបស់ពួកគេជារឿយៗវាអាស្រ័យទៅលើការសណ្តោសប្រណីរបស់ម្ចាស់ផ្ទះ ។ ភាគច្រើនដ៏លើសលប់នៃកុមារបំរើការតាមផ្ទះ គឺជាក្មេងស្រី ហើយបានប្រឈមមុខជាច្រើន និងការរំលោភផ្លូវកាយ ផ្លូវចិត្ត រឺ ក៏ការរំលោភ ផ្លូវភេទ ។

**កុមារបំរើការតាមផ្ទះ នៅអាស៊ី . មានតួលេខខ្លះ**



- ៣០០.០០០ CDWs មានអាយុពី ៧-១៧ឆ្នាំ ធ្វើការនៅក្នុងទីក្រុង ដាកា ប្រទេសបង់ក្លាដេស
- ៧០០.០០០ CDWs នៅក្នុងទីក្រុង Jakata ប្រទេស ឥណ្ឌូនេស៊ី គឺនៅក្រោមអាយុ ១៨ ឆ្នាំ
- ក្នុងប្រទេសឥណ្ឌា ២០% នៃអ្នកបំរើតាមផ្ទះទាំងអស់ គឺនៅក្រោមអាយុ ១៤ ឆ្នាំ និង ៤០% នៃអ្នកបំរើតាមផ្ទះចំនួន ៤០០.០០០ នាក់ នៅក្នុងទីក្រុង Mumbai គឺក្មេងស្រីនៅក្រោមអាយុ ១៥ ឆ្នាំ
- ៥៥.៦០០ CDWs ធ្វើការនៅតាមជាយក្រុងនៃទីក្រុង Kathmandu ប្រទេស នេប៉ាល់ដែលភាគ ច្រើននៃ CDWs គឺជាក្មេងប្រុស
- មួយក្នុងចំណោម ១០គ្រួសារ ក្នុងទីក្រុង Galle ប្រទេស ស្រីលង្កា បានប្រើប្រាស់ CDW មួយ ។
- ២៥.០០០ CDWs នៅក្នុងប្រទេសហ្វីលីពីន គឺមានអាយុពី ១០-១៤ឆ្នាំ និងលើចំនួន ២៧៥.០០០ គឺមានអាយុពី ១៥-១៩ ឆ្នាំ

ប្រភព : PIEC "ទិដ្ឋភាពទូទៅនៃកុមារបំរើការតាមផ្ទះក្នុងអាស៊ី "ឯកសារនេះបានបង្ហាញនៅក្នុងកិច្ចប្រជុំអាស៊ី

មានការប៉ាន់ប្រមាណថា ក្មេងជាង ១.២ លាននាក់ ត្រូវបានគេជួញដូរ សំរាប់ការកេងប្រវ័ញ្ចពលកម្ម និងការ កេងប្រវ័ញ្ចផ្លូវភេទ នៅក្នុងពិភពលោកប្រមាណ ២៥០.០០០ នាក់ នៅអាស៊ីប៉ាស៊ីភិច ។ ទោះបីជាយ៉ាងណា ក៏ដោយ ការប៉ាន់ប្រមាណចំនួនកុមារដែលត្រូវគេជួញដូរជារឿយៗ គឺមានការប្រែប្រួលតាមប្រភពផ្សេងៗ ។ ឧទាហរណ៍ចំនួនក្មេងដែលត្រូវគេជួញដូរសំរាប់របរពេស្យាចារ នៅឥណ្ឌាមានចន្លោះពី ២៥០០០ និង ៥០០០០០ ។ ដូច្នេះការប៉ាន់ប្រមាណគួរតែត្រូវបានគេគិតពិចារណាដោយប្រុងប្រយ័ត្ន ។ ទោះបីជាមានការពិបាកក្នុងការកំណត់ ចំនួនពិត នៃកុមារដែលត្រូវគេជួញដូរក៏ដោយ មានទិន្នាការច្បាស់មួយថាវាកំពុងតែកើនឡើងពាសពេញ ពិភពលោក ជាពិសេសសំរាប់ការកេងប្រវ័ញ្ចផ្លូវភេទ ។ នៅអាស៊ី ខាងត្បូង និងអាស៊ីអគ្នេយ៍ ចំនួនដ៏លើសលប់នៃកុមាររង គ្រោះពីការជួញដូរ គឺក្មេងស្រី ប៉ុន្តែលើកលែងតែនៅប្រទេសស្រីលង្កា ហើយនឹងមានចំនួនតិចនៅប្រទេសប៉ាគីស្ថាន ដែលក្មេងប្រុសត្រូវបានគេឃើញត្រូវគេជួញដូរសំរាប់កេងប្រវ័ញ្ចផ្លូវភេទដែរ (Tumlin, 2000) ។

## ២.២ បទពិសោធន៍ផ្សេងគ្នានៃក្មេងប្រុស និង ក្មេងស្រី

នៅក្នុងការវិភាគពលកម្មកុមារជាសំខាន់ត្រូវស្វែងយល់ស្វែងយល់ថាក្មេងប្រុសនិងក្មេងស្រីមានបទ ពិសោធន៍ផ្សេងគ្នា ។ ទី១ :ជាដំបូងមាតាបិតាជាច្រើនមានបំណងនិងសេចក្តីសង្ឃឹមផ្សេងគ្នារវាងកូនស្រី និងកូនប្រុស ។ កូនត្រូវបានកើតនៅក្នុងសង្គមមួយតាំងពីនៅក្មេង គឺវាជាប់នូវតួនាទីយ៉េនឌ័ររបស់មាតាបិតាពួកគេ ឧទាហរណ៍ ក្មេងប្រុសត្រូវបានសង្ឃឹមថាធ្វើការងារជួយឪពុក និងក្មេងស្រីជួយការងារម្តាយរបស់ពួកគេ ។ នៅសង្គមជាច្រើន បញ្ហានេះមានន័យ ថាក្មេងប្រុសនិងក្មេងស្រីចាប់ធ្វើសកម្មភាពផ្សេងៗគ្នា ហើយគឺត្រូវបានគេដាក់ទៅក្នុងការងារ របស់បុរស និង ការងាររបស់ស្ត្រីរៀងៗខ្លួន ។ ឧទាហរណ៍ ទាំងក្មេងប្រុស ទាំងក្មេងស្រី ត្រូវបានគេប្រទះឃើញ ក្នុងខណៈពេល កំពុងធ្វើការសំរាប់គ្រួសារនៅស្រែ និងនៅផ្ទះ ក្នុងភោជនីយដ្ឋានតូចៗ ក្នុងរោងចក្រ ឬក៏នៅ តាមផ្លូវ ក្មេងប្រុសជារឿយៗ ត្រូវបានគេប្រទះឃើញក្នុងផ្នែកបុរសភាគច្រើនធ្វើដូចជា ការជីករ៉ែ និង នេសាទ ចំណែកក្មេងស្រីធ្វើការងារក្នុងផ្នែកស្ត្រីរួមមានផលិតផលកាត់ដេរ និង សេវាផ្សេងៗទៀត ដូចជាការងារផ្ទះ និងកន្លែងកំសាន្តនានា ។



ទី២. ក្មេងប្រុស និងក្មេងស្រីមានការជំរុញ និង ហេតុផលផ្សេងគ្នាធ្វើអោយពួលគេប៉ះពាល់និងពលកម្មកុមារ ឬការចាកចេញពីផ្ទះ ។ ធម្មតាភាពក្រីក្រនិងគ្មានឱកាសជា កម្លាំងចលករដែលជំរុញចូលក្នុងពលកម្មកុមារ និងការចាកចេញពីផ្ទះ ដើម្បីស្វែងរកការងារ ។ មូលហេតុខ្លះក៏ដូចជា សេចក្តីសង្ឃឹមរបស់មាតាបិតា សេចក្តីប្រាថ្នាមុតមាំធ្វើអ្វីមួយផ្ទាល់ខ្លួនរបស់កុមារ និងឆន្ទះចង់ធ្វើការ និងនិយម ប្រើប្រាស់ទំនិញ ឬសេវា ដែលមាន បរិមាណខ្ពស់កាន់តែច្រើនឡើងៗជារឿយដែលកំណត់របៀបកុមារានិង កុមារីធ្វើការផ្លាស់លំនៅស្ថាន ឬក៏ត្រូវបានគេជួញដូរ ។ ហេតុផលដទៃទៀតរួមទាំងជម្លោះក្រុមគ្រួសារ គ្រួសារបែកបាក់ ការរំលោភផ្លូវកាយ និង ផ្លូវចិត្តស្ថានភាពនយោបាយ និងគ្រោះធម្មជាតិក៏រួមចំណែក ក្នុងការដឹកនាំកុមារឱ្យចាកចោលផ្ទះសំបែងដែរ ។ តាមលទ្ធផលការស្រាវជ្រាវបានស្នើរថាកុមារា ទោទន់ទៅនឹងឆាប់ទទួលសម្ពាធពីមិត្តភិក្តិក្នុងពេលដែលកុមារីត្រូវបានដឹកនាំដោយគ្រួសារ និងសម្ពាធមិត្តភិក្តិ (Wille 2002) ។



## ២.៣ កុមារី និងស្ត្រី : រស់នៅក្នុងសង្គមមានឋានៈទាប

គ្រប់សង្គមទាំងអស់ប្រាថ្នាឱ្យមានភាពល្អប្រសើរសំរាប់ក្មេងៗជំនាន់ក្រោយ និងត្រូវបានយល់ព្រមយ៉ាងទូលំទូលាយថា ក្មេងទាំងអស់មានសិទ្ធិចំពោះការអភិវឌ្ឍន៍សុខភាព ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសង្គមនិងគ្រួសារភាគច្រើនកុមារានៅតែមានសិទ្ធជាងកុមារី ។ តាមពិតទៅការប្រព្រឹត្តិផ្សេងគ្នា ចាប់ផ្តើមនៅពេល ចាប់កំណើត ឬមុនចាប់កំណើត ។ ភស្តុតាងនេះអាចឃើញក្នុងការសំលាប់ទារិកាក្នុងផ្ទៃជាស្រីមុនពេលវាកើត និង ការសំលាប់ ទារិកាជាស្រី ការកាត់ស្បែកចុងអង្គជាតិចេញពីកុមារា ការនិយមអោយមានពិធីច្រើននៃកំណើត ផ្សេងទៀត សំរាប់កុមារា និង កុមារី ហើយនិងការផ្លាស់ប្តូរក្នុងរបបអាហាររបស់ពួកគេ ។





ឪពុកម្តាយដែលក្រីក្រតែងចំណាយទុនច្រើនលើកូនប្រុសពួកគេ ហើយនិង ចង់ឱ្យកូនស្រីពួកគេធ្វើការដើម្បីជួយថែរក្សា តំរូវការក្រុមគ្រួសារជាមូលដ្ឋាន ។ សូម្បីនៅក្នុងករណីខ្លះ ដែលកុមារីត្រូវបានផ្តល់ឱកាសអោយរៀន ជានិច្ចកាលពួកគេយល់ថាជាកុមារាគឺវាប្រសើរនិងមាន តំលៃជាងការសិក្សារបស់កុមារី ។ នៅក្នុងវប្បធម៌ភាគច្រើនកុមារីមានអកប្បកិរិយាបែបនេះក្នុងខ្លួនដែលធ្វើអោយពួកនាងខ្មាសអៀនជារឿយៗនិងបង្ហាញបុគ្គលិកលក្ខណៈមោះមុតតិចជាងកុមារា ។ លទ្ធផលនេះក្នុងការធំឡើង ជាស្ត្រីភេទដោយមានការកាន់តែច្រើនឡើងនិងឱកាសកាន់តែតិច ។ ផ្ទុយទៅវិញ ពួកគេមានសមត្ថភាពតិចតួចចំពោះឥទ្ធិពលវិជ្ជមានលើការរស់នៅនៃកូនស្រី របស់ពួកគេដោយន័យនោះខួបនៃភាពក្រីក្រនិងការកេងប្រវ័ញ្ចលើស្ត្រីពីជំនាន់មួយទៅជំនាន់មួយទៀតចេះតែបន្តរហូត ។ឋានៈទាបរបស់ស្ត្រីហើយនិងក្មេងស្រីគឺបានជ្រួតជ្រាបនៅក្នុងសង្គមវប្បធម៌ និងទំនៀមទំលាប់ដូចជាគេអាចឃើញ នៅក្នុងសុភាសិត ពីប្រទេសជាច្រើន ។ ឧទាហរណ៍

- ប្រសិនអ្នកមានកូនស្រី ១០នាក់ ប្រៀបដូចជាអ្នកគ្មានកូន តែប្រសិនអ្នកមានកូនប្រុសម្នាក់ ប្រៀបដូចអ្នក មានកូនមួយ
- មានកូនស្រីម្នាក់គឺ ដូចជាមានបង្គន់នៅពីមុខផ្ទះអញ្ចឹង
- បុរសគឺជាជើងមុខហើយស្ត្រី គឺជាជើងក្រោយរបស់ដំរី

## ២.៤ ការអប់រំ និង ការបណ្តុះបណ្តាលជំនាញការងារ

បទដ្ឋានតំលៃ និងការអនុវត្តទាក់ទិនទៅនឹងសិទ្ធកុមារាច្រើនជាងកុមារី ពិសេសចំពោះឱកាសទទួលបានការ អប់រំកំពុងផ្លាស់ប្តូរ និងការលួតលាស់គួរចាប់អារម្មណ៍កំពុងត្រូវបានធ្វើ ជាពិសេសក្នុងការផ្តល់ឱកាសស្មើគ្នា រវាង កុមារា និងកុមារី ចំពោះការអបរំជាមូលដ្ឋាន ប៉ុន្តែឧបសគ្គដ៏សំបើមនៅតែមាន ។ កុមារីនៅតែបន្ត ការទទួល ឱកាសតិចតួច ចំពោះការសិក្សា និងការបណ្តុះបណ្តាលជាពិសេសនៅកំរិតមធ្យមសិក្សា និង ឧត្តម សិក្សា ។ នេះគឺជាការពិត នៅក្នុងសង្គម ដែលឋានៈរបស់ស្ត្រីគឺនៅក្រោម ឋានៈរបស់បុរស ហើយក្មេងស្រី និងស្ត្រីត្រូវបានគេកំណត់ទៅលើកិច្ចការក្នុងផ្ទះដោយគ្មានប្រាក់កំរៃ ហើយថែរក្សាសមាជិកនៅក្នុងផ្ទះ និង សហគមន៍ ។

ក្នុងចំណោមក្មេងដែលមិនបានចូលទៅសាលាបឋមសិក្សាទូទាំងពិភពលោកមាន ៦០% ជាក្មេងស្រី ។ទោះ បីក្នុងចំណោមកុមារដែលកំពុងសិក្សាផងក៏ដោយ ឃើញថា ក្មេងស្រីមានការអប់រំតិចជាងក្មេងប្រុស (Wille 2002) ប្រពៃណីវប្បធម៌អាចរារាំងក្មេងស្រីពីការចូលសាលារៀន ឧទាហរណ៍នៅក្នុងវប្បធម៌ខ្លះ ក្មេងស្រីគឺមិន ត្រូវគេអនុញ្ញាតិអោយចូលក្នុងថ្នាក់រៀនជាមួយក្មេងប្រុសទេ ជួនកាលឪពុកម្តាយថែរក្សាកូនស្រីរបស់ពួកគេនៅផ្ទះ ដោយសារសាលានៅឆ្ងាយពេក មិនមានសុវត្ថិភាព។ ជាធម្មតាពីព្រោះពួកគេត្រូវការជំនួយជាមួយការងារក្នុងផ្ទះ។ លើសពីនេះទៅទៀតកង្វះខាតនៃការទទួលគ្នា នៃការអប់រំជាមូលដ្ឋានក្មេងស្រី គឺតែងតែត្រូវគេដាក់ទៅក្នុង ការងារដែលមានតំលៃទាប នឹងការងារនៅក្នុងលំដាប់សក្តិដែលមានកំរិតទាបជាងកុមារាដែលមកពីគ្រួសារដែល មានកំរិតប្រាក់ចំណូលប្រហាក់ប្រហែលគ្នា ។



ជាលទ្ធផលទូទាំងពិភពលោក ស្ត្រីមានការអប់រំតិចជាងបុរស កាលពីពួកគេនៅក្មេង ភាគច្រើននៃប្រជាជន ដែលមិនចេះអក្សរគឺជាស្ត្រី ។ ពួកគេនៅតែបន្តការមានឱកាសតិចតួច ដើម្បីទទួលការ អប់រំនិងការបណ្តុះ បណ្តាល បើប្រៀបធៀបទៅនឹងបុរសពេញវ័យមកពីប្រភេទដែលមានប្រាក់ចំណូលដូចគ្នា ។បញ្ហានេះ មានន័យថា ស្ត្រីជាច្រើនដែលមានភាពក្រីក្រមិនមានឱកាសដើម្បីរកប្រាក់ចំណូល អោយបានគ្រប់គ្រាន់សំរាប់ខ្លួន ពួកគេផ្ទាល់ និងសំរាប់កូនៗ របស់ពួកគេឡើយ ។

ប្រពន្ធ័នៃការអប់រំនិងការបណ្តុះបណ្តាល ជារឿយៗ បានបន្ថែមអោយមានភាពមិនស្មើគ្នានៅក្នុងសង្គម ។ ឧទាហរណ៍ កម្មវិធី និងការពណ៌នាអំពី សំភារៈបណ្តុះបណ្តាលក្មេងស្រីនិងស្ត្រីនៅក្នុងបន្ទុក ឬក៏នៅ តំណែងក្រោមបង្គាប់ ឬក៏លក់ជា អ្នកមើលការខុសត្រូវកិច្ចការផ្ទះនៅក្នុងគ្រួសារ ។ បុរសគឺតែងតែជើរតួជាអ្នក សំរេចចិត្ត តែម្នាក់ឯង ហើយនិងជាអ្នករកការ ។ អ្នកបណ្តុះបណ្តាលលំអៀងបន្ថែមទៀតទៅលើភេទហើយនិងយេនឌ័រនៅពេលផ្តល់ការណែនាំពីមុខរបរដែលវាគឺជាការពិបាកច្រើនសំរាប់ទាំងបុរសទាំងស្ត្រី ដើម្បីស្វែងរកការ ងារ និងប្រាក់ចំណូលនៅក្នុងមុខរបរ ដែលគេគិតថា ជាការងាររបស់បុរស និង ការងាររបស់ស្ត្រីផ្សេងៗ ។

វិយោគកម្ម (ការញែក)ភេទនៅក្នុងទីផ្សារការងារគឺជាបញ្ហាធ្ងន់ធ្ងរ ។ ទូទាំងពិលោកមានបុរសធ្វើការ៧ដង ដូចស្ត្រីចំពោះការងារក្រៅពីកសិកម្ម ហើយចំណែកក្នុងមុខតំណែងកំពូលរបស់ស្ត្រីនៅក្នុងក្រុមហ៊ុនធំៗបំផុត ទូទាំងពិភពលោកគឺមានពីតែ ២ ទៅ ៣ % (Anker 1998 និង Wirth 2001) ដំណើរការត្រូវគេដឹងថាជាវិយោគកម្មមុខ របរតាមខ្សែទទឹង និង ខ្សែបណ្តោយដោយភេទ ។

ការងារស្ត្រីជាច្រើនត្រូវបានគេប្រទះជារឿយៗមានឋានៈទាបជាងការងារបុរស ។ ឧទាហរណ៍ នៅក្នុងសង្គមជាច្រើនវិជ្ជបណ្ឌិតជាធម្មតាគឺជាបុរសហើយគិលានុប្បដ្ឋាយិកា គឺភាគច្រើនជាស្ត្រី ។ នៅអឺរ៉ុបខាងកើត និងអតីត USSR សាស្ត្រាចារ្យនៃវិជ្ជបណ្ឌិតមានស្ត្រីភាគច្រើន ហើយត្រូវបានគេអនុញ្ញាតិអោយមានឋានៈទាប ជាង និង ទទួលប្រាក់ទាបជាងការងារជាវិស្វករ ដែលមានបុរសភាគច្រើន ។

## ២.៥ ការងារដែលមិនបានទទួលប្រាក់កំរៃ និងការងារដែលគេមិនអាចមើលឃើញ



ស្ត្រី និង កុមារីនៅតែបន្តអោយមានភាពទទួលខុសត្រូវជាចម្បងសំរាប់ការងារដែលមិនបានទទួលប្រាក់កំរៃ នៅក្នុងផ្ទះសម្បែង ដូចជា ការចំអិនម្ហូបអាហារ សំអាតផ្ទះ ការថែរក្សាក្មេងៗ និងសមាជិកគ្រួសារដែល មានវ័យចំណាស់នៅក្នុងបន្ទុក ។ ប្រភេទនៃការងារនេះគឺមិនបានផ្តល់ជារង្វាន់ និងបានចាត់ទុកថាជាការងារ ដែលមានលក្ខណៈមិនមែនសេដ្ឋកិច្ចនោះទេ ។ ដូច្នេះជាទូទៅវាមិនត្រូវបានគេវាស់វែងនៅក្នុងស្ថិតិពលកម្មទេ ហើយដូចនោះក្លាយជាមិនអាចឃើញ ។ ទោះជាយ៉ាងណាក៏ដោយ ពេលដែលរាប់នូវម៉ោងសរុបនៃការងារ បានចំណាយទៅលើសកម្មភាពសេដ្ឋកិច្ច និងគ្រួសារ និងថែរក្សា ផ្ទះសម្បែង ស្ត្រីនិងក្មេងស្រីទូទាំងពិភពលោកធ្វើការច្រើនម៉ោងជាងបុរស និងក្មេងប្រុសជានិច្ចកាល ។ ផ្ទុយមកវិញ ទាំងក្មេងប្រុស ទាំងបុរសបានទទួល ពេលសំរាកច្រើនជាងស្ត្រី និងក្មេងស្រី ។



មានមនុស្សរាប់លាននាក់ជាពិសេស ស្ត្រីនិងកុមារធ្វើការជាកម្មករក្នុងគ្រួសារដែលមិនមានប្រាក់កំរៃ នៅលើដីធ្លី ឬនៅក្នុងសហគ្រិនគ្រួសារមួយ ជារឿយៗនៅក្នុងវិស័យមិនរៀបរយ ។ ការងារបែបនេះត្រូវទទួលស្គាល់ ជាផ្លូវការថា ជាសកម្មភាពសេដ្ឋកិច្ច ប៉ុន្តែការឱ្យតម្លៃទាបបន្តកើតឡើង ពីព្រោះស្ត្រី និងកុមារ និងអ្នកចុះឈ្មោះ លើបញ្ជីដែលធ្វើបទសម្ភាសពួកគេ មិនចាត់ទុកសកម្មភាពទាំងនេះជាការងារទេ ។

ក្មេងស្រីចាប់ផ្តើមធ្វើការនៅវ័យក្មេងជាងក្មេងប្រុស ជាពិសេសនៅក្នុងតំបន់ជនបទ ដែលជាកន្លែងមាន កម្មករកុមារមួយភាគធំត្រូវបានគេប្រទះឃើញ ។ កុមារទាំងនោះ ក៏ធ្វើការងារក្នុងគ្រួសារ ទាំងនៅតំបន់ ជនបទ ទាំងតំបន់ទីក្រុង ។ កុមារភាគច្រើនត្រូវបានគេមិនអនុញ្ញាតអោយសិក្សា ឬ ទទួលរងបន្ទុក បីដងគឺ ការងារផ្ទះមួយ ការងារសាលាមួយ និងការងារសេដ្ឋកិច្ចមួយ ។

## ២.៦ ការងារច្រើនតែមិនសូវមានគុណភាព

រយពេលបីទសវត្សន៍ចុងក្រោយនេះបានបង្ហាញទុកភស្តុតាងនូវការកើនឡើងនៃការងារដែលមានប្រាក់កំរៃ សំរាប់ស្ត្រីជាសកល ជាដំណើរមួយដែលគេបានដឹងថា ជាការងារសំរាប់ស្ត្រី ប៉ុន្តែការងារនេះភាគច្រើនមានគុណ ភាពទាបណាស់ ។ នៅក្នុងបណ្តារប្រទេសកំពុងអភិវឌ្ឍន៍ ទំរង់ការងារមានការផ្លាស់ប្តូរនៅក្នុងវិធីដូចខាងក្រោម ៖

- នគរូបនីយកម្មនិងការអភិវឌ្ឍន៍យ៉ាងលឿននៃទីក្រុងនានានៅក្នុងបណ្តាប្រទេសជាច្រើនកំពុងទាក់ទាញបុរសច្រើនឡើងកមកាន់ទីក្រុងទាំងនោះ ។ បញ្ហានេះបានធ្វើឱ្យស្ត្រីជាអ្នកធ្វើកសិកម្ម នៅក្នុងតំបន់ជនបទជាច្រើន ដូចជានៅប្រទេសចិន និង ប្រទេសឥណ្ឌា ។



- យុវនារីដែលបានធ្វើចំណាកស្រុកពីតំបន់ជនបទត្រូវបានគេប្រទះឃើញភាគច្រើនធ្វើការនៅតាមរោងចក្រ ឬ កន្លែងធ្វើការផ្សេងៗ ការងារក្នុងការផលិត ផលិតផលកសិកម្មក្នុងការនាំចេញ តំបន់ឧស្សាហកម្មនានា ឬ នៅក្នុងសេវាកម្មនានា ។



■ តំរូវការសេដ្ឋកិច្ចគ្រួសារបានបង្ខំអោយស្ត្រីជាច្រើនមកពីគ្រួសារក្រីក្រក្លាយជាអ្នកប្រកបរបរទទួលទានក្នុងផ្នែកមិនរៀបរយដោយខ្លួនឯងនិងបង្កើនប្រាក់ចំណូលតាមរយៈការរកប្រកបរបរទទួលទានដោយខ្លួនឯង ដោយវិធីណាក៏ដោយពួកគេអាចការពារគ្រួសារពីគ្រោះអត់ឃ្លាន ។ ឧទាហរណ៍ការប្រកបរបរនៅតាមដងវិថី នៅក្នុងទីក្រុងនានាឬក៏ អ្នកបង្កើតរបរសិប្បកម្មនៅក្នុងតំបន់ជនបទ ។



■ ចំនួនស្ត្រីចេះតែកើនឡើងក្នុងកិច្ចការផ្ទះ បង្កើតអត្រាការងារជាចំណែកសំរាប់ការបង្កើតសហគ្រាសកមន្តសាលនៅពេលបញ្ចប់បណ្តាញក្រុមអ្នកម៉ៅការ ។



■ ស្ត្រីធ្វើការនៅផ្នែកបំរើសេវាកម្មច្រើនជាងបុរស ។ នៅក្នុងប្រទេសជាច្រើន ស្ត្រី និង កុមារីភាគច្រើនត្រូវបានប្រទះឃើញនៅក្នុងការងារដែលលំអៀងទៅតួនាទីបន្តពូជជាប្រពៃណីរបស់ស្ត្រីដូចជាការងារផ្ទះការបោសជូតការផ្តល់ការកំសាន្ត និងការងាររកស៊ីផ្លូវភេទ ។



កុមារទាំងឡាយ ជាពិសេសកុមារីជារឿយៗធ្វើការនៅជិតម្តាយរបស់ពួកគេនៅក្នុងផ្នែកមិនរៀបរយនិងការងារនៅផ្ទះ ហើយជួនកាលកុមារីគឺត្រូវធ្វើការនៅក្នុងឧស្សាហកម្មផលិតដែរ ។ នៅក្នុងករណីមួយភាគធំ ប្រាក់ចំណូលរកបាននិងលក្ខខ័ណ្ឌ ការងារនិងលក្ខខ័ណ្ឌការជួលទាបណាស់ ។

កម្មការនីដែលធ្វើការនៅក្នុងផ្នែកមិនរៀបរយបានត្រឹមតែគ្រប់គ្រាន់តែចិញ្ចឹមជីវិត ។ ភាគច្រើនមានកំរិតត្រឹមអាននិងសរសេរនិងជំនាញជាគ្រឹះផ្នែកគណិតសាស្ត្រនិងចាប់ផ្តើមការរកស៊ីតូចដដែលៗ ។ បញ្ហានេះ ដឹកនាំទៅរកការកកស្ទះ និងការប្រកួតប្រជែង ។ កម្មករធ្វើការតាមផ្ទះនៅក្នុងក្រុមអ្នកម៉ៅការអាចធ្វើការតែម៉្យាង នៅពេលមានបញ្ហាហើយជាទូទៅពួកគេមានអំណាចចរចារបន្តិចបន្តួចជាមួយអ្នកម៉ៅការ ។

ស្ត្រីបំរើការងារក្នុងឧស្សាហកម្មកមន្តសាល ឧទាហរណ៍នៅក្នុងតំបន់ ឧស្សាហកម្មទាំងនោះជារឿយៗត្រូវបានជួលជាកម្មករដែលមិនមានជំនាញនិងត្រូវងាយស្រួលចេញពីការងារក្នុងករណីរៀបការឬក៏មានផ្ទៃពោះ ។ម៉ោងធ្វើការក្នុងករណីទាំងបីមានរយៈពេលយូរ ហើយនិងការការពារពលកម្ម សន្តិសុខ និង សុវត្ថិភាពសង្គម និង ច្បាប់សុខភាព ជារឿយៗ មិនបានពង្រឹង ឬបានអនុវត្តមិនគ្រប់គ្រាន់ ។

## ២.៧ ការងារដែលមិនមានការការពារ ឬ ខុសច្បាប់



ក្នុងចំណោមពលករកុមារដែលមិនអាចមើលឃើញបំផុតនោះ ជាកុមារបំរើការតាមផ្ទះ ។ មានការទាក់ទង ជាក់លាក់រវាងកុមារដែលធ្វើការតាមផ្ទះនិងការជួញដូរកុមារសំរាប់ការកេងប្រវ័ញ្ចពលកម្មទាំងក្នុងប្រទេសទាំងឆ្លងកាត់ប្រទេស ។ ឧទាហរណ៍ ជាក់ស្តែងមួយនៃពលកម្មកុមារខុសច្បាប់ ( និងមើលមិនឃើញ ) គឺជាពាណិជ្ជកម្ម ភេទតែម្តង ។ ថ្វីត្បិតតែការជួញដូរកុមារ សំរាប់ពេស្យាកម្មបានទទួលការយកចិត្តទុកដាក់ច្រើនពីអាជ្ញាធរដែនដី សង្គមនិង ប្រពន្ធ័ឃោសនាការជួញដូរ កុមារក្មេងខ្ចីសំរាប់ការងារតាមផ្ទះត្រូវបានគេទទួលស្គាល់តែម៉្យាងនាពេលថ្មីៗនេះ បើទោះបីជាបញ្ហាទាំងពីរ ជាបាតុភូតជាសាកលក៏ដោយ ។ ក្មេងស្រី ( និងស្ត្រី ) មានឥទ្ធិពលលើប្រភេទការងារទាំងនេះដែលមិនត្រូវបានផ្តល់ការធានារ៉ាប់រងដោយច្បាប់ពលកម្ម និងការថែការពារ ។

ដោយសារប្រភេទការងារទាំងនេះជាទូទៅលាក់កំបាំងពីទស្សនៈក្នុងក្រុមគ្រួសារឯកជន ឬនៅក្នុងកន្លែងការ ងារដែលពិបាកចូលទៅជិតក្មេងៗដែល ធ្វើការក្នុងការងារទាំងនោះ ជាញឹកញាប់ត្រូវបានគេដាក់អោយដាច់ដោយឡែកពីសង្គម ។ ឧទាហរណ៍ កុមារបំរើតាមផ្ទះ ត្រូវបានគេបំបែកចេញពីគ្រួសារពួកគេធ្វើអោយពួកគេ ងាយ ទទួលរងគ្រោះ ពីការរំលោភលើផ្លូវចិត្ត ផ្លូវកាយ និងផ្លូវភេទ ។ លើសពីនេះ ដោយសារតែឋានៈ ទាប និងលក្ខណៈការងារមិនស្របច្បាប់កុមារកុមាររកស៊ីខាងផ្លូវភេទត្រូវ រងគ្រោះជារឿយៗ ដោយត្រូវបានបង្ខាំងទុក សំរាប់ការរំលោភធ្ងន់ធ្ងរលក្ខខណ្ឌកេងប្រវ័ញ្ច និងការគំរាមកំហែង ដល់ជីវិត ។




មិនត្រឹមតែក្មេងស្រី និងស្ត្រីកាន់តែកើនឡើងប៉ុណ្ណោះទេ បុរស និងក្មេងប្រុសក៏អញ្ចឹងដែរ ត្រូវបានគេជួញដូរសំរាប់ការកេងប្រវ័ញ្ចពលកម្មធ្លាក់ទៅជាពេស្យាកម្ម បំរើតាមផ្ទះ រោងចក្រឬកន្លែង ការងារតូចៗកិច្ចការទាំងអស់ហ្នឹងធ្វើអោយពួកគេរងទុក្ខវេទនា ជាពិសេសប្រសិនបើពួកគេ មិនចេះនិយាយភាសា ។



មិនមានឋានៈស្របច្បាប់ដែលអនុញ្ញាតិអោយពួកគេ រស់នៅ ទៅរៀន ឬធ្វើការងារស្របច្បាប់ កុមារដែល ជាអ្នកផ្លាស់លំនៅ បរទេសក៏ដូចជាកុមារក្នុងស្រុក មិនមានឯកសារស្របច្បាប់ច្បាស់លាស់ ។ ការទោរទន់ ជញ្ជូន ផលប្រយោជន៍ពីកុមារ ក្នុងភាពជាទាសករដែលជាប់បំណុល និងក្នុងពលកម្មដែលបង្ខំ និងការកេងប្រវ័ញ្ចផ្លូវភេទ ។ សិទ្ធិពួកគេមិនត្រូវបានគេទទួលស្គាល់ និងការពារ ។ ម៉្យាងវិញទៀតពួកគេអាចត្រូវបានគេកាត់ទោសថា ជាទោស ខុសច្បាប់ពេលចាប់ខ្លួនបានបង្កអោយពួកគេលាក់ខ្លួនពីអាជ្ញាធរ បញ្ហានេះបែរជាធ្វើអោយអជ្ញាធរកាន់តែពិបាករកពួកគេ ។

## ២.៨ ប្រាក់ចំណូល និងប្រាក់ចំណាយ

ស្ត្រីជាមធ្យមរកប្រាក់បាន 2/3 នៃប្រាក់ចំណូលរបស់បុរសក្នុងសេដ្ឋកិច្ចនៃការងារគ្រប់បែបទាំងអស់ហើយស្ត្រីនៅតែរកប្រាក់បានតិចជាងបុរសរាល់កំរិតនៃចំណេះដឹង ។ ផ្នែកមួយនៃគម្លាតនេះ ក្នុងប្រាក់ចំណូលអាចត្រូវគេពន្យល់ដោយភាពផ្សេងគ្នារវាងការសំរេចនៃការសិក្សានិងបទពិសោធន៍ការងារដែលមានន័យថា ការរើសអើងនៃយេនឌ័រក្នុងការទទួលប្រាក់ខែស្មើគ្នាសំរាប់ការងារដែលមានតំលៃដូចគ្នានៅតែរាលដាល ។

វាហាក់ដូចជាគោលការណ៍សំរាប់ក្មេងស្រី ។ ជាមធ្យមក្មេងស្រីត្រូវគេបើកប្រាក់តិចជាងក្មេងប្រុសចំពោះការងារដែលមានប្រភេទដូចគ្នា ។ ឧទាហរណ៍ ពាក់កណ្តាលនៃក្មេងស្រីដែលធ្វើការតាមផ្ទះនៅក្នុង ទីក្រុងដាកា ប្រទេសបង់ក្លាដេស គឺគេចំណាយតិចជាង RS. 4000 (US$51) ក្នុងមួយឆ្នាំ បើប្រៀបធៀបទៅឃើញ ថា មានត្រឹមតែ ២៨% ប៉ុណ្ណោះ នៃអ្នកបំរើការងារតាមផ្ទះជាកុមារា [៦] ។ វាគឺជាភាព ធម្មតាសំរាប់ក្មេងស្រី ក្នុងការមិនទទួលប្រាក់ខែទាល់តែសោះ ចំពោះ ការងារដែលពួកនាងត្រូវធ្វើ ។




[៦] ILO/ប្រទេសជប៉ុន/ប្រទេសកូរ៉េ កិច្ចប្រជុំអាស៊ានស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងនឹងកុមារបំរើការតាមផ្ទះថ្ងៃទី២-៤ ខែ តុលា ២០០២ ទីក្រុងឈៀងម៉ៃ ប្រទេសថៃ

ជាងនេះទៅទៀត ក្មេងស្រី និងស្ត្រីមិនទុកដាក់ប្រាក់ចំណូលដែលពួកគេរកបាននោះទេ ពីព្រោះពួកនាងតម្រូវ អោយប្រគល់ប្រាក់ចំណូលទាំងនោះទៅអោយឳពុកម្តាយ ឬក៏ប្តីរបស់ពួកគេ ។ នៅអាស៊ីខាងកើតស្ត្រីជាច្រើន មើលថែរក្សាការងារផ្ទះ ហើយពួកគេត្រូវតែធានាអោយមានប្រាក់ចំណូលដើម្បីបំពេញតំរូវការមូលដ្ឋានរបស់ គ្រួសារ ។ នៅក្នុងករណីបែបនេះ ស្ត្រីមានតួនាទីគ្រប់គ្រងបាក់ចំណាយប្រចាំថ្ងៃ ប៉ុន្តែជារឿយៗពួកគេត្រូវទទួល ខុសត្រូវជាចំបងសំរាប់ការរកប្រាក់ចំណូលដែលជាតំរូវការសំរាប់ចិញ្ចឹមជីវិត ។ លើសពីនេះទៅទៀត ការស្រាវ ជ្រាវបន្តបញ្ជាក់បន្ថែមថា ក្នុងករណីជាច្រើន ដែលក្មេងស្រី និងស្ត្រីបានទុកដាក់ប្រាក់ចំណូល ពួកនាងចំណាយ វាទៅលើតំរូវការគ្រួសារចាំបាច់ក្នុងកំរិតច្រើនជាងក្មេងប្រុស និងបុរស ។

## ២.៩ ចំណង់ចំណូលចិត្តចំពោះកុមារី និងកម្មការិនីជាច្រើន

ស្ត្រី និងក្មេងស្រីចូលចិត្តធ្វើជាកម្មករ ពីព្រោះពួកនាងតែងតែមានបំណងប្រាថ្នាធ្វើការដំសកម្មក្រោមលក្ខខ័ណ្ឌ ក្រីក្រ ។ ស្ត្រីបាននៅជាមួយអ្នកដទៃក្នុងសង្គមស្តាប់បង្គាប់គេ និង ជាកម្មការនីដំសកម្ម មិនតវ៉ា ឬក៏មិនស្នើរសុំ ។ តាមពិតក្មេងស្រីជាច្រើន គឺរងទុក្ខវេទនាជាពិសេសដោយសារតែវ័យពួកនាង ។ ស្ត្រីតែងតែធ្វើការក្នុងកត្តាជា ច្រើនដែលមិនត្រូវបានគេបង្កើតជាសហជីព ។ សូម្បីនៅក្នុងផ្នែកដែលគេបង្កើតជាសហជីពក៏ដោយ ស្ត្រីតែងតែ ស្វែងរកវាដោយលំបាក ដើម្បីអោយក្លាយជាការពាក់ព័ន្ធដោយសកម្មក្នុងសហជីព ដោយសារតែកិច្ចការផ្ទះសំបែង និងកាតព្វកិច្ចគ្រួសារជាច្រើន ។

## ២.១០ ចំណង់ចំណូលចិត្តរបស់កុមារី និងកម្មការិនីជាច្រើន

ប្រសិនបើស្ត្រី និងកុមារីត្រូវបានគេផ្តល់អោយនូវជំរើសមួយ ពួកគេភាគច្រើនគួរតែមិនចូលចិត្តធ្វើការនៅ ក្រោមលក្ខខ័ណ្ឌជាច្រើនដែលពួកនាងកំពុងធ្វើនាពេលបច្ចុប្បន្ន ។ ទោះបីជាយ៉ាងណាក៏ដោយ ជាទូទៅពួកនាងគិតថា ត្រូវតែធ្វើការ ដើម្បីរួមចំណែកឆ្លើយតបតំរូវការក្រុមគ្រួសារជាចាំបាច់ ។ ទោះជាការងារហ្នឹង កខ្វក់ គ្រោះថ្នាក់ ថោកទាប និង មិនមាន បៀវវត្សរ៍ គ្រប់គ្រាន់ក៏ដោយ ។

ការចង្អុលបង្ហាញជាច្រើនបង្ហាញថា ស្ត្រី និងកុមារីចូលចិត្តការងារដែលមានប្រាក់បៀវវត្សន៍ជាងការងារដែល មិនមានប្រាក់បៀវវត្សន៍ និងស្ម័គ្រចិត្តទទួលប្រាក់ខែទាប និងការរំលោភបំពានមួយចំនួនដូចជា ការបៀតបៀន ផ្លូវភេទ ឬក៏អំពើហឹង្សាផ្សេងៗ ។ ខណៈពេលដែលស្ត្រី និងក្មេងស្រីមិនទុកដាក់ប្រាក់ ចំណូលដែលរកបាននោះទេ កត្តាដែលថាពួកនាងចែករំលែកប្រាក់ចំណូលដល់គ្រួសារមានន័យថាមានការកើនឡើងនូវអំណាចចរចារក្នុងគ្រួសារ

## ២.១១ ទំនាក់ទំនងរវាងយុទ្ធសាស្ត្រនៃការចិញ្ចឹមក្រុមគ្រួសារ ការងារស្ត្រី និងពលកម្មកុមារ

មានពត៌មានតិចណាស់ដែលអាចប្រើបានអំពីទំនាក់ទំនងរវាងការងារស្ត្រី និងពលកម្មកុមារ ។ ទោះជាយ៉ាង ណាក៏ដោយវាច្បាស់ថា ឳពុកម្តាយពុះពារដើម្បីសំរេចបំណងរស់នៅរបស់ក្រុមគ្រួសារនឹងដោះស្រាយពលកម្មកុមារ បានប្រសិនបើពួកគេមិនមានជំរើសផ្សេងទៀត ។ ម្តាយទាំងពួងស្ថិតក្នុងស្ថានភាពនេះពួកគេចាំបាច់អោយគេដោះស្រាយដើម្បីធានាថាបញ្ហាពលកម្មកុមារមិនបានបន្តពីជំនាន់មួយទៅជំនាន់មួយទៀតទេ ។ទស្សនៈរូមនៃយុទ្ធសាទស្តនៃការ ចិញ្ចឹមជីវិតរបស់ក្រុមគ្រួសារជាប់ពាក់ព័ន្ធពលកម្មកុមារតាមគោលការណ៍ខាងក្រោម ។



■ **គ្មានការរៀបចំផែនការគ្រួសារ និងសិទ្ធិមានកូនចៅ** គ្រួសារដែល មានកូនច្រើន តែងតែយល់ ឃើញដោយខ្លួនឯងថា គ្មានសមត្ថភាពផ្តល់ លុយកាក់គ្រប់គ្រាន់សំរាប់ពួកគេទាំងអស់គ្នាបានទេ ។ ទោះបីជាអញ្ចឹងក៏ដោយ ការរៀបចំផែនការគ្រួសារបានប្រែក្លាយជាការរាលដាលក្នុងប្រទេសច្រើនបំផុត នៅតែមាន គ្រួសារភាគច្រើនតាមតំបន់ជនបទនិងក្រុមក្នុងសង្គម ដូចជាអ្នក ផ្លាស់ទីលំនៅដែលខ្វះការទទួលការរៀបចំតំ





■ **ក្រុមគ្រួសារដែលស្ត្រីគេជាមេគ្រួសារតែម្នាក់ឯង** ស្ត្រីដែលទទួលខុសត្រូវក្រុមគ្រួសារ តែម្នាក់ឯង ជាទូទៅខ្វះពេលកម្ម អញ្ចឹងហើយពួកនាង ត្រូវតែថែរក្សា កូនៗ យកចិត្តទុកដាក់ ភារកិច្ចនៅផ្ទះ និងរកប្រាក់ចំណូលដើម្បីឆ្លើយតប ចំណាយតំរូវការជាចាំបាច់របស់គ្រួសារ ។ គ្រួសារភាគច្រើនដែលមានស្ត្រីម្នាក់ជាមេគ្រួសារ នៅ ពេលពួកគេក្រជំរើសតែមួយគត់របស់ពួក គេគឺត្រូវ ដោះស្រាយបញ្ហាពលកម្មកុមារ ក្នុងគោល បំណងដើម្បីការរស់នៅ ។



■ **ធ្វើការតាមម្តាយរបស់ពួកនាង** ស្ត្រីទាំងឡាយសំរេចធ្វើការក្នុងកសិកម្ម ឬផលិត ផល សម្រាប់ទីផ្សារ នៅ ឯផ្ទះនៅតាមផ្លូវ ឬក្នុងកន្លែងធ្វើការនានាផ្សេងទៀត ។ នៅពេលដែលការ ថែទាំកុមារចំពោះ កុមារតូចៗ ហើយនឹងការចូលសាលារៀនរបស់កូនច្បង គឺមិនអាចធ្វើបាន ឬក៏ពុំ មានលទ្ធភាព ម្តាយតែងតែអោយ កូនធ្វើការ កូនរបស់ពួកគេនឹងចាប់ផ្តើមជួយធ្វើការម្តាយបន្តិច ម្តង ៗ ជាមួយនិង ការងាររបស់នាង ។



■ **ការច្រូនុយប្រូថានសម្រាប់ កូនស្រីច្បងនៅក្នុងគ្រួសារ** ពេលម្តាយចេញទៅខាងក្រៅ ដើម្បីធ្វើ ការ ជួយស ម្រាលការងារឪពុក សមាជិកគ្រួសារជំទង់ដ៏ទៃទៀតមិនទំនេរដើម្បីថែរក្សាសមាជិកគ្រួសារ ក្នុងបន្ទុកដ៏ ទៃទៀតទេ ការងារនេះ តែងត្រូវប្រគល់អោយកូនស្រីជាបងដើម្បីអោយមើលការខុសត្រូវផ្ទះ នឹងរក្សាផ្ទះ សម្បែងនិងគ្រួសារ ។



■ ឱកាសកាន់តែច្រើននៃកុមារដែលក្លាយពាក់ព័ន្ធទៅនឹង **ទំរង់ដ៏ធ្ងន់ធ្ងរនៃការគេចប្រចាំពួលពលកម្មកុមារ** ។ ជារឿយៗក្មេង ប្រុសព្រមទាំងក្មេងស្រី ត្រូវបានលក់អោយឈ្មួញកណ្តាល ជាមួយ កិច្ចសន្យាក្លែងបន្លំចំពោះ ទាំងកុមារ ខ្លួនឯង និងឪពុកម្តាយពួកគេថាមានសុវត្ថិភាពការងារមានប្រាក់ខែ សម្រាប់កុមារនៅកន្លែងផ្សេងទៀត ។ កុមារជាច្រើនក្លាយខ្លួនជាទាសករកុមារក្នុងពេស្យាកម្ម ឬ រោងចក្រ ដែលមានការឃាំបយ៉ឺនទទួលប្រាក់ កំរៃតិចតួចស្តួចស្តើង ឬ បំរើការតាមផ្ទះ នៅក្នុងស្ថានភាព ដែលពួកគេមិនមាន ជំរើសដ៏ទៃទៀត ជាងស្នាក់នៅ ឬ ធ្វើអ្វីដែលត្រូវបានគេបញ្ជារអោយធ្វើ ។ រូបភាពប្រហាក់ប្រហែលគ្នានេះអាច កើតឡើងចំពោះក្មេងជាពិសេសចំពោះក្មេងស្រីដែលគេ អនុញ្ញាតិអោយនៅឆ្ងាយដោយឪពុកម្តាយ ក្រីក្រទៅឱ្យ ឈ្មួញកណ្តាលជាច្រើនដែលសន្យាផ្តល់ការរស់នៅដ៏ប្រសើរជាងពួកគេនៅផ្ទះ ។ កុមារទាំងនេះតែងតែធ្លាក់ចូលទៅ ក្នុងស្ថានភាពក្រេប ជញ្ជាក់ញើសឈាមកុមារ ជាកុមារដែលត្រូវបានគេលក់ដូរ ។



■ **ការមានផ្ទៃពោះនៃក្មេងជំទង់** នៅតាមតំបន់ជនបទជាច្រើនក្មេងស្រី នៅតែបន្តការរៀបអាពាហ៍ពិពាហ៍នៅ ក្មេង និងត្រូវការប្រកាន់យកភារៈជាប្រពន្ធ និងជាម្តាយដោយមិនបាន ទទួលប្រយោជន៍ពីការអប់រំ និងបណ្តុះ បណ្តាលបន្ថែម ។ ក្មេងស្រីដែលមានផ្ទៃពោះក្នុងភាពជាប្តីប្រពន្ធនិងគ្នា ជាញឹកញាប់ត្រូវឈប់សិក្សា ។ ពួកគេត្រូវតែផ្គត់ផ្គង់ដោយខ្លួនឯងនិងកូនពេលដែលពួកនាងលែងជាផ្នែក នៃគ្រួសារឬសហគមន៍ ។ ដូច្នេះពួកគេ បានក្លាយទៅជាកម្មករ ក្នុងភាពជាកុមារដោយខ្លួនឯងហើយនិងពាក់ពន្ធ័ ដល់កូនផ្ទាល់ខ្លួនរបស់ពួកគេនៅពេលធំ វាឡើង នឹងជួប បញ្ហាខ្វះជំរើសសំរាប់ជីវិតរបស់ពួកគេ ។

## ២.១២ ការបែងចែកនៃ ការទទួលខុសត្រូវក្នុងគ្រួសារ

ការសិក្សាទូទាំងពិភពលោក បានអះអាងម្តងហើយម្តងទៀតថា ប្រពន្ធបានចំណាយប្រាក់ចំណូលគ្រួសារ ទៅលើសេចក្តីត្រូវការក្នុងគ្រួសារ ដូចជា អាហារ, ជម្រក, ការអប់រំកូន និងការថែរក្សា សុខភាពគ្រួសារ ក្នុងខណៈពេលដែលប្តីទោរទន់លៃលក ធនធានសម្រាប់កន្លែងផ្សេងទៀត ។ ជាទូទៅ នៅក្នុង សង្គមនានាស្ត្រីគឺជាអ្នកទុកដាក់ ការទទួលស្គាល់ច្រើនឡើងថា ឪពុកជាច្រើន មួយជាមួយប្រពន្ធ អំពីរបៀបចំណាយ បុរសជា អ្នកទុកដាក់ថវិកាគ្រួសារច្រើនជាងស្ត្រី សូម្បី លុយកាក់គ្រួសារក៏ដោយ ។ ដូចនេះវា កំពុងតែក្លាយជា ត្រូវការរៀនបែងចែកអំណាចដែលសម្រេចចិត្តធ្វើអ្វី ប្រាក់ចំណូលរបស់គ្រួសារ ។



ការងារគ្រួសារដែលមិនមាន ការសំអាតផ្ទះ ចំអិនម្ហូបអាហារ ប្រាក់បៀវត្សន៍ភាគច្រើន រួមមានទាំង និង ការថែរក្សាគ្រួសារ ត្រូវបាន អនុវត្តន៍ដោយស្ត្រី និងក្មេងស្រី ទោះបីជាបុរស និង ក្មេងប្រុសចាប់ផ្តើមអនុវត្តភារៈ កិច្ចគ្រួសារច្រើនជាងពីមុន ជាពិសេស ប្រសិនបើពួកគេបានសិក្សារៀនសូត្រនោះ ។ នៅទូទាំងពិភព លោក បើទោះបីជាស្ត្រី និងក្មេងស្រីបន្តការងារដែលមានរយៈពេលយូជាងបុរសក៏ដោយ ។ ជួនកាលបញ្ហានេះ មានន័យថា ពួកនាងបាត់បង់សុខភាព ពីព្រោះមិនបានសំរាកគ្រប់គ្រាន់ ។ មានន័យថា ស្ត្រី និងក្មេងស្រីមានពេល តិចជាងសម្រាប់ការនៅជាមួយអ្នកដទៃក្នុងសង្គម និងការបណ្តុះបណ្តាល ។ លើសពីនេះទៀត ការចែករំលែក ស្មើគ្នានៃការទទួលខុសត្រូវក្នុងគ្រួសារ រវាងបុរសនិងស្ត្រីគឺជាលក្ខខ័ណ្ឌដ៏សំខាន់សម្រាប់សមភាពដែលសំរេចបានរវាងបុរស និងស្ត្រីនៅឯការងារ និងក្នុងការរស់នៅ ។

## ២.១៣ ការតំណាងក្នុងដំណើរការនៃការសំរេចចិត្តធ្វើអ្វីមួយ

ជាទូទៅស្ត្រីមិនមែនជាមនុស្សដែលមានអំណាចពេញទំហឹងនៅក្នុងកម្រិតដំណើរការនៃការសំរេចចិត្តធ្វើអ្វីមួយ ក្នុងសហគមន៍នានា អង្គការ និង ក្រុមនយោបាយទេ ស្ត្រីតែងតែត្រូវបានហាមប្រាមពីដំណើរការដែលធ្វើដោយ ការសំរេចចិត្តជាផ្លូវការនិង មិនផ្លូវការ ។ ការកំណត់នៃ សមត្ថភាពរបស់ស្ត្រីនេះ បញ្ហានានា ដែលស្ត្រីព្រួយបារម្ភតែខ្លួនឯង និងកូន ។ ប្រើប្រាស់មូលនិធិសហគមន៍ក្នុង គ្លីនិកសុខភាព ផ្លូវថ្នល់, ទំនាក់ទំនងតែងត្រូវបានគេ ស្ត្រី ។ ចំពោះកិរិតមូលដ្ឋាន ក្រុមស្ត្រីនៅតាមភូមិ ត្រូវបាននិយាយក្នុងកិច្ចការសាធារណៈនិងក្នុង សហគមន៍អំពី ឧទាហរណ៍ ការសំរេចចិត្ត ថាតើត្រូវ មូលដ្ឋាន មួយ សម្រាប់អាគារសិក្សា, ប្រព័ន្ធទឹកស្អាត ឬ ការផ្គត់ផ្គង់អគ្គិសនី ឬ សំរេចចិត្តដោយគ្មានការចូលរួមពាក់ពន្ធ័ពី ស្ត្រីតែងតែត្រូវបានគេរៀបចំក្នុងគណកម្មការស្ត្រី ឬ



នោពេលដែលក្រុមស្ត្រីទាំងនោះ ចង់អោយមានការណែនាំសុខមាលភាពតែម្យ៉ាង ។នាឆ្នាំថ្មីៗនេះមានការកើតឡើងនូវការផ្លាស់ប្តូរចំពោះតួនាទីដែលមានសមត្ថភាពច្រើនឡើងសំរាប់អង្គការទាំងនេះ ក្នុងបណ្តាប្រទេសជាច្រើន ។ការផ្តល់អំណាចបញ្ចេញមតិបន្ថែមដល់ស្ត្រី ក្នុងអង្គការធ្វើការសំរេចចិត្តជាផ្លូវការបន្តអោយមានការខិតខំអស់ពីសមត្ថភាពជាការប្រឈមមុខមួយ ក្នុងផ្នែកការងារគ្រាប់យ៉ាងក្នុងពិភពលោក ។

ឧទាហរណ៍ការតំណាង របស់ពួកគេនៅក្នុងចំនួនក្រុមប្រឹក្សាភូមិគឺកម្រខ្ពស់ជាងបីនាក់ណាស់ហើយជារឿយៗបើតាមគេប្រមើលគឺតិចជាងនេះផង ។ នៅតាមសាលារៀនក៏អញ្ចឹងដែរស្ត្រីបង្កើតបានជាគ្រូបង្រៀនមួយភាគធំ ប៉ុន្តែពួកនាងកម្រត្រូវបានគេប្រទះឃើញធ្វើជានាយកសាលាឬប្រធានរដ្ឋបាលក្នុងតំបន់ ។ ស្ថានភាពនេះត្រូវបានឆ្លុះបង្ហាញចំពោះកំរិតថ្នាក់ជាតិ ដែលស្ត្រីបង្កើតជាក្រុមភាគ នៅក្នុងរដ្ឋបាលកំរិតខ្ពស់ និងចរនាសម្ពន្ធ័នយោបាយ ។

ការកំណត់សេរីភាពរបស់ស្ត្រី ក្នុងការដើរតួនាទីស្មើគ្នា សម្រាប់ដំណើរការសម្រេចចិត្តត្រូវបានគេស្គាល់ថា គឺ ឈឺចាប់ដល់ស្ត្រី និងកូនជាញឹកញាប់ ។ សម្រាប់ហេតុផលនេះ ការអភិវឌ្ឍន៍ និងអង្គការស្ត្រីជាច្រើនគាំទ្រសំរាប់ផ្លាស់ប្តូរវិស័យនេះ ។

# ៣. គោលការណ៍និងយុទ្ធសាស្ត្រដើម្បីជំរុញអោយមានសមភាពនៃយេនឌ័រនៅក្នុងកម្មវិធីប្រឆាំងពលកម្មកុមារ

## ៣.១ គោលការណ៍សំខាន់ៗ សំរាប់ការជំរុញអោយមានសមភាពនៃយេនឌ័រ

**៣.១.១ ដើម្បីទទួលបាននូវសមភាពនៃយេនឌ័រ គឺមិនត្រឹមតែជាការព្រួយបារម្ភណ៍របស់ស្ត្រីតែប៉ុណ្ណោះទេ ប៉ុន្តែជា ការទទួលខុសត្រូវសំរាប់មនុស្សទាំងអស់នៅក្នុងសង្គម ។**



កាលពីអតីតកាលក្រុមអ្នកតស៊ូមតិភាគច្រើនដើម្បីការជំរុញអោយមានភាពស្មើគ្នានៃយេនឌ័រគឺជាស្ត្រី ។ ដូច្នេះហើយ ជួនកាលគេគិតថា ប្រធានបទនេះមានការព្រួយបារម្ភណ៍ទៅលើតែស្ត្រី ហើយមិនមានការព្រួយបារម្ភចំពោះបុរស ។ ទោះបីជាយ៉ាងនេះក៏ដោយ គំនិតនេះកំពុងតែបាត់រូបរាង នាពេលបច្ចុប្បន្ននេះដែរ ។ ក្នុងនេះដែរ មានការបង្កើនឡើងនូវការព្រមព្រៀងភាពស្មើគ្នារវាងយេនឌ័រ គឺទាំងការងាររបស់ស្ត្រី និងការងាររបស់បុរស គឺជាការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូបនៅក្នុងសង្គម និងតំរូវអោយមានការរួមចំណែក និងផ្តល់ចំណេះ ដឹងពត៌មានពីទាំងស្ត្រី និងបុរស ។

៣.១.២ ការជំរុញអោយមានភាពស្មើគ្នានៃយេនឌ័រ និងទទួលបានអត្ថប្រយោជន៍នៅក្នុងសង្គម

ការផ្តល់អំណាចអោយស្ត្រី និង កុមារីឆ្ពោះទៅកាន់ការចូលរួមយ៉ាងច្រើនក្នុងកាអភិវឌ្ឍន៍ មានន័យថា ធ្វើការ ឆ្ពោះទៅរកតុល្យភាពនិងអំណាចស្មើគ្នាដែលទាក់ទិនរវាងភេទ។ ជួនកាលភាពភ័យខ្លាចដែលស្ថិតនៅជំរុញមុខដំណែងឈានមុខគេ ចំពោះស្ត្រីឱ្យទៅមុខមានន័យថាការងារខ្លះត្រូវយកចេញពីបុរស ។ ទោះជាយ៉ាងណាក៏ដោយ ការជំរុញអោយមានភាពស្មើគ្នានៃយេនឌ័រមិនបង្កប់ន័យដែលផ្តល់អំណាចជាច្រើនទៀតអោយទៅស្ត្រីហើយយកអំណាចពីបុរសនោះទេ ។ ការជំរុញអោយមានភាពស្មើគ្នារវាងស្ត្រី និងបុរស គឺផ្តល់អំណាចទាំងបុរស ទាំងស្ត្រី ។ វាអនុញ្ញាតិ ទាំងបុរសទាំងស្ត្រីដើម្បីចូលរួមយ៉ាងពេញលេញ ក្នុងសង្គមនិងជីវិតសេដ្ឋកិច្ចហើយឆ្ពោះទៅរកស្ថានភាពឈ្នះឈ្នះសំរាប់ទាំង បុរសនិងស្ត្រី ។



*"Power over"* ពោលទៅលើស្ថានភាពដែលនៅក្រោមបង្គាប់លើដៃម្ខាង និងការគ្របសង្កត់នៅដៃម្ខាង ទៀត គឺមិនយុត្តិធម៌ និងធ្វើអោយខូចប្រយោជន៏ទៅលើការអភិវឌ្ឍន៍ ដោយសារតែការផ្លាស់ប្តូរ មិនស្មើគ្នា ដែលវាតម្រូវ ។ ស្ថានភាពឈ្នះឈ្នះគឺត្រូវបង្កើតដោយការគាំពារ ។

*Power- to* : ប្រភេទនៃអំណាចដែលប្រកបដោយប្រឌិតញាណនិងដែលបង្កលក្ខណៈងាយស្រួលអាចអោយធ្វើអ្វីមួយទៅបាន ការអោយ អំណាចរបស់ប្រជាជន

*Power-with* : អំណាចជាក្រុម អំណាចពេញលេញ គឺធំជាង ការបូកបញ្ចូលគ្នានៃផ្នែករបស់វា

*Power-within* : ភាពរឹងមាំខាងផ្លូវចិត្ត ជំនឿទុកចិត្តលើខ្លួនឯង

៣.១.៣ភាពស្មើគ្នានៃយេនឌ័រត្រូវការការឆ្លើយតបតាមគ្រប់កម្មវិធីអភិវឌ្ឍន៍ទាំងអស់ និងគ្រប់ដំណាក់នៃវដ្តកម្មវិធី



**ជួនកាលគេគិតថា ការជំរុញអោយមានភាពស្មើគ្នា រវាងបុរស និង ស្ត្រី ឱ្យមានទំនាក់ទំនងគ្នា នៅក្នុងវិស័យដូចជាការអប់រំសុខភាព និង សុខមាលភាព និង ការយកចិត្តទុកដាក់ផ្សេងៗទៀតនិងការងារផ្អែកលើសេវាកម្ម ហើយវាមិននៅក្នុងវិស័យដូចជាគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ច វិស្វកម្ម ការសាងសង់ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៍ក៏ធ្វើការសំរេចចិត្តក្នុងគោលនយោបាយ ។ ឧទាហរណ៍ផ្សេងទៀតគេគិតថា ភាពស្មើគ្នានៃយេនឌ័រ និងទទួលបានជោគជ័យប្រសិនបើការងារមួយតូចតាចនិងការងារពិសេសត្រូវបានគេធ្វើឡើងយ៉ាងពិសេសចំពោះ ស្ត្រីនិងក្មេងស្រី ។**

គំនិតទាំងនេះមិនបានឆ្ពោះទៅរកដំណើរការនៅក្នុងការអនុវត្តន៍ព្រោះថាភាពមិនស្មើគ្នានៃ យ៉េនឌ័របានជ្រួតជ្រាបនៅក្នុងសង្គមសេដ្ឋកិច្ចវប្បធម៌និងនយោបាយសង្គម ។ភាពស្មើគ្នានៃយ៉េនឌ័រជាបញ្ហាមួយដែលត្រូវការដោះស្រាយនៅក្នុងកម្មវិធីអភិវឌ្ឍន៍ទាំងអស់គ្រប់ដំណាក់នៃវដ្តកម្មវិធីនិងនៅក្នុងការធ្វើផែនការ និងការអនុវត្តន៍ ការត្រួតពិនិត្យ និងដំណាក់ការនៃការវាយតំលៃ ។

### ៣.១.៤ ត្រូវការវិធានការជាក់លាក់នៃយ៉េនឌ័រក្នុងករណីមានភាពមិនស្មើគ្នា



ទំនាក់ទំនងរវាងការជំរុញអោយមានសមភាពនៃយ៉េនឌ័រ និងការរីកចំរើនរបស់ស្ត្រីគឺមិនមែនតែងតែគេយល់ ថាល្អនោះទេ ហើយជួនកាលត្រូវគេគិតថា ទាំងនេះគឺជាបញ្ហាពីរផ្សេងពីគ្នា។ នេះគឺមិនមែនជាករណីទេ ។ ការរីកចំរើនរបស់ស្ត្រី និងកុមារី គឺជាយុទ្ធសាស្ត្រដ៏ចាំបាច់មួយនៅពេលដែលពួកគេនៅក្នុងមុខតំណែងដែលចាញ់ ប្រៀបបើធៀបទៅនឹងបុរស និងកុមារ ។ តាមភាពមិនស្មើគ្នានាពេលបច្ចុប្បន្ននេះជារឿយៗគឺជាបញ្ហាចំណាស់ ការប្រព្រឹត្តិស្មើគ្នារបស់បុរសនិងស្ត្រីពីពេលនេះទៅជារឿយៗគឺមិនទាន់គ្រប់គ្រាន់ទេពីព្រោះភាពមិនស្មើគ្នាដែលមានពីមុនអាចនៅសេសសល់ឬក៏ថែមទាំងអាចក្លាយទៅជាច្រើនជាងមុនផង។ វិធានការដ៏ជាក់លាក់នៃយ៉េនឌ័រ គឺជាធម្មតាគេត្រូវការដើម្បីកែឡើងវិញនូវអតុល្យភាពដែលមានពីមុនរវាងមុខតំណែងរបស់បុរស និងស្ត្រី រហូតទាល់តែស្ត្រី អាចចូលរួម និងទទួលផលប្រយោជន៍ពីការអភិវឌ្ឍន៍លើជំហារស្មើគ្នាជាមួយនិងបុរស ។




តាមពិតទៅប្រសិនបើក្មេងប្រុស និងបុរសត្រូវបានគេចាត់ទុកថាមានប្រៀបតិចជាង បើប្រៀបធៀបទៅ ក្មេងស្រី និងស្ត្រី វិធានការជាក់លាក់នៃយ៉េនឌ័រ ចាំបាច់យកមកអនុវត្តដើម្បីធ្វើអោយប្រសើរឡើងនូវតួនាទី របស់ពួកគេ ។ លើសពីនេះ ចូរកត់សំគាល់ថា វិធានការជាក់លាក់នៃយ៉េនឌ័រ អាចទាក់ទងទៅនឹងការងារ របស់ស្ត្រី បុរស ឬក៏ទាំងពីរ។ ឧទាហរណ៍បុរសដែលជាអ្នកដឹកនាំ ត្រូវលើកកំពស់ការយល់ដឹងនៃយ៉េនឌ័រ ដើម្បីធ្វើ អោយមានការប្តេជ្ញាចិត្តដើម្បីធ្វើអោយប្រសើរឡើងនូវតួនាទីរបស់ក្មេងស្រី និងស្ត្រីដែលមានការចាញ់ប្រៀប ។

### ៣.១.៥ ដោះស្រាយការអនុវត្តន៍ និង សេចក្តីត្រូវការយុទ្ធសាស្ត្រនៃយ៉េនឌ័រ

តួនាទីរបស់បុរស និងស្ត្រីនៅក្នុងសង្គមគ្រួសារកន្លែងការងារ និងស្ថាប័ននានា ជាទូទៅមានលក្ខណៈផ្សេងៗ ពីគ្នា ។ ដូច្នោះហើយ សេចក្តីត្រូវការរបស់ពួកគេ និងមានភាពផ្សេងៗពីគ្នាជាច្រើន ។ ប្រភេទសេចក្តីត្រូវ ការទាំងពីរធម្មតាត្រូវបានគេរកឃើញ ដើម្បីអភិវឌ្ឍន៍ផែនយុទ្ធសាស្ត្រ ដែលជំរុញអោយមានភាពស្មើគ្នា រវាង បុរស និងស្ត្រី ។



- តំរូវការជាក់ស្តែងសំដៅទៅលើតំរូវការពាក់ពន្ធ័និងការចិញ្ចឹមជីវិតជាមូលដ្ឋាន ដូចជា អាហារទឹកជំរកប្រាក់ចំណូល សំលៀកបំពាក់និងការថែទាំសុខភាព។ តំរូវការទាំងនេះកើតឡើងពីលកខណ្ឌពិតប្រាកដដែលមនុស្សទទួលបទពិសោធន៍ ដោយសារតួនាទីយ៉េនឌ័របានតែងតាំងឱ្យពួកគេនៅក្នុងសង្គមនិងកង្វល់ពីភាពមិនគ្រប់គ្រាន់ក្នុងការរស់នៅនិងលក្ខខណ្ឌការងារ។ ចំពោះគ្រួសារក្រីក្រជារឿយៗតំរូវការទាំងនេះផ្សារភ្ជាប់ទៅនិងយុទ្ធសាស្ត្រដើម្បីរស់រាន។
ស្ត្រីនិងក្មេងស្រីនៅពេលខ្លួនជាអ្នកថែទាំផ្ទះយ៉ាងសំខាន់និងជាអ្នកផ្តល់តំរូវការជា មូលដ្ឋានដល់គ្រួសារ មានតំរូវការជាក់ស្តែងជាច្រើន ។ទោះជាយ៉ាងពាក់ដោយការដោះស្រាយតែតំរូវការជាក់ស្តែងតែមួយមុខអាចនាំឱ្យមានស្ថានភាពចាញ់ប្រៀបនៃភេទណាមួយជារៀងរហូតជាធម្មតាគឺស្ត្រីនិងក្មេងស្រីនៅក្នុងសង្គមរបស់ខ្លួន ។គេត្រូវតែដោះស្រាយតំរូវការជាក់ស្តែង ប៉ុន្តែសមភាពនៃយ៉េនឌ័រនឹងមិនបានជោគជ័យដោយគ្មានការដោះស្រាយតំរូវការយុទ្ធសាស្ត្រទេ។

- តំរូវការយុទ្ធសាស្ត្រសំដៅលើតំរូវការពាក់ពន្ធ័និងការចូលរួមដោយមានន័យនិងស្មើភាពពីក្មេងប្រុស ក្មេងស្រី បុរស និងស្ត្រីក្នុងគ្រួសាររបស់ខ្លួនក៏ដូចជាសហគមន៍។ ជាស្ត្រី និងក្មេងស្រី ជាធម្មតាស្ថិតនៅក្នុងស្ថានភាពចំណុះ ការបើប្រៀបធៀបនិងបុរសនិងក្មេងប្រុសនៅក្នុងសង្គមរបស់ខ្លួន។ តំរូវការយុទ្ធសាស្ត្រផ្លាស់ប្តូរស្របតាមបរិបទ នយោបាយសង្គមនិងសេដ្ឋកិច្ចដែលបានបង្កើតឡើង។ តំរូវការយុទ្ធសាស្ត្រផ្តោតលើបញ្ហាសមភាពដូចជាការបង្ក លក្ខណៈងាយស្រួលឱ្យស្ត្រីទទួលបានឱកាសធ្វើការងារ ការបណ្តុះបណ្តាល ការចែកចាយរំលែកការទទួលខុសត្រូវ ក្នុងគ្រួសារស្មើគ្នា ការទទួលប្រាក់កំរៃស្មើគ្នាចំពោះការងារណាដែលមានតម្លៃស្មើគ្នាសិទ្ធិទទួលបានដីធ្លីនិងទ្រព្យ សម្បត្តិឯទៀតកិច្ចការពារពីការបៀតបៀនផ្លូវភេទនៅកន្លែងការងារនិងអំពើហឹង្សាក្នុងគ្រួសារនិងទទួលបានសេរីភាពក្នុងការជ្រើសរើសលើការមានគភ៌ ឧទាហរណ៏នៃតំរូវការយុទ្ធសាស្ត្រសំរាប់បុរសនិងក្មេងប្រុស ពាក់ពន្ធ័និងការបង្កលក្ខណៈងាយស្រួលដល់ពួកគេឱ្យ មាន " តួនាទីថែទាំ " ក្នុងគ្រួសារនិងសង្គមហើយស្វែងរកមធ្យោបាយជាវិជ្ជមានដើម្បីទប់ស្កាត់ជម្ងឺវិបត្តិផ្លូវចិត្ត និងជៀសវាងអំពើហឹង្សា។ ការដោះស្រាយ តំរូវការយុទ្ធសាស្ត្រពាក់ពន្ធ័និងដំណើរការមួយជាជំហាន១និងយឺតយូរលើការផ្លាស់ប្តូរឥរិយាបទនិងការអនុវត្តន៏ក្នុងសង្គម។



## ៣.២ ការបញ្ជ្រាបចូលនៃយ៉េនឌ័រៈ និង ឧបករណ៍សំខាន់ៗ

យុទ្ធសាស្ត្រចំបងសំរាប់ការជំរុញសមភាពនៃយ៉េនឌ័រ គឺ ការបញ្ជ្រាបចូលនៃយ៉េនឌ័រៈ និយមន័យខាងក្រោម គឺត្រូវបានយល់ព្រមដោយអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ ១៩៩៧ ។

- ការបញ្ជ្រាបទស្សនៈនៃយ៉េនឌ័រ គឺជាដំណើរការប៉ាន់ប្រមាណទៅលើការជំពាក់ទាក់ទិនរបស់បុរស និងស្ត្រីនៃសកម្មភាពគម្រោងនានា រួមមានច្បាប់ គោលនយោបាយ រឺកម្មវិធីនៅក្នុងតំបន់នានា និងនៅ គ្រប់កំរិតទាំងអស់ ។
- យុទ្ធសាស្ត្រក្នុងការបង្កើតកង្វល់ និងបទពសោធន៍របស់ស្ត្រីព្រមទាំងបុរស ដែលជាផ្នែកបរិស្ថាននៃគំរោងកិច្ច ប្រតិបត្តិការត្រួតពិនិត្យ ហើយនិងការវាយតំលៃគោលការណ៏ និងកម្មវិធីនយោបាយទាំងអស់នៃសេដ្ឋកិច្ច និងវិស័យសង្គមដើម្បីនាំអោយស្ត្រី និងបុរសមានផលប្រយោជន៍ស្មើគ្នាហើយភាពមិនស្មើគ្នា គឺមិនចិតថេរ ទៀតទេ ។
- គោលដៅចុងក្រោយនៃការបញ្ជ្រាប គឺ ដើម្បីសំរេចអោយបានទូវសមភាពនៃយ៉េនឌ័រ [7]

មានការខ្វះខាតនៃការយល់ដឹង នូវអ្វីដែលជាការបញ្ជ្រាបអត្ថន័យនៅក្នុងការអនុវត្តន៍ ហើយអ្វីដែល ត្រូវការតំរូវដើម្បីអនុវត្តន៏នូវគំនិតនេះ ។ការបញ្ជ្រាបមិនត្រឹមតែទាក់ទងទៅនឹងសមាហរណកម្មនៃកង្វល់ខាង យ៉េនឌ័រក្នុងទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍការធ្វើផែនការដើម្បីធានាថាស្ត្រីនិងបុរសអាចចូលរួមគ្រប់ដំណើរការអភិវឌ្ឍន៏ និងទទួលប្រយោជន៏ស្មើគ្នារួមបញ្ចូលទាំងអន្តរាគមន៍ដ៏ជាក់លាក់របស់យ៉េនឌ័រប្រសិនបើមានអតុល្យភាព ហើយនិងភាពមិនស្មើគ្នាក្នុងការបញ្ចេញយោបល់ ។

- ការបញ្ជៀតយ៉េនឌ័រ គឺ ជាយុទ្ធសាស្ត្រជាស្ថាប័នមួយ ក្នុងបំណងផ្តល់នូវឱកាស និងសិទ្ធិស្មើ១គ្នា ដល់បុរស និងស្ត្រីជាអ្នកទទួលផលប្រយោជន៏ ជាអ្នកចូលរួម និងជាអ្នកធ្វើការសំរេចចិត្ត។ ការបញ្ជ្រាបយ៉េនឌ័រសំដៅ លើដំណើរការនេះ
  - ការធ្វើសមាហរណកម្មនៃសមភាពយ៉េនឌ័រទៅក្នុងដំណើរការរៀបចំគោលនយោបាយ កម្មវិធី គំរោងយន្តការស្ថាប័ន និងថវិកា
  - ការដោះស្រាយវិសមភាពនៃយ៉េនឌ័រតាមរយៈវិធានការជាក់លាក់នៃយ៉េនឌ័រសំរាប់ស្ត្រី បុរសឬទាំងពីភេទ

[7] ក្រុមព្រឹក្សាសង្គម និងសេដ្ឋកិច្ចអង្គកាសហប្រជាជាតិ (ECOSOC) បានបញ្ចប់ការយល់ស្រប E/1997/L.30, p.2

ការបញ្ជ្រៀបយ៉េនដ័រត្រូវការធ្វើឡើងនៅគ្រប់ដំណាក់កាលរៀបចំគោលនយោបាយ កម្មវិធី និងកិរិតគំរោងនៃវដ្ត នៃកម្មវិធី (រៀបចំ ធ្វើផែនការ អនុវត្ត តាមដាន និងវាយតម្លៃ ហើយគ្របដណ្តប់លើគ្រប់វិស័យសកម្មភាពតាម រយមធ្យោបាយទាំងអស់។ គេត្រូវការសកម្មភាពលើ :

- ការអនុវត្តន៏នូវការវិភាគយ៉េនដ័រ ដោយមានទស្សនៈមួយដែលបង្ហាញភាពមិនស្មើគ្នារវាងបុរសនិងស្ត្រីដែល ត្រូវដោះស្រាយ។

- ផ្តល់ឱកាសស្មើគ្នដល់ជនគ្រប់រូបហើយអនុវត្តវិធានការជាក់លាក់នៃយ៉េនដ័រនៅពេលមានវិសមភាពដោយយក ស្ត្រីនិងក្មេងស្រីជាគោលដៅដោយឡែក បុរសឬក្មេងប្រុសជាគោលដៅដោយឡែក ឬក្មេងប្រុសនិងក្មេងស្រី ស្ត្រីនិងបុរសទាំងអស់គ្នាជាមួយទស្សនៈមួយដើម្បីបំបាត់វិសមភាពយ៉េនដ័រនិងការរើសអើងដែលកើតឡើង
- ការចាប់ផ្តើមដំណើរការក្នុង ការផ្លាស់ប្តូរស្ថាប័ន ក្នុងនិតិវិធី មានការសហការណ៏ ជាមួយ ផ្នែកយ៉េនដ័រ នៅក្នុងការធ្វើផែនការ ការធ្វើកម្មវិធី ការអនុវត្តន៏ ការត្រួតពិនិត្យ ការវាយតំលៃ កម្មវិធី និងសកម្មភាព និងនៅក្នុងដំណើរការនៃស្ថាប័ន ។

- **ការផ្តល់សំលេងគាំទ្រចំពោះ កុមារី និង ស្ត្រី** បុរសនិងក្មេងប្រុសដោយបង្កើតនូវការចូលរួមរបស់ពួកគេ នៅកម្មវិធីផ្សេង ៗ អង្គការនានា និងនៅក្នុងការធ្វើការសំរេចចិត្ត ជាមួយទស្សនៈមួយ ដើម្បីធានាថា ចំណាប់អារម្មណ៏ របស់ពួកគេនឹងទស្សនវិស័យ នឹងត្រូវបានគេ ពិចារណានៅក្នុងការងារអភិវឌ្ឍន៏ ។
- ការអនុវត្តន៏គំរោងថវិការ និងសវនកម្ម (ការជំរះបញ្ជី យ៉េនដ័រដោយមានការចូលរួម

### ៣.២.១ ការវិភាគបញ្ហាយ៉េនដ័រ

ការវិភាគបញ្ហាយ៉េនដ័រ គឺជាឧបករណ៏ដើម្បីវិភាគភាពផ្សេងគ្នា និងទំនាក់ទំនងរវាងកុមារី កុមារា បុរស និងស្ត្រី ។ ការវិភាគនេះ រួមមានៈ

- ប្រមូលទិន្នន័យទាំងអស់ដែលមិនបានបញ្ចូល ឧទាហរណ៏ ការធ្វើអោយខុសច្បាប់ដោយភេទ និងការចែកលំដាប់ថ្នាក់សំខាន់ៗដូចជា អាយុ, ប្រាក់, ចំណូល, ជាតិសាសន៏, សញ្ជាតិ ឬសាសនា ។
- បញ្ជាក់បង្ហាញភាពផ្សេងគ្នានៃយ៉េនដ័រ នៅឯកន្លែងធ្វើការ និងនៅក្នុងការរស់នៅ និងក៏ដូចជា ការបែងចែកពលកម្មនិងការទទួលបាន និងគ្រប់គ្រងលើធនធាន និងអត្ថប្រយោជន៏ ។
- ដោយយល់ចំពោះតំរូវការរបស់កុមារី ស្ត្រី បុរស និងបញ្ហា និង ឱកាសនៅក្នុងទំនាក់ទំនងតំរូវការចំណេះដឹង និងជំនាញនានា ដែលត្រូវការលក្ខខ័ណ្ឌការងារការ ការពារសង្គម ការទទួលខុសត្រូវចំពោះគ្រួសារ ការធ្វើការសំរេចចិត្តក្នុងនយោបាយនិងសេដ្ឋកិច្ច ។
- រកអោយឃើញបញ្ហានិងឱកាសនៅក្នុងបរិស្ថានដ៏ធំមួយ (ច្បាប់, ឥរិយាបទ ហើយនិង

- ពិនិត្យជាថ្មីនូវសមត្ថភាព របស់ស្ថាប័ននិងយន្តការដែលមានស្រាប់ដើម្បីទទួលបានភាពស្មើរទាំងកុមារីកុមារា ស្ត្រី និងបុរស ហើយជំរុញអោយមានភាពស្មើគ្នានៃយ៉េនដ័រ ។



## ៣.២.២ សកម្មភាពច្បាស់លាស់នៃយេនឌ័រ

គោលនយោបាយយ៉ាងច្បាស់នៃយេនឌ័រ វិធានការ រឺសកម្មភាពត្រូវការនៅពេលណាដែលកុមារី រឺក៏ស្រ្តី ជាពិសេស នៅក្នុងតួនាទី ដែលចាញ់ប្រៀប ។ សកម្មភាពបញ្ជាក់នៃយេនឌ័រ តម្រូវអោយមានការចាប់ អារម្មណ៍លើចំណែកនៃការពេញចិត្ត ទំរង់និង ដំណើរការ ( អ្វី និង យ៉ាងដូចម្តេច ។

ក្នុងចំណែកនៃការពេញចិត្ត គ្រប់វិស័យនិងគ្រប់បញ្ហាដែលត្រូវដោះស្រាយមានភាពផ្សេងគ្នាពីប្រទេសមួយ ទៅប្រទេសមួយ ។ ទោះបីយ៉ាងនេះក៏ដោយកម្មវិធី និងវិធានការជាញឹកញាយត្រូវបានគេត្រូវការក្នុង:



■ វិស័យនានា ឧស្សាហកម្ម និងមុខរបរដែលកុមារី និងស្ត្រីជាច្រើនដែលបានគេប្រទះឃើញ ឧទាហរណ៏ ការធ្វើ កសិកម្ម និងការធ្វើការផ្នែកមិនរៀបរយណាមួយ ការងារបំរើតាមផ្ទះ ការងារក្នុងប្រទេស ការងារជាស្ត្រីរកស៊ីផ្លូវភេទ និងការងារតាមរោងចក្រដេរស្បែកជើងនិង វាយនភ័ណ្ឌ ។



■ វិស័យឯកជន ដែលជាកន្លែងកុមារី និងស្ត្រី គឺអវត្តមានយ៉ាងជាក់ស្តែង ( ឧស្សាហកម្មដែលពេញដោយ បុរសធ្វើការ ដូចជា វិស្វកម្ម យន្តកម្ម កុំព្យូទ័រ បច្ចេកវិទ្យា ឬក៏ការងារជាច្រើនទៀតនៅគ្រប់កំរិតនៃការងារប្រតិបត្តិ ។

■ បញ្ហាដែលកម្មការនី និងកម្មករកុមារព្រួយបារម្ភជាពិសេសគឺ( តួនាទីក្នុងការបង្កើតកូន និងភាពទទួលខុសត្រូវ ការមានផ្ទៃពោះនៅវ័យជំទង់ ការគាំពារមាតានិងទារក អំពើហឹង្សានៅតាមផ្ទះ នៅក្នុងកន្លែងការងារដូចជា ការយាយីផ្លូវភេទ ។



នៅក្នុងចំណែកនៃទំរង់ និង ដំណើរការ វិធានការ ជាក់ច្បាស់របស់យេនឌ័រ អាចរួមបញ្ចូល រឺក៏មានការបញ្ចូល គ្មានទូវសេវាកម្ម ដូចខាងក្រោម :

■ សកម្មភាពស្របរឺក៏សកម្មភាពវិជ្ជមាន បានទៅដល់វិធាន ការបណ្ដោះអាសន្នសំខាន់ត្រូវបានគេ រៀបចំដើម្បីលុបបំបាត់ លទ្ធផល ដោយផ្ទាល់ និងដោយ ប្រយោលនាបច្ចុប្បន្ននៃការរើសអើង ។ ជាទូទៅវិធានការនេះ មានការបង្កើតគោលដៅរឺក៏កូតា សំរាប់ការ ចូលរួមរបស់ក្មេងស្រី ស្ត្រី ក្មេងប្រុសនិងបុរសនៅក្នុងកម្មវិធីផ្សេងៗ សំរាប់អំឡុងពេលដែលបានផ្តល់ជូន ។ សកម្មភាពវិជ្ជមាន ត្រូវបានគេដឹងផង ដែរថា ជាការរើសអើងភេទដ៏ ជាក់លាក់ ។ ជួនកាលការប្រើមធ្យោបាយសកម្មភាពនេះ នាំទៅរកកិច្ចពិភាក្សា រឺកញ្លែកយ៉ាងក្តៅគគុក ។ ទោះបីយ៉ាងណាក៏ដោយ សហគមន៍អន្តរជាតិ បានយល់ព្រមថា វិធានការសកម្មភាពវិជ្ជមាន គឺត្រូវគេធ្វើ យុត្តិកម្ម និងចាំបាច់ដើម្បីប្រយុទ្ធប្រឆាំង នឹងឥទ្ធិពលនៃការរើសអើងភេទពីមុន និងជួយអោយស្រ្តីដើម្បី សំរេចអោយមានសមភាពពិតប្រាកដនៅក្នុងទីផ្សារការងារ ។ វិធានការសកមភាពជាវិជ្ជមានគួរ :



- មានបំណងដើម្បីលុបបំបាត់ការរើសអើងភេទដែលចាញ់ប្រៀប ប៉ុន្តែមិនគួរបង្កើតការរើសអើងប្រឆាំង និងភេទដ៏ទៃទៀតទេ ។
- បញ្ជាក់បង្ហាញពីតំបន់ជាក់លាក់ដែលជាលទ្ធផលបច្ចុប្បន្ននៃការរើសអើងភេទពីមុន អាចត្រូវបានគេបង្ហាញថាបានបង្អាក់ការសប្បាយរីករាយនូវសិទ្ធិដែលមានស្រាប់ ។
- ជាវិធានការបណ្ដោះអាសន្នដើម្បីលុបបំបាត់លទ្ធផលនៃការរើសអើងភេទពីមុន ។ នៅពេលមានតុល្យភាពការវាស់វែង គួរតែបញ្ចប់ ។



- សកម្មភាពជាក់ច្បាស់របស់ស្ត្រី គឺការធ្វើអន្តរាគមន៍យ៉ាងច្បាស់លាស់ដោយផ្តោតគោលដៅចំពោះក្មេងស្រី និងស្ត្រីដែលនិងអាចត្រូវការជាចាំបាច់នៅពេលណាមានការកើតបទដ្ឋានវប្បធម៌និងបទដ្ឋានតំលៃពីការចូលរួមស្មើភាពគ្នារបស់ ស្ត្រីនៅក្នុងសកម្មភាពផ្សេងៗ ដែលទាក់ទងនិងភេទទាំងពីរ ។ សកម្មភាពជាក់ច្បាស់របស់ស្ត្រី និងត្រូវបានគេប្រើប្រាស់ផងដែរ ដើម្បីធ្វើអោយស្ត្រីឈានទៅដល់ការអភិវឌ្ឍន៍និងពង្រឹងតំលៃខ្លួនឯងដែលទទួលស្គាល់ពីសង្គម ។ដើម្បីរកអោយឃើញនូវបញ្ហានិងអភិវឌ្ឍរួមគ្នាដើម្បីយកជ័យជំនះលើបញ្ហាទាំងនោះ ។
- សកម្មភាពជាក់ច្បាស់របស់បុរស ក៏ត្រូវការចាំបាច់ដែរ ពីព្រោះថា ការដាក់ទុនទាំងបុរសទាំងស្ត្រីគឺសំខាន់ ណាស់ដើម្បីទទួលបានភាពស្មើគ្នានៃយេនឌ័រ ។ ដោយមានការលើកឡើងពីបុរស គឺសំខាន់ជាពិសេស បុរសតែងតែមានអំណាចជាប្តីជាឪពុក និងជាអ្នកធ្វើការសំរេចចិត្តដែលត្រូវគេលើកទឹកចិត្តនិងប្តេជ្ញាដើម្បីទទួលយកទំនួលខុសត្រូវចំពោះ ភាពស្មើគ្នានៃយេនឌ័រ ក្នុងភាពដៃគូរជាមួយស្ត្រី ។

## ៣.២.៣ ការផ្លាស់ប្តូរស្ថាប័ន



ភាពមិនស្មើគ្នានៃយេនឌ័រជាញឹកញាប់ណាស់ត្រូវបានគេបង្កើតនៅក្នុងដំណើរការអង្គភាពនានានិងយន្តការស្ថាប័ន ។ ដូច្នេះ ការផ្លាស់ស្ថាប័នត្រូវបានគេអំពាវនាវអោយមានគំរោងស្ថាប័នការងាររចនាសម្ព័ន្ធ និងវប្បធម៌ និតិវិធី និងដំណើរការដើម្បីបង្កើតបរិយាកាសរបស់អង្គការដែលដឹកនាំទៅនឹងការជំរុញអោយមានភាពស្មើគ្នានៃយេនឌ័រ ។ អង្គភាពការិយាធិបតេយ្យមានការតស៊ូចំពោះការផ្លាស់ប្តូរ និងជាញឹកញាយមានប្រតិកម្មពីសុភាវគតិប្រឆាំងនឹងការផ្លាស់ប្តូរឆ្ពោះទៅរកទំនាក់ទំនងសមភាពយេនឌ័រថែមទៀតដោយសារតែមានកង្វល់ដែលជាប់ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ ។ ទោះយ៉ាងនោះក៏ដោយការព្រមព្រៀងរួមកំពុងតែកើនឡើងដែល យេនឌ័រនិងបរិស្ថានដែលពោរពេញទៅដោយស្ត្រីនៅក្នុងអង្គភាពនានានិងដំណើរការស្ថាប័នធ្វើឱ្យអង្គភាពមានប្រសិទ្ធិភាពកាន់តែច្រើនឡើងៗ ។

ដំណើរការនៃការបញ្ច្រៀបយេនឌ័រ នៅក្នុងប្រទេស និង អង្គការ តែងតែមានជំហានដូចខាងក្រោម :

- ការទទួលនិងធានានូវឆន្ទៈនយោបាយជាក់លាក់ រដ្ឋត្រូវតែកំណត់អោយច្បាស់លាស់នូវសមភាពនៃយេនឌ័រ ដែល ជាជំហានមួយក្នុងចំណោមទិសដៅអភិវឌ្ឍន៍ ។ មានការជាប់ទាក់ទងគ្នាយ៉ាងខ្លាំងមួយរវាងឆន្ទៈ នយោបាយសំរាប់ការបញ្ច្រៀបយេនឌ័រនឹងចំណេះដឹងជាសាធារណៈនៃបញ្ហាសមភាពយេនឌ័រ ។ ការទទួល ខុសត្រូវសំរាប់អនុវត្តយុទ្ធសាស្ត្រ ការបញ្ច្រៀបគឺជាប្រព័ន្ធធំទូលាយហើយនៅកំរិតខ្ពស់បំផុតក្នុងស្ថាប័ន ។ គួរមានយន្តការទទួលខុសត្រូវគ្រប់គ្រាន់សំរាប់ដំណើរការត្រួតពិនិត្យ ។
- ការបង្កើតច្បាប់អោយមានឱកាសស្មើគ្នានិងច្បាប់ប្រឆាំងអំពើរើសអើងភេទ : ច្បាប់ស្មើសិទ្ធិគ្នាបំរើជាអ្នក ការពារប្រឆាំងនឹងការរើសអើងគឺមិនមែនចំនួនតិចតួចនៅក្នុងទីផ្សារការងារទេ ។ ច្បាប់នេះជាមូលដ្ឋានដ៏ចាំបាច់សំរាប់ការជំរុញអោយមានភាពស្មើគ្នា ។
- ការយល់ព្រមដែលបានថែងយ៉ាងជាក់លាក់ស្តីពីគោលនយោបាយសមភាពនៃយេនឌ័រ និងវិធានការ ហើយ និងការបង្កើតកម្មវិធីថវិកា និងនិតិវិធីមានគណនីភាពសំរាប់ជំរុញសមត្ថភាព រវាងបុរស និងស្ត្រី ដូចជាការកំណត់គោលដៅពេលវេលាដ៏ជាក់លាក់ការបង្កើតយន្តការស្ថាប័នការបង្កើតគំរោង ថវិកានៃយេនឌ័រ និង សវនកម្ម ( ការជំរះបញ្ជី នៃយេនឌ័រ ។

ចំពោះដំណើរការស្ថាប័នវាមានសារៈសំខាន់ណាស់ដើម្បី :

- ផ្តល់នូវការបង្កើនចំណេះដឹងនិងបណ្តុះបណ្តាល ទៅដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់
- ធ្វើអោយបុគ្គលិកទាំងអស់មានគណនីភាព និងកសាងសមត្ថភាពរបស់ពួកគេ ដើម្បីអោយក្លាយទៅជា ភ្នាក់ងារប្រតិបត្តិឆ្ពោះទៅរកការសំរេចឱ្យបានសមភាពយេនឌ័រ នៅកន្លែងធ្វើការ ។
- បង្កើតយន្តការដាច់ដោយឡែកដើម្បីអភិវឌ្ឍន៍ណែនាំផ្លូវនិងត្រួតពិនិត្យមើលផលប៉ះពាល់ចំពោះការបញ្ច្រាប យេនឌ័រ និងសកម្មភាពជាក់លាក់នៃយេនឌ័រ ។

សកម្មភាពទាំងនោះត្រូវបានប្រកាន់យកដោយប្រទេសមួយចំនួនពាសពេញពិភពលោកដោយរួមបញ្ចូលទាំង ការបង្កើតនូវ :

- អ្នកជំរុញ និងអ្នកតាមដានដូចជាមន្ត្រីទទួលបន្ទុកស៊ើបអង្កេតលើការប្តឹងផ្តល់របស់សាធារណៈ រឺ គណៈកម្មាធិការ រឺ ក្រុមប្រឹក្សាសំរាប់ការពារប្រឆាំងទប់ទល់និងការរើសអើង ។
- យន្តការសមភាពនៃយេនឌ័រជាតិ ( របៀបរៀបចំរដ្ឋបាល ដោយប្រើឧបករណ៍ និងធនធាន គ្រប់គ្រាន់ ( ទាំងធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីប្រើឥទ្ធិពលលើគោលនយោបាយនៅគ្រប់កំរិតដែលធម្មតារួមមាន យន្តការស្ត្រីជាអ្នកដឹកនាំក្នុងជួររដ្ឋាភិបាលនិងអ្នកជំនាញការយេនឌ័រមកពីអង្គការសង្គមស៊ីវិល ។
- ការបែងចែកសហភាពឬក៏ជនបង្គោលនៅក្នុងក្រសួងនិមួយៗនៅកំរិតថ្នាក់ជាតិ និង វិមជ្ឈការ

- បង្កើតចំណុចូលអនុវត្តឱ្យបានច្បាស់លាស់ក្នុងគោលនយោបាយទាំងមូលនិងវដ្តកម្មវិធីនៃអង្គការដែលពាក់ព័ន្ធដើម្បីឆ្លើយតបនឹងការជំរុញអោយមានសមភាពយេនឌ័រ ។
- បង្កើតគោលដៅចំពោះការជ្រើសរើសបុគ្គលិក និងការជំរុញឆ្ពោះទៅរកការតំណាងដោយស្មើភាពគ្នារបស់ស្ត្រីឱ្យច្រើនទៀតជាពិសេសក្នុងភាពជាអ្នកដឹកនាំអង្គការឬអង្គភាព ។

## ៣.២.៤ ផ្តល់សំលេងដល់ក្មេងស្រី និង ស្ត្រី

កុមារី និងស្ត្រីចាំបាច់ត្រូវផ្តល់នូវឱកាសដើម្បីចូលរួម និងទទួលបានផលប្រយោជន៍ពីកម្មវិធីអភិវឌ្ឍន៍ឈរលើ មូលដ្ឋានស្មើភាពគ្នាជាមួយបុរស ។ ទាំងក្មេងប្រុស និងក្មេងស្រីត្រូវការជាចាំបាច់ នូវការសិក្សាវ័យក្មេង ចំពោះ ការសំរេចចិត្តដែលត្រូវធ្វើឡើងក្នុងភាពជាដៃគូរវាងបុរស និង ស្ត្រី ។



ដោយមានការរាប់បញ្ចូលស្ត្រីច្រើនទៀតនៅក្នុងអង្គការនានានិងនៅក្នុងដំណើរការនៅពេលធ្វើការសំរេចចិត្តមិនឆ្ពោះទៅរកគោលការយេនឌ័រដោយស្វ័យប្រវត្តិទេកម្មវិធីអង្គការនិងយន្តការស្ត្រីមិនមែនជាអ្នកជំរុញសមភាពយេនឌ័រទោះយ៉ាងណាក៏ដោយអទិភាពរបស់ស្ត្រីនឹងធ្លាក់ចុះទៅជាអ្នកជំរុញដ៏សកម្មភាពសំរាប់ការផ្លាស់ប្តូរឱ្យមានទំនាក់ទំនងស្មើគ្នានៃយេនឌ័រចំណែកហេតុផលដ៏សមញ្ញមួយដែលពួកគេចែករំលែកទំនាក់ទំនងយេនឌ័រនិងការជំទាស់ជាមួយស្ត្រីដ៏ទៃៗទៀត នៅក្នុងសង្គមរបស់ពួកគេ ។

ការចូលរួមរបស់បុរសស្មើភាពគ្នានិងស្ត្រី ក្នុងការធ្វើការសំរេចចិត្តជាធម្មតាមានន័យថា អត្រាចូល រួមរបស់ស្ត្រី ត្រូវការជាចាំបាច់អោយបង្កើនយ៉ាងរឹងមាំ នៅក្នុងកំរិតខ្ពស់នៃអង្គភាព ។ ចំពោះគោល បំណងនេះ អង្គភាពជាច្រើន បានទទួលយកគោលដៅមានពេលវេលាដ៏ជាក់ច្បាស់មួយសំរាប់ការបង្កើនតុល្យភាពនៃ យេនឌ័រ ក្នុងចំណោមបុគ្គលិករបស់ពួកគេ ។ ពេលដែលភាគរយនៃការចូលរួមរបស់ស្ត្រី និង ពឹងផ្អែកទៅលើបញ្ហា វិស័យនានានិងការបង្កើតអោយមានយេនឌ័ររហូតដល់ធ្វើអោយពួកគេជឿជាក់ ឧទាហរណ៍ ការរួមបញ្ចូលស្ត្រីមួយ នាក់ ឬ ក៏ពីរនាក់តែប៉ុណ្ណោះ ការងារនេះនឹងមិនដំណើរការទេ ។

- ជាទូទៅតំណាងភាគរយរបស់ស្ត្រី រឺ បុរសគួរមានចំណាត់ថ្នាក់រវាង ៤០ និង ៦០ ភាគរយ ក្នុងក្រុម ចំរុះដើម្បីបង្ហាញអោយឃើញតុល្យភាពនៃមតិរបស់បុរស និងស្ត្រី ។
- ច្បាប់ជាមូលដ្ឋានដ៏សំខាន់មួយគឺ ធានានូវអាត្រាតំណាងនៃ៣០ភាគរយចំពោះភេទនីមួយៗ ជាអតិប្បរមារ បើពុំនោះទេ វាមានការលំបាកចំពោះអ្នកណាដែលនៅក្នុងមតិភាគតិចឱ្យទទួលនូវការគាំទ្រដ៏មានប្រសិទ្ធភាព

ប្រសិនបើស្ត្រីបានចូលរួមក្នុងសង្គមជាពលរដ្ឋ " ថ្នាក់ទី២ " រឺ ប្រសិនជាប្រពៃណីវប្បធម៌ រឺក៏ជាកំលាំង ឯទៀតដែលបង្អាក់ការនិយាយទាក់ទងគ្នាដោយសេរីរវាងបុរសនិងស្ត្រីនៅទីសាធារណៈនោះស្ត្រីមានការខ្មាស់អៀនខ្លាំងដើម្បីបញ្ចេញមតិរបស់ខ្លួនក្នុងចំណោមអ្នកស្តាប់ដែលលាយឡំ ។ ក្នុងករណីបែបនេះយន្តការដាច់ដោយឡែកចាំបាច់ត្រូវបង្កើតដើម្បីកំណត់អោយស្ត្រីនិងបុរសនៅទីដ៏ទៃពីគ្នាដើម្បីថាសំលេងរបស់ភេទទាំងពីរនេះអាចគេស្តាប់លឺនិងយកមកគិតនិងដើម្បីបង្កើតភាពជឿទុកចិត្តរបស់ស្ត្រី ។ ឧទាហរណ៍ ប្រសិនបើសហគមន៍ត្រូវបំបែកចេញដោយឡែកដោយភេទវាអាចជាការចាំបាច់ដើម្បីបង្កើតគណកម្មាធិការអប់រំដាច់ ដោយឡែកមួយសំរាប់ស្ត្រីជាការបន្ថែមទៅលើគណកម្មាធិការ ឳពុក ម្តាយ ដែលមានរួចមកហើយ ប្រសិនបើគណៈកម្មាធិការដែលមានចុងក្រោយនេះគឺត្រឹមតែសំរាប់បុរស ឯស្ត្រីត្រូវគេមិនអនុញ្ញាតិអោយចូលរួមឬបញ្ចេញមតិនៅក្នុងគណកម្មាធិការដើម្បីជួយឳពុក ម្តាយបាននិយាយចំពោះការសិក្សារបស់កូន ។

### ៣.២.៥ ការរៀបចំគំរោងថវិការ និងការជម្រះបញ្ជីរយ៉េនឌ័រ




ថវិការយ៉េនឌ័រ :" ថវិការយ៉េនឌ័រ Gender Sensitive" ឬថវិការស្ត្រីសំដៅចំពោះដំណើរការ និងឧបករណ៍ ផ្សេងៗដែល១-វាយតម្លៃលើការប្រើគំរោងថវិការក្នុងចំណែកផលប៉ះពាល់ខុសៗគ្នាលើគ្រប់វ័យលើក្រុមផ្សេងៗគ្នានៃស្ត្រីនិងបុរសគ្រប់វ័យ និង ២ អនុញ្ញាតិអោយការរៀបចំគំរោងការប្រតិបត្តិ ឬការត្រួតពិនិត្យឡើងវិញ នៃសកម្មភាពជាក់លាក់នៃយ៉េនឌ័រ ។

ថវិកាយ៉េនឌ័រ ឬថវិកាសំរាប់ស្ត្រីមិនមែនជាថវិកាដាច់ដោយឡែកសំរាប់ស្ត្រីឡើយ ។ ថវិកា Gender-Sensitive គឺអំពីការប្រែច្បាប់ គោលនយោបាយ និងការប្តេជ្ញាចិត្តរៀបចំកម្មវិធីទៅកាន់ភាពស្មើគ្នានៃយ៉េនឌ័រ ទៅក្នុងការសន្យាផ្តល់ថវិការទាំងក្នុងការបែងចែក នឹងអនុញ្ញាតិ សកម្មភាពជាក់លាក់នៃយ៉េនឌ័រតួយ៉ាងដូចជាដើម្បីអនុវត្តឱកាសស្មើភាពគ្នាឬក៏ច្បាប់គ្មានការរើសអើង ។

គំរោងថវិកាយ៉េនឌ័ររួមមាន :

- គ្មានការបែងចែកភេទ ផលប៉ះពាល់នៃការបញ្ចូលការចាយវាយដោយផ្លូវកាត់គ្រប់ផ្នែក និងសេវាទាំងអស់
- ការរៀបចំផែនការនិងការអនុវត្តឬត្រួតពិនិត្យឡើងវិញ នៃការបែងចែកយ៉េនឌ័រជាក់លាក់ ។ ឧទាហរណ៍ គោលនយោបាយ និង ឱកាសស្មើភាព និងការបែងចែកនៅក្នុងសេវាកម្មរដ្ឋាភិបាលឬក៏កម្មវិធីពិសេស នៃការដាក់គោលដៅ ស្ត្រី ក្មេងស្ត្រី និងក្មេងប្រុសឬបុរស ដើម្បីដោះស្រាយភាពមិនស្មើគ្នា ។

**ការជម្រះបញ្ជីរយ៉េនឌ័រ :** គឺជាការត្រួតពិនិត្យឡើងវិញឬក៏ជាការវាយតំលៃនៃការអនុវត្ត របស់អង្គការមួយក្នុងការជំរុញអោយមានសមភាពនៃយ៉េនឌ័រ ។ ការជំរះបញ្ជីរយ៉េនឌ័រមួយសម្រួលការរៀនរៀបចំជាលក្ខណៈបុគ្គល ឯកសារការងារ និងក៏រិតនៃការ រៀបចំរបៀបប្រតិបត្តិយុទ្ធសាស្ត្រ ការបញ្ជ្រាបយ៉េនឌ័រអោយមានប្រសិទ្ធភាពក្នុងគោលនយោបាយ កម្មវិធី និង រចនាសម្ព័ន្ធ របស់អង្គការមួយ ។

## ៣.៣ យុទ្ធសាស្ត្រៈចំបង តើត្រូវធ្វើអ្វី និងត្រូវធ្វើដូចម្តេច

ដើម្បីសំរួលការអនុវត្តន៍ នៃឧបករណ៍បញ្ជ្រាបការយ៉េនឌ័រខាងលើក្នុងកម្មវិធី និងគំរោងប្រឆាំងពលកម្មកុមារ និងការជួញដូរយុទ្ធសាស្ត្រខាងក្រោមនេះអាចយកប្រើប្រាស់ដើម្បីយកបញ្ហាសមភាពយ៉េនឌ័រមកដាក់បញ្ចូលនៅគ្រប់កម្មវិធីនិងគំរោង ខ្នាតតូច និង កម្មវិធីសកម្មភាពប្រឆាំងនិងពលកម្មកុមារ ។ អនុសាសន៍ផ្តល់ជូនចខាងក្រោម គឺមានសុពលភាពផងដែរដើម្បីកែប្រែភាពពុំស្មើគ្នាដែលត្រូវបានប្រឈមមុខដោយក្រុមបន្ទាប់បន្សំផ្សេងទៀតដូចជាជនជាតិភាគតិច ឬជនជាតិភាគតិចដែលជឿសាសនាយ៉ាងមាំ ឬជនពិការ ។ ក្នុងករណីដូចនេះក្មេងស្រីនិង ស្ត្រីក្នុងចំណោមក្រុមទាំងនោះ ជាញឹកញាប់ត្រូវការលៃលកដោះស្រាយជាមួយនឹងផលប៉ះពាល់នៃការរើសអើង គ្រប់ស្រទាប់វណ្ណៈ ។ ឧទាហរណ៍ ក្មេងស្រីម្នាក់អាចប្រឈមមុខទល់នឹងការរើសអើងដោយសារតែនាងនៅក្មេង ។ នាងជាស្ត្រីម្នាក់ដែលចំណាកស្រុកមកពីជនជាតិភាគតិចមួយដែលធ្វើការក្នុងវណ្ណៈទាបមួយដូចជាអ្នកបំរើតាមផ្ទះ រឺក៏អ្នកបំរើផ្លូវភេទ ។

### ៣.៣.១ តើត្រូវធ្វើអ្វី

- ផ្តល់ឱកាសស្មើគ្នាដល់ជនគ្រប់រូប និងដោះស្រាយវិសមភាពយ៉េនឌ័រប្រសិនបើមានម្យ៉ាងវិញទៀតការបញ្ចូលទំហំយ៉េនឌ័រដែលមានភាពជាក់លាក់នៅគ្រប់គោលនយោបាយនិងកម្មវិធីប្រឆាំងពលកម្មកុមារ ។ ដើម្បីប្រាកដថាក្មេងប្រុស និងក្មេងស្រីទទួល អត្ថប្រយោជន៍ស្មើគ្នា ពីគោលនយោបាយ និង កម្មវិធីប្រឆាំងពលកម្មកុមារ សេចក្តីត្រូវការផ្សេងៗរបស់កុមារ ឧបសគ្គ និង ឱកាសត្រូវការអោយគេយកមកពិចារណា ។ ប្រសិនបើក្មេងស្រី ឬ ក៏ម្តាយរបស់ពួកគេឬក៏ក្មេងប្រុស និងបុរសមិនទទួលបានផលប្រយោជន៍ទេ វិធានការពិសេស ៗ ត្រូវការជាចាំបាច់ ដើម្បីដោះស្រាយបញ្ហាស្ថានភាពរបស់ពួកគេ ដើម្បីជំរុញដំណែងរបស់ពួកគេ ដើម្បីអោយ ពួកគេអាចចូលរួម និង ទទួលផលប្រយោជន៍ពីកម្មវិធីអភិវឌ្ឍន៍ស្មើគ្នា ។

កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC របស់អង្គការពលកម្មអន្តរជាតិ (ILO បានប្រើយុទ្ធសាស្រ្តការបញ្រ្ជាបយេនឌ័រ ដែលមានចែងយ៉ាងជាក់លាក់នៅក្នុងកម្មវិធីរបស់ខ្លួននៅឆ្នាំ ២០០១ ។ វាបានរកឃើញក្មេងស្រីដែលធ្វើការជា ក្រុមគោលដៅអទិភាព ។ការអនុវត្តផែនការមានសមាសភាព ៤យ៉ាងដូច តទៅ :




- ការបង្កើតភាពយល់ដឹង និងការកសាងសមត្ថភាពរបស់បុគ្គលិក IPEC និងដៃគូរក្នុងបែបបទរួមគ្នាជាផ្លូវ មួយ ពាក់ព័ន្ធនិង យេនឌ័រក្នុងសកម្មភាពគំរោង ។
- ការកែលំអរមូលដ្ឋានចំណេះដឹងដោយផ្អែកលើយេនឌ័រ និងពលកម្មកុមារតាមរយៈ ការស្រាវជ្រាវ ការវិភាគ យេនឌ័រ នៃប្រតិបត្តិការតាមទីវាល និងអភិវឌ្ឍន៍ឧបករណ៍បញ្រ្ជាបយេនឌ័រ ចំពោះដៃគូររបស់ IPEC
- ការបង្កើកដ៏មានប្រសិទ្ធភាពការត្រួតពិនិត្យនិងការវាយតំលៃចំពោះកាបង្កើត គំរោងឆ្លើយតបឱ្យ មានប្រសិទ្ធិភាពលើយេនឌ័រ
- ការធានានូវយុទ្ធសាស្រ្តដ៏ប្រាកដមួយសំរាប់គំរោងថវិការលើយេនឌ័រ : ការរកឃើញមូលនិធិសំរាប់ សមាសភាពនៃយេនឌ័រនៅក្នុងឯកសារកម្មវិធីអភិវឌ្ឍគំរោងការងារនិងការបង្កើតឡើងជាផ្អែកលើទំហំយេនឌ័រ និងការ រួមបញ្ចូល ការបញ្រ្ជាបនៃយេនឌ័រ ក្នុងគំរោងថវិការរបស់ IPEC ។

- ការជ្រើសរើសយកការព្រួយបារម្ភឬបញ្ហារបស់សមភាពយេនឌ័រ ដើម្បីយកមកពិចារណានៅឯតំណាក់កាលដំបូងបំផុត នៃវដ្តកម្មវិធី និងនៅកំរិតខ្ពស់បំផុតនៃការចងក្រងគោលនយោបាយការបង្កើតកម្មវិធី និង ការបង្កើតគំរោងថវិការ ។ ពិតមែនហើយការព្រួយបារម្ភពីភាពស្មើគ្នានៃយេនឌ័រអាចនឹងត្រូវបានគេដោះស្រាយក្រោយពីវដ្តនៃគំរោងនៅពេលដែលអ្នកអនុវត្តន៍គំរោងរកឃើញថាមានបញ្ហាទំនាក់ទំនងយេនឌ័រកើតមានឡើង ។ ទោះបីយ៉ាងណាក៏ដោយ វាមានតំលៃស្មើដើម្បីបញ្ចូលការព្រួយបារម្ភសមភាពផ្អែកយេនឌ័រនៅក្នុងដំណាក់កាលដំបូងនៃការធ្វើផែនការនិងការរៀបចំគំរោងនៅពេលដែលកម្មវិធីនឹងថវិការកំពុងរៀបចំដោយអ្នកអនុវត្ត និង យល់ព្រមដោយអ្នករៀបចំគោលនយោបាយ ។

Juan samovia ដែលជាអគ្គនាយកប្រតិបត្តិទូទៅនៃអង្គការ ILO បានថ្លែងក្នុងសន្ទរកថានៅថ្ងៃបុណ្យសិទ្ធិនារីអន្តរជាតិថ្ងៃទី ០៨ ខែមិនា ឆ្នាំ ១៩៩៩ នៅទីក្រុងសឺណែវថា "ខ្ញុំបានក្លាយមកជាអ្នកជួយគាំទ្រដ៏ពិតប្រាកដម្នាក់នៃសមភាពយេនឌ័រ មិនមែនសំរាប់តែហេតុផលនៃគោលការណ៍ដែលខ្លួនផ្ទាល់សមតែល្មមគ្រប់គ្រាន់នោះទេ ប៉ុន្តែក៏សំរាប់មូលហេតុដែលមានកម្មវិធីផងដែរ......... ការជំរុញអោយមានសមភាពនៃយេនឌ័រ វាមិនគ្រាន់តែ ជារឿងរ៉ាវដែលត្រឹមត្រូវ ដែលត្រូវតែធ្វើប៉ុណ្ណោះទេ វាគឺជារឿងរ៉ាវដ៏ឈ្លាវឆ្លាត ដែលត្រូវធ្វើផងដែរ " ។ភ្លាមៗ បន្ទាប់ពីចូលកាន់ការិយាល័យនៅខែមិនា ក្នុងឆ្នាំ ១៩៩៩អគ្គនាយកប្រតិបត្តិរបស់ ILO បានធ្វើសច្ចា ប្រនិធានសន្យាយ៉ាងមុតមាំនឹងផ្តល់សមភាពនៃយេនឌ័រ និងការបញ្រ្ជាបយេនឌ័រ ដើម្បីសំរេចគោលដៅនៃសមាហរណកម្មយេនឌ័រ នៅក្នុងតំបន់គោលនយោបាយ ៣ របស់ ILO :

- ការតំណាង : ធ្វើអោយប្រសើរឡើង នូវតុល្យភាពនៃបុគ្គលិក វិជ្ជាជីវៈក្នុងក្របខ័ណ្ឌ ILO ឆ្ពោះទៅកាន់គោលដៅ ៥០% ជាស្រ្តីក្រោយឆ្នាំ ២០១០ និង បង្កើតឡើងនូវទីកន្លែងការងារដែលស្អិតរ មួតដូចគ្រួសារថែមទៀត ។
- បញ្ជីរខ្លឹមសារសមភាពនៃយេនឌ័រ ត្រូវបានបញ្ចូលរួមគ្នារនៅក្នុងគ្រប់ការងារបច្ចេកទេសសកម្មភាពគាំពារ និងប្រតិបត្តិរបស់ ILO ។
- រចនាសម្ព័ននៅគ្រប់ផ្នែកទាំងអស់ គឺត្រូវបានតំរូវអោយធ្វើការអភិវឌ្ឍន៍និងពង្រឹងការរៀបចំស្ថាប័ន ដើម្បីធ្វើការបញ្រ្ជាបយេនឌ័រអោយមានប្រសិទ្ធិភាពនៅក្នុងការងាររបស់ពួកគេ : បញ្ហាយេនឌ័រ នឹងត្រូវបាន បញ្ចូលរួមគ្នា ទៅក្នុងយន្តការថ្មីនិងយន្តការមានស្រាប់ ដើម្បីការរៀបចំកម្មវិធី ការប្រតិបត្តិ ការត្រួតពិនិត្យ និងការវាយតំលៃ ។

- សកម្មភាពប្រឆាំងនឹងការជួញដូរពលកម្មកុមារអាចទទួលបានជោគជ័យ ប្រសិនបើសកម្មភាពនោះរួមមានយុទ្ធសាស្រ្តដោះស្រាយទាំងតំរូវការជាក់ស្តែងនិងតំរូវការយុទ្ធសាស្រ្តយេនឌ័ររបស់អ្នកទទួលផលប្រយោជន៏មាននៅក្នុងកម្មវិធី ។ កម្មវិធីនិមួយៗមានចរិតលក្ខណៈជាក់លាក់របស់ខ្លួនអាស្រ័យលើតំរូវការនិងស្ថានភាពរបស់ក្រុមគោលដៅ ។ចំពោះហេតុផលនោះអ្នករៀបចំកម្មវិធីនិងអ្នកអនុវត្តគួរស្តាប់និងមើលហើយត្រូវប្រុងប្រៀបជានិច្ចក្នុងការរក វិសមភាពយេនឌ័រដែលបង្អាក់ដំណោះស្រាយដោយជោគជ័យនៃបញ្ហាការជួញដូរពលកម្មកុមារ ។ ឧទាហរណ៏ ការ កំហិតតាមផ្លូវច្បាប់និងការអនុវត្តពាក់ពន្ធ័និងការទទួលបានរបស់ស្រ្តីក្នុងការទទួលបានដីធ្លីនិងទ្រព្យសម្បត្តិឯទៀត អាចជាឧបសគ្គក្នុងការបង្កើនប្រាក់ចំណូលរបស់ស្រ្តី ។ បញ្ហាពាក់ពន្ធ័យេនឌ័រដ៏ទៃទៀតដូចជាការធ្វើផែនការគ្រួសារ ភាពមានគិរក្នុងវ័យជំទង់ និងអំពើហឹង្សាក្នុងគ្រួសារក៏អាចជាកត្តាអន្តរាគមន៏សំខាន់ៗដែលត្រូវដោះស្រាយក្នុងការ រៀបចំកម្មវិធីប្រឆាំង នឹងការជួញដូរពលកម្មកុមារ ។

សមាគមរៀបចំផែនការភាពជាឪពុកម្តាយនៃប្រទេសថៃ ( PPAT) ជាទីភ្នាក់ងារដៃគូរមួយរបស់គំរោង អនុតំបន់មេគង្គរបស់ ILO ស្តីពីការជួញដូរស្រ្តីនិងកុមារ(TICW) ក្នុងប្រទេសថៃបានផ្តល់ការអប់រំ និងបណ្តុះបណ្តាលដល់ស្រ្តីនិងក្មេងស្រីក្នុងសហគមន៏អំពីសុខភាពបន្តពូជ (រួមមានផែនការគ្រួសារនិង HIV/AIDS) សិទ្ធិមានកូនចៅ ការមិនចង់មានគិរ និងអំពើហឹង្សាក្នុងគ្រួសារ យុទ្ធសាស្រ្តរបស់PPAT ដើម្បីជំរុញសមភាពយេនឌ័រនិងសិទ្ធមានកូនចៅរួមមាន :




- ការផ្តល់ការអប់រំសុខភាពបន្តពូជនិងសេវាកម្មដល់ស្រ្តីក្នុងសហគមន៏
- ការជំរុញឱ្យមានការចូលរួមរបស់សហគមន៏ក្នុងការផ្តល់អំណាចដល់ស្រ្តីឱ្យបានទទួលសេវាកម្មសុខភាព បន្តពូជ
- លើកទឹកចិត្តបុរសឱ្យចូលរួមក្នុងការអប់រំ និងពិគ្រោះយោបលអំពីសុវត្ថិភាពនៃសុខភាពបន្តពូជ
- ផ្តល់ការអប់រំខាងផ្លូវភេទនិងជំរុញសុវត្ថិភាពនៃសុខភាពបន្តពូជក្នុងចំណោមប្រជាជនវ័យក្មេង

ដើម្បីធានាការបង្ហាញអោយមានភាពស្មើគ្នានៃភាពតំណាង និងការចូលរួមយ៉ាងសកម្មរបស់ស្រ្តី និង បុរស គ្រប់កំរិតទាំងអស់ និងជាពិសេសនៅក្នុងធ្វើការសំរេចចិត្ត និងយន្តការផ្សេងៗ នៅគ្រប់ វដ្តនៃគំរោង ។ ឧទាហរណ៏ នៅពេលធ្វើផែនការ ការរៀបចំគំរោង ការអនុវត្តន៍ ការត្រួតពិនិត្យ និងការវាយ តំលៃនៃកម្មវិធី ត្រូវមានការពិគ្រោះជាមួយអ្នកជំនាញយេនឌ័រនិងអង្គការស្រ្តីជាច្រើន និងធ្វើការប្រមូលផ្តុំ តួនាទីរបស់ស្រ្តីដែល ជាគំរូដែលអាចធ្វើទៅបាន ។

- អនុវត្តន៍ការវិភាគផ្នែកយេនឌ័រ និងដើម្បីបំបែកទិន្នន័យសំខាន់ទាំងអស់ ដែលទាក់ទងទៅនិងពលកម្មកុមារ ដោយភេទ មុនពេលចាប់ផ្តើមអន្តរាគមន៍ណាមួយនោះ ។ ដំណើរការនៃការចាប់ផ្តើមនៃកម្មវិធីថ្នាក់ជាតិ IPEC ចាប់ផ្តើម ដោយស្វែងរកទីកន្លែងដែលមានការទាក់ទងនិងពលកម្មកុមារ និងកំរិតនៃ ទំរង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ។ នៅពេលធ្វើការសំរេចចិត្តរៀបចំកម្មវិធី IPEC ការស្រាវជ្រាវជាលើក ដំបូង និងវិភាគតម្រូវការ គួរតែត្រូវធ្វើឡើង ដោយរាប់បញ្ចូលទាំងសកម្មភាពសេដ្ឋកិច្ច និងសកម្មភាពមិន មែនសេដ្ឋកិច្ចនៃកុមារពីអាយុ៥ឆ្នាំឡើងទៅ។ កំរិតការពាក់ពន្ធ័ក្នុងការងារផ្ទះភាពខុសគ្នាដែលអាចកើតមានចំពោះក្មេងប្រុស និងក្មេងស្រី និងតម្រូវការរបស់ពួកគេ ជំរើសយុទ្ធសាស្រ្តដោះស្រាយបញ្ហា និងឱកាស។ ពត៌មាននេះ អាចត្រូវបានគេប្រមូលផ្តុំ ពីប្រភពជាច្រើន ប៉ុន្តែគួររួមបញ្ចូលការពិភាក្សា និងបទសំភាសជាមួយ ក្មេងប្រុស និងក្មេងស្រី ដោយពួកគេផ្ទាល់ និងឪពុកម្តាយរបស់ពួកគេ។

បណ្តាញការងារអភិវឌ្ឍន៍របស់ប្រជាជនតំបន់ខ្ពង់រាប (HPDN មានគោលបំណងលើកកំពស់សមភាពនៃ កុលសម្ព័នជនជាតិភាគតិចតាមតំបន់ភ្នំ ក្នុងប្រទេសថៃ ។

ការវិភាគលើបញ្ហាបានអនុវត្តន៍មុនពេលចាប់ផ្តើមនៃសកម្មភាព បញ្ចេញអោយដឹងនូវបញ្ហាសំខាន់ៗមួយចំនួន ដែលរួមមានកង្វះឋានៈផ្លូវច្បាប់នៃកុលសម្ព័នជនជាតិភាគតិចតំបន់ភ្នំប្រមាណមួយលាននាក់ នៅក្នុងប្រទេស ថៃដែលចំនួន ៣៥០.០០០នាក់ត្រូវបានគេចាត់ទុកជាជនបរទេស រឺជាជនអន្តោប្រវេសន៍ ខុសច្បាប់ហើយ ២៥០.០០០នាក់ ដែលគ្មានរដ្ឋ ស្ថិតនៅក្រោមច្បាប់ប្រទេសថៃ ។ ការរើសអើងនៅក្នុងច្បាប់ចំពោះការអនុវត្តន៍ និងការបដិសេធពីការអភិវឌ្ឍន៍ ស្រ្តីនិងក្មេងស្រីងាយទទួលនូវការកេងប្រវ័ញ្ចជាពិសេស ។ យោងទៅតាម ការវិភាគនេះ (HPDN បានរៀបគំរោងការអន្តរាគមន៍ ជាយុទ្ធសាស្រ្តនៅឯក្រុមសហគមន៍ និងកំរិត បណ្តាញការងារដោយផ្តោតលើយុវវ័យ និងស្ត្រី ។ សមាសភាពពីរយ៉ាងសំខាន់នៃការអន្តរគមន៍បង្កើនដំណើរការសិក្សាក្នុងសហគមន៍ និងការកសាងសមត្ថភាព របស់ក្រុមនិងបណ្តាញការងារ ។

- **បង្កើនដំណើរការសិក្សា** វេទិការស្ត្រី និង ជំរុំវប្បធម៌
- **ការកសាងសមត្ថភាព** ក្រុមប្រឹក្សាយុវជនភាគតិច នៅកំរិតសហគមន៍ ជំរុំយុវវ័យ នៅកំរិតបណ្តាញការ ងារ និងសភាស្ត្រីភាគតិច នៅកំរិតតំបន់ ។



- វិស័យដែលជាទិសដៅ ដែលជាកន្លែងក្មេងស្រីជាច្រើនត្រូវបានគេរកឃើញកំពុងតែធ្វើការ ក្មេងស្រីជាញឹកញាប់ត្រូវបានគេចាប់អារម្មណ៍នៅក្នុងផ្នែកជាច្រើននិងមុខរបរដែលប្រឈមមុខ និងគ្រោះថ្នាក់ខ្ពស់នៃកេងប្រវ័ញ្ចពលកម្មកុមារ។ ពួកគេមានវត្តមានជាតំណាងនៅក្នុងការងារជាស្រីពេស្យានិងការងារតាមផ្ទះ និងទំរង់ផ្សេងទៀតនៃជនរងគ្រោះពីការជួញដូរ។ ការងារគ្រោះថ្នាក់ដ៏គួរអោយព្រយបារម្ភនិងការជួញដូរវាមានភាពពិបាកណាស់ក្នុងការទៅជួបក្មេងស្រីទាំងនោះ។ កម្មវិធីពិសេសនេះបាននាំទៅដល់ការការពារនៃការរំលោភលើពលកម្មកុមារប្រភេទនេះ។ លើសពីនេះទៅទៀតការធ្វើសមាហរណកម្មគំរោងវាត្រូវការដើម្បីដកចេញពួកគេពីការងារ និងការផ្តល់ដល់ពួកគេនិងគ្រួសាររបស់ពួកគេជាមួយជំរើសផ្សេងៗ ។

កម្មវិធី Kasamahay ផ្តល់មូលនិធិដោយ វេទិកាវVisayan (Visayan Forum Foundation ក្នុងប្រទេសហ្វីលីពីនបានជួយកុមារ បំរើការតាមផ្ទះទាំងក្នុងប្រភពក្នុងគោលដៅ សហគមន៍ ពី Visayo និង MIndanao ដល់ Manila ។ កម្មវិធី Kasambahy ដែលបានចាប់ផ្តើមនៅឆ្នាំ២០០១ ប្រកាន់យកវិធីសាស្ត្រ បីមុខព្រួញ គឺ :

- **សេវាកម្មផ្ទាល់-** រួមមាន ទីលំនៅបណ្តោះអាសន្ន ទំហំសន្តិសុខសង្គម និង ឱកាសទទួលការសិក្សា ត្រូវបានគេផ្តល់ឱ្យជាង ៥.000 CDWS ដែលភាគច្រើននៃពួកគេជាក្មេងស្រី ។
- **ការរៀបចំ**-ក្នុងឆ្នាំ ១៩៩៥ វេទិការ Visayan (Visayan Forum) បានជួយបង្កើត SUMAPI (សមាគមន៍នៃការទាក់ទងគ្នា នៃកុមារបំរើការតាមផ្ទះនៅប្រទេសហ្វីលីពីន ។
- **ការតស៊ូមតិ**-Kasambahy អំពាវនាវអោយមានការចាប់អារម្មណ៍ និង សកម្មភាពចំពោះស្ថានភាពដ៏អាក្រក់ចំពោះ កុមារបំរើតាមផ្ទះតាមរយៈការបញ្ចុះបញ្ចូលនិងការចូលរួមវិភាគទានចំពោះកិច្ចការពារពលកម្មក្នុងច្បាប់សំរាប់ការងារតាមផ្ទះ និងការគាំទ្រជាស្ថាប័នដល់ CDW ក្នុងកម្មវិធីជាតិ ។



- ការកំណត់ក្រុមគោលដៅពលករកុមារដែលមើលមិនឃើញភាគច្រើននៃពួកគេគឺជាក្មេងស្រី ដែលប្រើវិធីសាស្ត្រ ជាក់លាក់ជាតំបន់និងគ្រួសារ ។ ជារឿយៗ វាច្រើនកើតមានឡើងនៅតាមទីជនបទ ដែលកំពុង តែឆ្លើយតបទៅនឹងបញ្ហាពលកម្មកុមាររបស់ពួកគេដោយចង់ដោះស្រាយនូវបញ្ហារបស់អ្នកផ្តល់ពលកម្មកុមារជាច្រើន ដែលមិនអាចមើលឃើញជាលើកដំបូងទោះបីជាពួកគេមិនមានការទាក់ទងនៅក្នុងទំរង់អាក្រក់បំផុតនៃពលកម្មកុមារក៏ដោយ ។ នៅក្នុងកាលទេសជាច្រើនមានក្មេងប្រុស និងបុរស ជាច្រើននៅ ក្នុងសង្គម ការងារទូទៅ ដែលធ្វើការនៅក្នុងកន្លែងសាធារណៈ រីឯកុមារី និងស្ត្រីធ្វើការនៅក្នុងផ្ទះឯកជន ដែលគេជួលអោយបំរើ ឬក៏កន្លែងធ្វើការផ្សេងៗទៀត ដែលលាក់កំបាំងពីភ្នែកសាធារណៈជន ។ នៅក្នុងកាលៈទេសៈផ្សេងទៀត មានការអំពាវនាវអោយមានការលុបបំបាត់ពលកម្មកុមារតែ នៅក្នុងឧស្សាហកម្ម ឬកន្លែងការងារជាក់លាក់តែប៉ុណ្ណោះ។ ជាថ្មីម្តងទៀត ដំណោះស្រាយមួយពេល២នឹងមិនឆ្ពោះទៅរកលទ្ធផល ជានិរន្តបានទេ និងអាចនាំឆ្ពោះទៅរកភាពមិនស្មើគ្នាថែមទៀត ក្នុងចំណោមអ្នកដែលទទួលផលដែលរំពឹងទុក ។ វាអាចនិងមានប្រយោជន៍ និងជូនកាលចាំបាច់ ត្រូវចាប់ផ្តើមដោះស្រាយនូវបញ្ហាពលកម្មកុមារ នៅក្នុងផ្នែកជាក់ច្បាស់ណាមួយ ឬ មុខរបរនៅក្នុងតំបន់ភូមិសាស្ត្រណាមួយ។ ទោះបីជាយ៉ាងណាក៏ដោយវាចាំបាច់ត្រូវមានមធ្យោបាយយូរអង្វែង និងដោះស្រាយនូវការរំលោភពលកម្មកុមារទាំងអស់នៅក្នុងតំបន់នេះ។ ឧទាហរណ៍ ដោយការកំណត់គោលដៅលើកម្មករជាក្មេងស្រី ដោយរាប់បញ្ចូលទាំងបងប្រុសរបស់ពួកគេធ្វើការ នៅក្នុងឧស្សាហកម្ម វិស័យកសិកម្ម រឺ ការងារដែលបានដាក់គោលដៅស្ថិតនៅក្រោមកម្មវិធី ។
- ការកែតម្រូវនៃភាពមិនស្មើគ្នា ក្នុងមធ្យោបាយដែលឱ្យក្មេងស្រី និងស្ត្រីអាចទទួលបានការអប់រំនិងការបណ្តុះបណ្តាលមានគុណភាព ។សិទ្ធិទទួលបានការចូលរួមស្មើគ្នារបស់ក្មេងប្រុស និងក្មេងស្រី ដើម្បីទទួល បានការអប់រំ និងការបណ្តុះបណ្តាលមានគុណភាព នៅក្នុងជំនាញដែលអាចរកការងារបាន វាជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ប្រឆាំងពលកម្មកុមារ។ ក្រៅពីការបង្កើនសិទ្ធិរបស់ក្មេងស្រីទទួលបានការអប់រំ និងការបណ្តុះបណ្តាលការចាប់អារម្មណ៍ដ៏សំខាន់គួរផ្តោតលើគុណភាពនៃកម្មវិធីក៏ដូចជាតំរូវការក្នុងការប្រយុទ្ធប្រឆាំងការបែងចែកភេទក្នុងទីផ្សារការងារ។ មានសារៈសំខាន់ណាស់ក្នុងការរៀបចំរូបភាពជាវិជ្ជមាននៃក្មេងស្រី ស្ត្រី ក្មេងប្រុស ហើយធ្វើជាបណ្តាញដល់ក្មេងស្រីនិងក្មេងប្រុសឱ្យចូលរួមក្នុងការបណ្តុះបណ្តាលពហុជំនាញដែលរៀបចំឱ្យភេទទាំងពីរដើម្បីធ្វើការងារផលិត ។ការអប់រំដល់ស្ត្រីនិងបុរសវាមានសារៈសំខាន់មិនសំរាប់តែពួកគេប៉ុណ្ណោះទេវាថែមទាំងជួយឱ្យពួកគេអាចមើលថែរក្សាកូនចៅរបស់គេដោយសមរម្យទៀតផងការអប់រំដល់ស្ត្រីជាពិសេសបានបង្ហាញដើម្បីធ្វើអោយមានការចំណេញខ្ពស់នៃការវិនិយោគលើការបង្កើនឡើងនូវសុខមាលភាពគ្រួសាររបស់ពួកគេ ។

គំរោងការអនុតំបន់ទន្លេមេគង្គ របស់អង្គការ ILO ស្តីពីការជួញដូរកុមារ និង ស្ត្រី (TICW ក្នុងខេត្ត Yunnan នៃប្រទេសចិន ត្រូវបានអនុម័តជា (Cascade training method ក្នុងការជំរុញអោយមាន សមភាពនៃយេនឌ័រក្នុងការសិក្សាដែលជាផ្នែកមួយនៃកម្មវិធីជួញដូររបស់ខ្លួននៅក្នុងតំបន់គោលដៅ ដែល ក្មេងប្រុសជាញឹកញាប់ត្រូវបានផ្តល់អាទិភាពអោយចូលរៀន ។ ដៃគូរក្នុងការប្រតិបត្តិការងារស្តីពី TIC-YANNAN ការិយាល័យ អប់រំក្នុងខេត្ត Jiangcheng និង Menghai បានបណ្តុះបណ្តាលនាយក ១៣៥ នាក់ នៅសាលាបឋមសិក្សា និងអនុវិទ្យាល័យដែលពួកគេអាចបណ្តុះបណ្តាលគ្រូបង្រៀនបាន ៤៧៥ នាក់ ហើយដែល ផ្ទេរការបណ្តុះបណ្តាលដល់សិស្ស ១៣.០០៩ នាក់ ។ នៅក្នុងសមាគមន៍ដែលជាគោលដៅ ក្រុមអ្នកស្ម័គ្រចិត្ត ៤៨ នាក់ ធ្វើការជាមួយឪពុកម្តាយដែលទទួលពតិមានពីកូនរបស់ពួកគេពីសាលា ។




បញ្ជីរសំនួរ pre- and post-training បានបង្ហាញថាការដឹងស្តីពីសមភាពនៃយេនឌ័របានកើនឡើងក្នុង ចំណោមសិស្ស គ្រូបង្រៀន និងប្រជាជននៅក្នុងសហគមន៍។ ការចុះឈ្មោះចូលរៀន របស់ក្មេងស្រីបានកើនឡើង ហើយគ្រូបង្រៀនបានយកចិត្តទុកដាក់ទៅលើការសិក្សា និងការបង្រៀនអំពីការ ជំរុញអោយមានសមភាពយេនឌ័រ ។ ការផ្លាស់ប្តូរ មួយចំនួនលើអកប្បកិរិយា ត្រូវបានសង្កេតផងដែរ ។ ជាឧទាហរណ៍ : ក្មេងប្រុស បានចាប់ផ្តើមបោសកំរាលឥដ្ឋហើយនៅក្នុងគ្រួសារខ្លះម្តាយនិងកូនស្រីត្រូវបានគេអនុញ្ញាតអោយអង្គុយទទួលទានអាហាររួមគ្នាជាមួយនិងឪពុក និងកូនប្រុស ដែលពីមុនស្រីញុំាបាយដាច់ដោយឡែក ឬក្រោយពីបុរសញុំារួច ។

- ការកំណត់ក្រុមគោលដៅដែលក្រីក្របំផុត និងក្រុមគ្រួសារដែលងាយរងគ្រោះ ។ ភាពក្រីក្របណ្តាលមកពីកង្វះខាត នៃសិទ្ធិអាចទទួនបាន និងសិទ្ធិគ្រប់គ្រងធនធនមនុស្ស និងធនធានហិរញ្ញវត្ថុ ឧបករណ៍ និងពត័មាន។ ការតកាត់បន្ថយភាពក្រីក្រ គឺជាការព្យាយាមដ៏តឹងតែងមួយប្រឆាំងនិងពលកម្មកុមារ។ ជាទូទៅវាមាន ការពិបាកបំផុតដើម្បីអោយទៅដល់ក្រុមគោលដៅដែលងាយរងគ្រោះភាគច្រើន នៅក្នុងកម្មវិធីអភិវឌ្ឍន៍-ហើយកិច្ចខិតខំប្រឹងប្រែងពិសេសមួយត្រូវតែធ្វើឡើងដើម្បីអោយគេអាចចូលរួមបាន។ ក្រុមគោលដៅជា អាទិភាពគួរតែត្រូវរាប់បញ្ចូលអ្នកក្រីក្របំផុត។ ភាគច្រើននៃពួកគេកំព្រាម្តាយ ឬកំព្រាឪពុក ឬក្មេងដែលជា មេគ្រួសារ ។

- ផ្តល់នូវជំរើសនៃយុទ្ធសាស្ត្រការរស់នៅដល់គ្រួសារដែលពឹងផ្អែកទៅលើ ឬ ដែលបានធ្លាប់ដោះស្រាយ បញ្ហារួចមកហើយទៅនិងការងារកុមារតាមរយៈការផ្តល់អំណាចសេដ្ឋកិច្ច និងបរិយាកាសសង្គមនៃឪពុកម្តាយ និងកូន។ ដំណោះស្រាយមួយពេលៗជាញឹកញាប់វាមិនអាចនាំទៅដល់លទ្ធផលដែលយើងទន្ទឹងថាបាន នៅក្នុងគំរោង ប្រឆាំងពលកម្មកុមារនោះទេ។ វាមិនបាននាំទៅដល់ការបញ្ចប់ពលកម្មកុមារទេ។ ប៉ុន្តែការរកចំណូលសំរាប់កូន ឬក៏ឪពុកម្តាយរបស់ពួកគេអាចពិតជានាំទៅដល់លទ្ធផលនេះបាន ។ សេវាកម្មចំរុះគឺត្រូវការដើម្បីបង្កើនប្រាក់ចំណូលនិងស្ថានភាពគ្រួសារដែលមានប្រាក់ចំណូលទាបដោយផ្តល់ដល់ពួកគេនូវការបណ្តុះបណ្តាលជំនាញ ផលិតកម្ម អន្ទរកម្ម លេខទំនាក់ទំនងជំនាញបង្កើតក្រុមឬអង្គការ ។ នៅពេលដែលធ្វើការដោយខ្លួនឯងប្រសើរជាងធ្វើការអោយគេស៊ីប្រាក់ខែគឺជាជំរើសដែលអាចធ្វើបានល្អបំផុត សេវាឧបត្ថម្ភការ ប្រកបមុខរបរគឺ ត្រូវបញ្ចូលជាមួយឥណទានខ្នាតតូច ។ពត៌មានស្តីអំពីផលប៉ះពាល់ដ៏អាក្រក់បំផុតនៃពលកម្មកុមារ ការអភិវឌ្ឍន៍មនុស្ស និងសុខមាលភាពគ្រួសារ គឺត្រូវការ ដើម្បីអនុញ្ញាតិ ការប្រើប្រាស់ដ៏មាន ប្រយោជន៍នៃប្រាក់ចំណូលក្នុងគ្រួសារ ។ លើសពីនេះទៅទៀត វិធានការ ដើម្បីអភិវឌ្ឍន៍ ការពង្រឹងការចងក្រងក្រុមនិងកិច្ចសហប្រតិបត្តិការជាញឹកញាប់គឺសំខាន ដើម្បីអោយប្រជាជនគោលដៅអាចរៀនសូត្រពីគ្នាទៅវិញទៅមក និងបានប្រយោជន៍ពីទំហំសេដ្ឋកិច្ច និងការកើនឡើងនៃអំណាចការចរចារ។

ទទួលការបណ្តុះបណ្តាលជាដំបូង (G=យ៉េនដ័រ E=ភាពជាសហគ្រិន T=ទាំងអស់គ្នា ត្រូវបានគេធ្វើដើម្បី ពង្រឹងសកម្មភាពក្នុងការបង្កើតប្រាក់ចំណូល (IGA នៅក្នុងគំរោងខ្លះរបស់ ILO បានជំរុញឱ្យមានឱកាសការងារការបង្កើត ការជួយស្ត្រីដែលក្រីក្រ នឹងការពារការជួញដូរកុមារ និងស្ត្រី ។ដោយមានឥន្ទទានខ្នាត ឧបត្ថម្ភពី អនុតំបន់ទន្លេមេគង្គ ILO គំរោងស្តីពីការជួញដូរកុមារ និងស្ត្រី (TICW មេដឹកនាំសហគមន៍ ស្ត្រីមួយចំនួន ដែលមាន ការចេះដឹងទាបបានទាក់ទិននៅក្នុងការរៀបចំសកម្មភាពកម្មវិធីបង្កើតប្រាក់ចំណូល (IGAs ដូចជាការចិញ្ចឹមជ្រូក និង មាន់ និងការដាំផ្សិត និងសកម្មភាពសេដ្ឋកិច្ច នៅតាមមូលដ្ឋានជនបទផ្សេងៗទៀតគំរោង (TICW) ដែលមាននៅក្នុងប្រទេសឡាវ PDR ក្រៅអំពីឥណទាន និង ការបណ្តុះបណ្តាលវិជ្ជាជីវៈពួកគេត្រូវការជំនាញនិងចំណេះដឹង ផ្អែកលើដំណើរការរកស៊ីទីផ្សារ និងអង្គការក្រុម ដីម្បីទ្រទ្រង់ និង ពង្រីកសកម្មភាពក្នុងការបង្កើតប្រាក់ចំណូលរបស់ពួកគេនៅក៏រិតសហគមន៍ ។

ទទួលការបណ្តុះបណ្តាលជាតំបូង GEP ជាវិធានការដ៏ជាក់លាក់នៃយ៉េនដ័របានកំណត់គោលដៅលើសក្តានុពលមុខជំនួញរបសស្រ្តីក្រីក្រមានគោលបំណងដើម្បីអភិវឌ្ឍន៍សមត្ថភាពសហគ្រិនរបស់ស្ត្រីដើម្បីប្រែក្លាយIGAs របស់ពួកគេទៅក្នុងមីក្រូដែលមានជំនាញ និងសហគ្រាសតូចៗ ជាមធ្យោបាយយ៉ាងមានប្រសិទ្ធិភាព ដើម្បីរារាំងការជួញដូរកុមារ និងស្ត្រីសំរាប់ធ្វើការងារពលកម្ម និងទំរង់ដ៏ទៃទៀតនៃការកេងប្រវ័ញ្ច ។ ដោយ មានការគាំទ្រផ្នែកបច្ចេកទេសពីអង្គភាពជាច្រើននៅក្នុង ILO ទទួលក្បួនហ្វឹកហាត់ជាដំបូង GET ហើយនិងសិក្ខាសាលា របស់អ្នកបណ្តុះបណ្តាលជំនាញ គឺត្រូវគេធ្វើយ៉ាងជោគជ័យនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសឡាវ PDR នៅដើមឆ្នាំ ២០០៣។ ការកសាងសមត្ថភាពបន្ថែមទៀតទៅលើការអភិវឌ្ឍន៍សហគ្រាសរបស់ស្ត្រី និងកើតឡើងសំរាប់សកម្មភាពអង្គការជាដៃគូរក្នុងការការពារនិងការប្រយុទ្ធប្រឆាំងការរំលោភបំពានពលកម្មកុមារការជួញដូរ ហើយនិងការជួយស្ត្រី និងគ្រួសាររបស់ពួកគេដើម្បីជំនះភាពក្រីក្រ ។



- ដោយមានទំនាក់ទំនងទាំងឪពុកម្តាយ នៅក្នុងកម្មវិធីរីគំរោងណាក៏ដោយដែលប្រឆាំងនិងពលកម្ម កុមារ និង យកចិត្តទុកដាក់ចំពោះការចែករំលែកការទទួលខុសត្រូវនៅក្នុងគ្រួសារ និង បន្ទុកការងារផ្សេង ទៀត ក៏ដូចជាដំណើរការនៃការធ្វើការសំរេចចិត្តនៅក្នុងគ្រួសារ ។ បន្ទុកការងារទាំងមូលរបស់ក្មេងស្រី និងស្ត្រី ជាញឹកញយត្រូវបានគេកាត់បន្ថយ ហើយអនុញ្ញាត្តិអោយពួកគេបានទទួលការសំរាកគ្រប់គ្រាន់ និង ដើម្បីចូលរួមសកម្មភាពផលិតជាច្រើនទៀត ។ បន្ថែមលើការផ្តល់ឧបករណ៍បច្ចេកទេស ដែលជាជំនួយការងារ វាសំខាន់ណាស់ ដើម្បីលើកទឹកចិត្តក្មេងប្រុស និង បុរសដើម្បីទទួលខុសត្រូវចំពោះការងារផ្ទះ ឧទាហរណ៍ បង្កើនលក្ខន្តិកៈនៃការយកចិត្តទុកដាក់ថៃទាំ។ ការផ្លាស់ប្តូរអត្តចរិតនៅក្នុងការទំនាក់ទំនងចំពោះការផ្តល់យោបល់គ្នានៃការធ្វើការសំរេចចិត្តស្មើគ្នារវាងឪពុកម្តាយស្តីអំពីការចំណាយប្រាក់ចំណូលរបស់គ្រួសារក៏ដូចជាត្រូវការចំបាច់ជាផ្នែកមួយ និងជាផ្នែកតូចៗ នៃកម្មវិធីប្រឆាំង ពលកម្មកុមារ ។

បណ្តាញការងាររបស់បុរសកម្ពុជា (CMN ត្រូវបានបង្កើតនៅឆ្នាំ ២០០០ដែលជាផ្នែកនៃយេនឌ័រ និងការ អភិវឌ្ឍន៍សំរាប់ប្រទេសកម្ពុជា (GAD/C កម្មវិធីតស៊ូមតិក្នុងគោលបំណងដើម្បីជួយបុរសអោយយល់ពីតួនាទី និងភាពទទួលខុសត្រូវរបស់ពួកគេក្នុងការនាំឱ្យមានការផ្លាស់ប្តូរសង្គម ។បណ្តាញការងាររបស់បុរសកម្ពុជា(CMN គឺមានសកម្មភាពនៅក្នុងខេត្តចំនួន១២និងក្រុងចំនួន២មានសមាជិកជាង១០០០នាក់ ។ បណ្តាញការងាររបស់បុរសកម្ពុជា បានលើក ទឹកចិត្តសមាជិករបស់ខ្លួន ដើម្បីអោយក្លាយជាឪពុកមានការស្រលាញ់ និងទទួលខុសត្រូវ ។ សមាជិកទាំងនោះបានជួយបុរសផ្សេងៗ អោយយល់ពីបញ្ហាទំហំយេនឌ័រ ដូចជាការជួញដូរស្ត្រី និង កុមារ HIV/AID ។ ការរើសអើងភេទ ការយាយីផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងការរំលោភ ។ សារដ៏សំខាន់គឺទាំងនេះ គឺជាបញ្ហារបស់បុរសផងដែរ ។ រួមជាមួយក្រុមយុវវ័យរបស់ប្រទេសកម្ពុជា បណ្តាញការងាររបស់បុរសកម្ពុជា CMN បានដឹកនាំការបណ្តុះបណ្តាលដែលរួមមាន ទាំងសិទ្ធិមនុស្ស និងសិទ្ធស្ត្រី ដោយមានទាហាន ប៉ូលីស គ្រូបង្រៀន កម្មករ មន្ត្រីរដ្ឋាភិបាល បុគ្គលិក NGO និងបុរសក្នុងសហគមន៍ ។



## ៣.៣.២ ត្រូវធ្វើដោយវិធីណា

- ដើម្បីបង្កើនការយល់ដឹងពីយេនឌ័រនៅក្នុងកម្មវិធីគ្រួសារទាំងអស់អ្នកពាក់ពន្ធ័ស្តីអំពីការលើកតំកើងអោយមានភាពស្មើគ្នានៃយេនឌ័រមនុស្សជាច្រើនមិនទាន់មានការយល់ដឹងនៅឡើយរីក៏លើកទឹកចិត្តអំពីសេចក្តីត្រូវការសំរាប់ដោះស្រាយភាពខុសគ្នារវាងស្ត្រីនិងបុរសព្រមទាំងក្មេងប្រុសនិងក្មេងស្រី ។ កង្វះការយល់ដឹង និងកង្វះវិធាន ការសមស្របដើម្បីដោះស្រាយវិសមភាពយេនឌ័រដែលមាននៅនឹងនាំទៅរកភាពគ្មានការផ្លាស់ប្តូរក្នុងស្ថានភាពដដែល ឬរឹតតែអាក្រក់ថែមទៀតចំពោះស្ថានភាពស្ត្រីនិងក្មេងស្រី ។

SCREAM របស់អង្គការ ILO-IPEC (ការគាំទ្រ សិទ្ធិកុមារតាមរយៈការអប់រំ សិល្បៈ និង ឃោសនា វគ្គអប់រំសំរាប់លើកទឹកចិត្តក្មេងៗក្នុងការប្រើសិល្បៈ ដែលបង្កើតឡើងដើម្បីធានាបញ្ហាមួយចំនួនដែលទាក់ទង និងការងារពលកម្មកុមារជាមួយខ្លឹមសារបញ្ជ្រាបសមភាពយេនឌ័រតាមរយៈវគ្គសិក្សា ។

ជាមួយទស្សនៈនៃការរៀបចំវិសមភាពយេនឌ័រ និងការរើសអើងក្នុងបញ្ហាការងារពលកម្មលើកុមារ វគ្គសិក្សា SCREAM តំរង់ទិសដៅលើកុមារានិងកុមារីរួមគ្នាដោយប្រើការអានឬ ការសរសេរអក្សរ ការសំដែងសិល្បៈ ដែលជាឧបករណ៍មួយដើម្បីជួយពួកគេឱ្យសំដែងចេញនូវអ្វីដោយខ្លួនឯងនិងការផ្តល់ចំណេះដឹងព្រមទាំងជំនាញដល់ ពួកគេដើម្បីនាំមកនូវការផ្លាស់ប្តូរក្នុងសង្គម ។ វគ្គសិក្សានេះជួយពួកគអោយរៀនវិភាគរិះគន់អំពីឥរិយាបទលើ សមភាពផ្លូវភេទ និងធ្វើការផ្តល់ជាអនុសាសន៏អំពីកម្មវិធីគោលនយោបាយ និងការបង្កើតជំនឿទុកចិត្ត និងជំនាញ ដើម្បីបង្ហាញសារ ផ្ទាល់ខ្លួន ដល់ឪពុកម្តាយរបស់ពួកគេ សហគមន៍ និងអ្នកធ្វើការសំរេចចិត្ត ។



- ការវាយតំលៃ និងការពង្រឹងសម្ថភាពរបស់បុគ្គលិក ដើម្បីដោះស្រាយរាល់សេចក្តីត្រូវការរបស់ក្មេងស្រី និងក្មេងប្រុស បុរស និងស្ត្រីនិងការងាររបស់ពួកគេអោយកាន់តែមានភាពស្មើគ្នានៃយ៉េនឌ័រកាន់តែធំធេង ឡើង ។
- ការពង្រឹងក្រុមរបស់ស្ត្រីចល័ត និងអង្គភាព ។ ក្រុមរបស់ស្ត្រីអាចជាឧបករណ៍ដ៏មានអំណាចនៅក្នុងការតស៊ូបឆាំង ពលកម្មកុមារ ។ ការពង្រឹងកំលាំងនិងអំណាចចំពោះស្ត្រី មានន័យថា កុមារនឹងមានន័យថា ធ្វើអោយជីវភាពកុមារ ប្រសើរជាងមុនផងដែរ ។

អង្គការជាច្រើនដូចជាសហជីពស្ត្រី នៅក្នុងប្រទេសចិន នៅឡាវ និង វៀតណាម អាចមានប្រសិទ្ធភាពណាស់ ក្នុងការបង្កើនការយល់ដឹង ពីកិរិតនៃការធ្វើនយោបាយ ដល់សហគមន៍នៅក្នុងតំបន់ជនបទ និងទីក្រុង ។ កាលពី អតីតកាល អង្គការនោះជាញឹកញាប់បានដោះស្រាយតំរោងស្ត្រីក្នុងរូបភាពតូចៗតែប៉ុណ្ណោះ ។ ក្នុងពេលសព្វថ្ងៃនេះ សហជីពទាំងនោះបានចាត់វិធានការណ៍ទៅរកការបញ្ចៀតនៃយ៉េនឌ័រ ដែលនាំទៅដល់ការជោគជ័យ ។ ទោះជាយ៉ាងណាក៏ដោយការបញ្ច្រៀបយ៉េនឌ័រនិងការព្រួយបារម្ភរបស់ស្ត្រីនៅក្នុងសង្គមដ៏ធំមួយនិងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតែជាបញ្ហាប្រឈមមុខ ដដែល ។

- ជៀសវាងការប្រើភាសាលំអៀងនិងអនុវត្តលំអៀង និងផ្តត់រូបារម្មណ៍របស់យ៉េនឌ័រ ។ ឧទាហរណ៍ នៅពេលដែលអភិវឌ្ឍន៍សំភារៈបណ្តុះបណ្តាល និងយុទ្ធាការលើកកំពស់ការយល់ដឹង ឬនៅពេលដែលជ្រើស រើសបុគ្គលិក ។
- ផ្តល់ការទទួលខុសត្រូវចំពោះការជំរុញនៃភាពស្មើគ្នា ទៅកាន់ជនណាដែលពាក់ព័ន្ធនៅក្នុងកម្មវិធី ។ រៀបចំសកម្មភាពផ្សព្វផ្សាយ ដើម្បីបង្កើនជំរុញគំនិតយ៉េនឌ័រ និងសមត្ថភាពជំនាញដើម្បីបញ្ចូលបញ្ហាយេនឌ័រ ក្នុងការងាររបស់ពួកគេ ។
- ប្រសិនបើអតុល្យភាពរវាងស្ថានភាពរស់នៅរបស់ស្ត្រីនិង បុរសកើតមានឡើង ផែនការ ថវិការ និងត្រូវប្រើ ប្រាស់ជំនាញយ៉េនឌ័ រយ៉ាងជាក់ច្បាស់ នៅគ្រប់វដ្តនៃកម្មវិធី ។ ប្រភពធនធានគ្រប់គ្រាន់ ត្រូវទុក ដោយឡែកសំរាប់ អ្នកវិភាគយ៉េនឌ័រក្នុងការស្រាវជ្រាវនិងការអនុវត្តការវាស់វែងជាក់លាក់ដើម្បីដោះស្រាយ អតុល្យភាព នៃយ៉េនឌ័រ ។ ជាញឹកញាប់វាមានសារៈសំខាន់ណាស់ដើម្បីបង្កើតគោលដៅចំពោះបុគ្គលិកទាំងពីរ ភេទដើម្បីធានាការជ្រើសរើសស្ត្រី ក្នុងករណីដែលក្មេងស្រីនិងស្ត្រីមានប្រសិទ្ធិភាពជាងបុរស ។
- វិភាគនូវផលប៉ះពាល់ផ្សេងគ្នាចំពោះកម្មវិធីស្តីអំពីក្មេងស្រី និងស្ត្រី ក្មេងប្រុស និងបុរស នៅដំណាក់ការត្រួតពិនិត្យនិងវាយតំលៃ និងបង្កើតការតាមដានសកម្មភាពដ៏សមរម្យមួយ ។ ដូចដែលបានរៀបរាប់ខាងលើ វានិងប្រសើរជាងប្រសិនបើយើងចង្អុលបង្ហាញអោយឃើញ និងដោះស្រាយ ភាពមិនស្មើគ្នា នៃយ៉េនឌ័រ នៅតំណាក់កាលរៀបចំគំរោងនៃកម្មវិធីនោះ ។ យ៉ាងនេះក៏ដោយជាពិសេសនៅពេលដែលកម្មវិធីមិនអើរពើយ៉េនឌ័រជាសំខាន់ត្រូវក្រឡេកមើលបញ្ហាយ៉េនឌ័រសំខាន់ៗនូវដំណាក់កាលត្រួតពិនិត្យនិងវាយតំលៃកែប្រែស្ថានភាព ។
- ទាក់ទិននិងនិយោជកនិងសហជីពដែលត្រូវគេចាត់តាំងឡើងដើម្បីវាយតំលៃនិងកំណត់តម្រូវការទីផ្សារពលកម្មនិងជំរុញអោយប្រើកិច្ចសន្យាត្រឹមត្រូវ និងការត្រួតពិនិត្យមើលស្តង់ដាការងារជាមូលដ្ឋាន ទាក់ទងនឹងពលកម្មចំណាកស្រុក និយោជកនិងបុគ្គលិតអង្គការ អាចដើរតួរនាទីជាអ្នកតវ៉ា ជាពិសេសសំរាប់ច្បាប់ និងវិវត្តិភាពក្នុងការផ្លាស់ប្តូរការងារ និងការធ្វើនិប្រវេសន៍ត្រឹមត្រូវនៃកម្មករនិប្រវេសន៍ ។ សហជីពអាចដើរ តួនាទីជាផ្នែកមួយ ក្នុងការប្រយុទ្ធប្រឆាំងខាងការប្រកាន់ជាតិសាសន៍ យ៉េនឌ័រ និងប្រភេទនៃការរើសអើង ដ៏ទៃទៀត ដែលជារឿយៗជះឥទ្ធិពលដល់ស្ត្រី និងកម្មករដែលងាយរងគ្រោះ ផ្សេងទៀត ។

NUWHRAIN (សហជីពកម្មករជាតិនៅតាមសណ្ឋាគារ និង សម្ព័ន្ធឧស្សាហកម្ម បានធ្វើកម្មវិធីរួម មួយជាមួយ ILO តាំងពីឆ្នាំ ១៩៩៩។ គម្រោងរបស់ NUWHRAIN ស្តីពីសកម្មភាពសហជីពក្នុងការ ប្រយុទ្ធប្រឆាំងនិងពលកម្មកុមារនៅក្នុងឧស្សាហកម្មទេសចរណ៍នៅប្រទេសហ្វីលីពិន មានគោលបំណងផ្តើមដោះស្រាយការកេងប្រវ័ញ្ចលើកុមារ ជាពិសេសការកេងប្រវ័ញ្ច ផ្លូវភេទនៅក្នុងឧស្សាហកម្មទេសចរណ៍ ។ វាផ្តោតទៅលើការអភិវឌ្ឍន៍ស្ថាប័ននៃសហជីពនៅក្នុងការការពារ ការរំលោភពលកម្ម កុមារនៅតាមផ្លូវខាង ក្រៅជាច្រើន multifaceted approach រួមមានការស្រាវជ្រាវ ការគាំទ្រ ការរួបរួមសង្គម ការបញ្ចុះបញ្ចូល ការជំដែកដោះស្រាយប្រតិបត្តិការនៃ ការិយាល័យពលកម្មកុមារ ការអោយដំបូន្មាន និង referal ។ NUWHRAIN គឺជាសាខាសហជីពអន្តរជាតិនៃស្បៀងអាហារ កសិកម្ម សណ្ឋាគារ ភោជនីយដ្ឋាន ការផ្តល់ម្ហូប អាហារ និង សមាគមន៍កម្មកររោងចក្រ បារី (IUF ។ វាមានសាខា ក្នុងស្រុកចំនួន ៤៥ ដោយ មានសមាជិកសហជីព ចំនួន ៦.០០០ នាក់នៅក្នុង ៥ តំបន់ នៃប្រទេសហ្វីលីពីន ។







- បង្កើតបណ្តាញការងារអង្គការដែលមានជំនាញទាំងយេនឌ័រនិងពលកម្មកុមារដើម្បីចែករំលែកបទ ពិសោធន៏និងឧបករណ៏។ មានសារៈសំខាន់ណាស់ក្នុងការលើកទឹកចិត្តឱ្យមានសហប្រតិបត្តិការ និង សកម្មភាពរួមគ្នាក្នុងចំណោមស្ថាប័នពលកម្មនិងដៃគូសង្គមដើម្បីជំរុញឱ្យមានសមភាពយេនឌ័រនៅក្នុងការងាររបស់ខ្លួនក៏ដូចជាក្នុងសង្គមទាំងមូលផងដែរ។